# ទស្សនាវដ្ដី
# ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
## *Magazine of the Ministry of Culture and Fine Arts*



### ការរៀបចំខ្សែទស្សនាចរ ភ្ញៀវទេសចរតំបន់អង្គរ
របត់ថ្មីនៃទេសចរណ៍អង្គរៈ
ការគ្រប់គ្រងលំហូរភ្ញៀវនិងខ្សែទស្សនាចរចម្រុះ

### ចេតិយវត្តសាលាម្នាង ខេត្តកោះកុង
វត្តនេះកសាងឡើងតាំងពីសតវត្សទី១៥
ស្ថិតក្នុងស្រុកស្រែអំបិល។ ឈ្មោះ "សាលាម្នាង"
មានប្រភពមកពីរឿងព្រេងទាក់ទង
នឹងសាលាសំណាក់ស្រីស្នំរបស់ព្រះរាជា

### កិច្ចគាំពារបេតិកភណ្ឌរូបីនិងអរូបី
បេសកកម្មដើម្បីព្រលឹងជាតិ និងបេតិកភណ្ឌ

### តម្បាញកន្ទេលផ្ការ ខេត្តសៀមរាប
តម្បាញកន្ទេលផ្ការ ជាសិប្បកម្មបុរាណ
របស់អ្នកស្រុកអង្គរធំ ខេត្តសៀមរាប

### រឿងដើមពុទ្រាឧត្តមា
រឿងរ៉ាវនៃក្តីស្រឡាញ់ ការលះបង់
និងការចាប់ផ្តើមសារជាថ្មីរបស់ក្មេងស្រីម្នាក់
ដែលរឹងមាំដូចដើមពុទ្រា

### មហោស្រពភាពយន្តអន្តរជាតិកម្ពុជា លើកទី១៤ ឆ្នាំ២០២៥
ភាពយន្ត ១៥១ រឿង - បច្ចេកវិទ្យា VR -
ទស្សនិកជនជាង ១៦,០០០ នាក់
ជំរុញកម្ពុជាជាគោលដៅភាពយន្តលើឆាកអន្តរជាតិ

លេខ២៨ / ២០២៥
*Number 28 / 2025*

## ក្រុមប្រឹក្សាពិនិត្យនិងសម្រេច

| | | |
|---|---|---|
| លោកជំទាវបណ្ឌិតសភាចារ្យ | ភឿង សកុណា | រដ្ឋមន្ត្រី |
| លោកជំទាវ | ឡងឌី សាន់ណារ៉ា | រដ្ឋលេខាធិការ |
| ឯកឧត្តម | អ៊ុន ទឹម | អនុរដ្ឋលេខាធិការ |
| ឯកឧត្តមបណ្ឌិត | គឹម ពីនន់ | អនុរដ្ឋលេខាធិការ |
| ឯកឧត្តម | ឈុំ ម៉េងហុង | អគ្គនាយកបច្ចេកទេសវប្បធម៌ |
| ឯកឧត្តម | វិន ឡៃជួ | អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ |
| ឯកឧត្តម | អ៊ុក សុខា | អគ្គនាយកបេតិកភណ្ឌ |

## និពន្ធនាយក

លោក កុក រស់

## និពន្ធនាយករង

លោក ហ៊ិន ចាន់ណារ៉ា

## រចនាទំព័រ

លោកស្រី ញឹក ថាវី
លោក ឡេង ពុទ្ធី

## ប្រមូលឯកសារនិងចងក្រងដោយ

នាយកដ្ឋានសៀវភៅនិងការអាន
នៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌

## រក្សាសិទ្ធិ

©ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

អាសយដ្ឋាន៖
អគារលេខ៤៨, ផ្លូវ២១៨, សង្កាត់បឹងរាំង, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ

# មាតិកានុក្រម


- កំណាត់ស្ដីពីការបោះពុម្ព ........ ក


## ជំពូកទី១៖ អត្ថបទស្រាវជ្រាវ


- ចេតិយវត្តសាលាម្នាង ខេត្តកោះកុង ........ ២
- តម្បាញកន្ទេលផ្ដៅ ខេត្តសៀមរាប ........ ១៤
- សិប្បកម្មចម្លាក់ស្លាន់, ស្មិត, តម្បាញដោយដៃអំពីជាងត្នោត,វល្លិ៍ ផ្ដៅ(អំពីរុក្ខជាតិ), ក្អម ថ្នាំង(អំពីដីដុត) ខេត្តកំពង់ស្ពឺ ........ ២៣


## ជំពូកទី២៖ របាយការណ៍, គម្រោងការ


- ការរៀបចំខ្សែទស្សនាចរភ្ញៀវទេសចរតំបន់អង្គរ( សៀមរាប) ........ ៣៨
- របាយការណ៍សង្ខេបស្ដីពីកិច្ចគាំពារបេតិកភណ្ឌរូបីនិងអរូបីរបស់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកណ្ដាល ........ ៥៣


## ជំពូកទី៣៖ សកម្មភាព, ព្រឹត្តិការណ៍


- ព្រឹត្តិការណ៍មហោស្រពចាប៉ីដងវែងទូទាំងប្រទេសឆ្នាំ២០២៥ ........ ៦៤
- ជោគជ័យដ៏ត្រចះត្រចង់នៃ មហោស្រពល្ខោនយីកេឆ្នាំ២០២៥ ក្រោមប្រធានបទ “គុណធម៌និងកតញ្ញូ” ........ ៦៦
- ពិធីបើកឆ្នាំទេសចរណ៍កម្ពុជា-ចិនឆ្នាំ២០២៥ ........ ៦៨
- ការសម្ដែងសិល្បៈក្នុងពិធីបើកនិងបិទពិព័រណ៍កម្ពុជា នៅប្រទេសជប៉ុនលើកទី៩ ឆ្នាំ២០២៥ ........ ៦៩
- ព្រឹត្តិការណ៍បុណ្យទន្លេលើកទី៩ ឆ្នាំ២០២៥ នៅខេត្តតាកែវ ........ ៧០
- ការសម្ដែងល្ខោនបាមោជ្ជទ័យ រឿងកុលាបប៉ៃលិន នៅសាលសន្និសីទចតុម្មុខ ........ ៧១
- ពិធីសម្ពោធពិព័រណ៍ “ស្នាដៃមរតកមនុស្សរស់” ........ ៧២
- ពិធីសម្ពោធពិព័រណ៍រូបថតក្រោមប្រធានបទ៖“រួមគ្នាលើកតម្កើងមរតកវប្បធម៌អរូបី” ........ ៧៤
- សិល្បៈចាក់ចេក៖ មរតកវប្បធម៌ដ៏រស់រវើក ........ ៧៦
- មហោស្រពភាពយន្តអន្តរជាតិកម្ពុជាលើកទី១៤ ឆ្នាំ២០២៥ ........ ៧៨
- វគ្គបណ្ដុះបណ្ដាលភាពយន្តខ្លីកម្ពុជា ជំនាន់ទី៨ ឆ្នាំ២០២៥ ........ ៨៣
- ការរួមចំណែកលើកស្ទួយការតែងនិពន្ធ ការបោះពុម្ព និងការអាននៅកម្ពុជា ........ ៨៩


## ជំពូកទី៤៖ អក្សរសិល្ប៍, កម្សាន្ត


- ប្រលោមលោកខ្នាតខ្លី :“ដើមពុទ្រាឧត្តមា” ........ ៩៤

# កំណត់ស្ដីពីការបោះពុម្ព

ចាប់តាំងពីឆ្នាំ២០០៩ នាយកដ្ឋានសៀវភៅ និងការអាននៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានខិតខំប្រមូលចងក្រងហើយបោះពុម្ពផ្សាយសៀវភៅឈ្មោះថា «ទស្សនាវដ្ដីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ» ក្នុងគោលបំណងអប់រំ និងផ្សព្វផ្សាយចំណេះដឹងផ្នែកសិល្បៈ និងវប្បធម៌ដល់មហាជនទូទៅ។ ទស្សនាវដ្ដីនេះ បានអាក់ខានការផ្សាយរបស់ខ្លួនចំនួនពីរឆ្នាំ គឺក្នុងឆ្នាំ២០១៣-១៤ ដោយបញ្ហាកង្វះខាតថវិកាទ្រទ្រង់។ ឆ្នាំ២០១៥ ទស្សនាវដ្ដីនេះចាប់ផ្ដើមដំណើរការផ្សាយ ឡើងវិញដោយបានកែលម្អទាំងសោភណភាព, គុណភាពនិងខ្លឹមសារ។ ទស្សនាវដ្ដីនេះចេញផ្សាយ ១ឆ្នាំម្ដង ពោល គឺនៅរៀងរាល់ចុងឆ្នាំ។ ទស្សនាវដ្ដីនេះ បែងចែកជា៤ជំពូក ជំពូកទាំង៤នោះ គឺ៖

## ជំពូកទី១៖ អត្ថបទស្រាវជ្រាវ

ជំពូកនេះចុះផ្សាយអំពីអត្ថបទសិក្សាស្រាវជ្រាវផ្សេងៗទាក់ទងនឹងសិល្បៈ វប្បធម៌មានដូចជា៖ អក្សរសាស្ត្រ, ប្រវត្តិសាស្ត្រ,ស្ថាបត្យកម្ម, គំនូរ, ចម្លាក់, ភ្លេង, របាំ, ជំនឿ,ទំនៀមទម្លាប់,របរចិញ្ចឹមជីវិត, ឧបករណ៍ ប្រពៃណី, ភូមិសាស្ត្រ និងជម្មជាតិ។ល។ ជំពូកនេះ អាចចុះផ្សាយអត្ថបទមួយឬពីរទៅតាមអត្ថបទវែងឬខ្លី។ ជំពូកនេះក៏អាចលើកយកអត្ថបទស្រាវជ្រាវភាសាបរទេសដែលមានខ្លឹមសារល្អៗមកបកប្រែដើម្បីផ្សព្វផ្សាយដែរ ប្រសិនបើយើងយល់ថាអត្ថបទនោះមានសារៈសំខាន់ដល់ប្រជាពលរដ្ឋខ្មែរ (ក្នុងករណីដែលទទួលបានសិទ្ធិក្នុងការបកប្រែ)។

## ជំពូកទី២៖ របាយការណ៍, គម្រោងការ

ផ្នែកនេះចុះផ្សាយរបាយការណ៍នៃពិធីផ្សេងៗដែលក្រសួងរៀបចំរួមមាន៖ កិច្ចប្រជុំរបស់ថ្នាក់ដឹកនាំ, សន្និបាតបូកសរុបការងារវប្បធម៌, សិក្ខាសាលា, វគ្គបណ្ដុះបណ្ដាល, ផែនការសកម្មភាពការងាររបស់ក្រសួង។ល។ កិច្ចសហប្រតិបត្តិការទាំងក្នុងស្រុក និងក្រៅស្រុក។

## ជំពូកទី៣៖ សកម្មភាព, ព្រឹត្តិការណ៍

ជំពូកនេះរៀបរាប់អំពីសកម្មភាពការងាររបស់ក្រសួងនិងមន្ទីរដែលបានប្រារព្ធ និងអនុវត្តដូចជាទិវាវប្បធម៌ជាតិ, ការសម្ដែងសិល្បៈ,ពិព័រណ៍,

កំណាយស្រាវជ្រាវ, កិច្ចការអភិរក្ស និងគាំពារ (ប្រាសាទ, វត្ត, ចម្លាក់, គំនូរ, រមណីយដ្ឋានទេសចរណ៍,ធម្មជាតិ,វប្បធម៌, ភ្លេង, របាំជាដើម)។

## ជំពូកទី៤៖ អក្សរសិល្ប៍, គម្ពរាជ

ជំពូកនេះនិយាយអំពីរឿងរ៉ាវផ្សេងៗ ពិសេសរឿងទាក់ទងនឹងសាសនា មានរាមកេរ្តិ៍ ជាតកនិងសាស្ត្រាល្បែងជាដើម។ ក្រៅពីនេះក៏មានដកស្រង់យកកំណាព្យល្បីៗ និងច្បាប់ (ឧទាហរណ៍ ច្បាប់ស្រី ច្បាប់ប្រុស) មកចុះផ្សាយផងដែរ។ ការចុះផ្សាយឡើងវិញនូវរឿងនិងកំណាព្យដូចដែលបានពោលមកនេះ ដើម្បីជាការរំឭកគុណដល់អ្នកនិពន្ធនិងកវីល្បីៗ ដែលបានបន្សល់ស្នាដៃឆ្នើមទាំងនោះ។ ម្យ៉ាងវិញទៀតការផ្សព្វផ្សាយនេះក៏ជាឱកាសដើម្បីឱ្យក្មេងជំនាន់ក្រោយបានស្គាល់នូវស្នាដៃរបស់លោកផង ហើយក៏ជាគតិសម្រាប់ការអប់រំនិងទូន្មានផង។ ស្នាដៃនិពន្ធជំនាន់ថ្មីទាំងប្រលោមលោកនិងកំណាព្យដែលមានខ្លឹមសារល្អបម្រើ ដល់វិស័យអប់រំ និងមានប្រយោជន៍ដល់សង្គមក៏នឹងលើកយកមកចុះផ្សាយ។ ចំណែករឿងកំប្លែងនិងគំនូរត្លុកបែបអប់រំ ក៏នឹងបង្ហាញនៅក្នុងជំពូកនេះដែរ។

## សេចក្តីអំពាវនាវ

ដើម្បីឱ្យ «ទស្សនាវដ្តីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ» មានអត្ថបទចុះផ្សាយកាន់តែសម្បូណ៌បែប ពោលគឺមានលាយចម្រុះសិល្បៈវប្បធម៌គ្រប់វិស័យទាំងបុរាណវិទ្យា, ស្ថាបត្យកម្ម, សូនរូប, ភ្លេង, នាដសាស្ត្រ, ទំនៀមទម្លាប់ប្រពៃណី, សាសនាជាដើម នាយកដ្ឋានសៀវភៅនិងការអានសូមអំពាវនាវដល់សាស្ត្រាចារ្យ, និស្សិត, អ្នកស្រាវជ្រាវ, អ្នកជំនាញ, មន្ត្រីរាជការ ទោះស្ថិតក្នុង ឬនៅក្រៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈក្តី មេត្តាចូលរួម ផ្តល់ជាអត្ថបទឬជារបាយការណ៍ស្តីពីវប្បធម៌អប់រំឬសិក្សាស្រាវជ្រាវផ្សេងៗដើម្បីចុះផ្សាយតាមការគួរ៕

# ជំពូកទី១

# អត្ថបទស្រាវជ្រាវ



# ចេតិយវត្តសាលាម្នាង ខេត្តកោះកុង

ស្រាវជ្រាវដោយៈ **ខុន មូផា**
មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកោះកុង







## សេចក្ដីផ្ដើម

នៅក្នុងប្រទេសកម្ពុជា បើនិយាយពីសំណង់បុរាណ ឬសំណង់បេតិកភណ្ឌ គឺមានច្រើននៅតាមបណ្ដាខេត្តនានា ពិសេសខេត្ត សៀមរាប បាត់ដំបង បន្ទាយមានជ័យ ព្រះវិហារ កំពង់ធំ ។ល។ ដោយឡែកខេត្តកោះកុង ជាខេត្តមួយដាច់ស្រយាលនាទិសនិរតីនៃប្រទេសកម្ពុជា ស្ថិតនៅតំបន់ជាប់មាត់សមុទ្រ និងព្រៃភ្នំពុំសម្បូរសំណង់បុរាណឬប្រាសាទបុរាណដូចជាខេត្តដទៃឡើយ។ ជាក់ស្ដែង សំណង់បុរាណដែលមាននៅក្នុងខេត្ត មានចេតិយឃុនឲាង ព្រះរាជដំណាក់ ឬផ្ទះក្រហម ស្ថិតនៅជាប់ដែសមុទ្រកោះប៉ោ ចេតិយបុរាណនៅឃុំអណ្ដូងទឹក ចេតិយបុរាណវត្តសាលាម្នាង និងគ្រឹះប្រាសាទថ្មបាយក្រៀម ស្ថិតក្នុងវត្តអង្គរភ្នំខ្ពង់ ស្រុកស្រែអំបិល។ បើតាមការរៀបរាប់ខាងលើនេះ ឃើញថាសំណង់បុរាណមានចំនួនតិចតួចប៉ុណ្ណោះ បើប្រៀបធៀបជាមួយខេត្តផ្សេងៗ ក្នុងប្រទេសកម្ពុជា។ ដោយមើលឃើញថាសំណង់បុរាណក្នុងខេត្តទាំងនេះនៅពុំទាន់មានការចងក្រងឯកសារច្បាស់លាស់នៅឡើយ មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកោះកុង បានជំរុញឱ្យមន្ត្រីជំនាញចុះសិក្សារៀបចំចងក្រងជាឯកសារដើម្បីរក្សាទុក ព្រោះបារម្ភថាការចងចាំរបស់អ្នកស្រុក ពិសេសចាស់ៗ ពីមួយជំនាន់ទៅមួយជំនាន់អាចមានការប្រែប្រួល ឬភ្លេចប្រវត្តិនៃការកសាងសំណង់ទាំងនោះ ដែលនាំឱ្យមានការបាត់បង់ប្រវត្តិដើមរបស់សំណង់នាថ្ងៃអនាគត។ មូលហេតុដូចបានជម្រាបជូន នាំឱ្យមានការចុះស្រាវជ្រាវនិងចងក្រងប្រវត្តិចេតិយបុរាណវត្ត

សាលាម្នាង ដែលខាងក្រោមនេះ នឹងបង្ហាញពីប្រវត្តិនៃការកសាង ទីតាំងភូមិសាស្ត្រ ជំនឿផ្សេងៗ ក៏ដូចជាការរស់នៅរបស់អ្នកស្រុកដែលរស់នៅជុំវិញតំបន់នោះផ្ទាល់។

## ១-ទីតាំងភូមិសាស្ត្រ

ចេតិយវត្តសាលាម្នាង ស្ថិតនៅក្នុងវត្តសាលាម្នាង ភូមិសាលាម្នាង ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ដែលពីមុនទីតាំងនេះស្ថិតនៅក្នុងស្រុកមួយរបស់ខេត្តកំពត។ បច្ចុប្បន្ននេះ វត្តសាលាម្នាង មានពុទ្ធបរិស័ទចំណុះជើងវត្តចំនួន ១៥ភូមិ។ បើតាមការសាកសួរលោកតា ឌុច សារុទ្ធ អាយុ៧១ឆ្នាំ អតីតព្រះសង្ឃធ្លាប់បួសរៀននៅក្នុងវត្តសាលាម្នាង បានឱ្យដឹងថា វត្តសាលាម្នាងមានផ្ទៃដីសរុបប្រហែល ៥ហិកតា រីឯទំហំដីវត្តជាក់ស្តែងនៅពុំទាន់មានការវាស់វែងនៅឡើយទេ។ វត្តនេះស្ថិតនៅលើទីទួល ជាប់ផ្លូវជាតិលេខ ៤៨ មានចម្ងាយប្រហែល ៣គីឡូម៉ែត្រ ពីដែសមុទ្រ ឬព្រែកចុងថ្នល់ ស្រុកស្រែអំបិល។ ចំណែកទីតាំងវត្តសាលាម្នាងមានចម្ងាយប្រហែល១៤០គីឡូម៉ែត្រពីទីរួមខេត្តកោះកុង។ ប្រសិនបើយើងធ្វើដំណើរតាមផ្លូវជាតិលេខ៤ បត់ចូលមកផ្លូវជាតិលេខ៤៨ ចេញដំណើរពីផ្លូវបំបែកស្រែអំបិលប្រហែល៨គីឡូម៉ែត្រ យើងនឹងឃើញវត្តនេះនៅខាងស្តាំដៃ (រូបទី១, រូបទី២)។ ពីមុនវត្តសាលាម្នាង មានមួយផ្នែក ស្ថិតនៅខាងក្រោមផ្លូវជាតិលេខ៤៨ ដោយកុដនៅផ្នែកខាងក្រោមផ្លូវជាតិ ហើយព្រះវិហារនៅផ្នែកខាងលើផ្លូវជាតិ( ផ្លូវជាតិកាត់ដីវត្ត) តែក្រោយពីការសាងសង់ផ្លូវជាតិលេខ៤៨ ជាផ្លូវកៅស៊ូមក វត្តត្រូវបានរើមកផ្នែកខាងលើផ្លូវជាតិទាំងស្រុង ។ សូមរំលឹកដែរថា ផ្លូវជាតិលេខ៤៨ ដែលតភ្ជាប់ពីផ្លូវជាតិលេខ៤ ទៅកាន់ទីរួមខេត្តកោះកុង បានសាងសង់ដំបូងក្នុងឆ្នាំ១៩៦៦ ជាផ្លូវគ្រួសក្រហម។ ក្រោយមក នៅឆ្នាំ២០០៣ បានសាងសង់ និងជួសជុលពង្រីកផ្លូវនេះបន្ថែម ចំណាយពេលសាងសង់រយៈពេល៣ឆ្នាំ ពីឆ្នាំ២០០៣ ដល់ ឆ្នាំ២០០៥។ ក្រោយពីសាងសង់ពង្រីកផ្លូវគ្រួសក្រហមរួចរាល់នៅ ឆ្នាំ២០០៥ ក៏បន្តសាងសង់ជាផ្លូវក្រាលកៅស៊ូ សាងសង់រួចរាល់នៅឆ្នាំ២០០៧ ( ប្រសាសន៍លោកតា ឌុច សារុទ្ធ អាយុ៧១ឆ្នាំ នៅភូមិសាលាម្នាង ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង )។







រូបទី១: ផែនទីវត្តសាលាម្នាង







*រូបទី២: ខ្លោងទ្វារផ្លូវចូលវត្តសាលាម្នាង*

## ២_ប្រវត្តិចេតិយបុរាណ

វត្តសាលាម្នាងជាវត្តមានវ័យចំណាស់មួយនៅក្នុងចំណោមវត្តជាច្រើន ដែលមាននៅក្នុងខេត្តកោះកុង។គិតត្រឹមឆ្នាំ២០២២ ខេត្តកោះកុង មានវត្តសរុបចំនួន៥៤ ក្នុងនោះមានវត្តមហានិកាយ ៤៧វត្ត និងវត្តធម្មយុត្តិមានចំនួន៧វត្ត។ វត្តសាលាម្នាងជាវត្តមហានិកាយ បានកសាងឡើងនៅទសវត្សឆ្នាំ១៤៧០( តាមស្ថិតិវត្តនៅក្នុងខេត្តកោះកុងចងក្រងដោយ មន្ទីរធម្មការនិងសាសនាខេត្ត)។ បើតាមសង្ឃដីការព្រះគ្រូចៅអធិការវត្តបច្ចុប្បន្ន ក៏ដូចជាចាស់ៗចំណុះជើងវត្តបានឱ្យដឹងថា ពីមុននៅក្នុងវត្តនេះមានចេតិយចំណាស់ជាងគេចំនួន ៤ ដែលបាន កសាងឡើង ក្នុងសម័យកាលតែមួយតែអាយុកាលផ្សេងៗគ្នា។ មកដល់បច្ចុប្បន្ននេះ ក្នុងចំណោមចេតិយទាំង៤ មានចេតិយ ចំនួន១ បានរលំបាត់រូបរាង ហើយគ្រឹះដែលនៅសល់ត្រូវបានសាច់ញាតិ ជំនាន់ក្រោយកសាងចេតិយថ្មីនៅលើគ្រឹះចាស់។ ចេតិយបុរាណដែលនៅសល់មានចំនួន៣ គឺទី១ ចេតិយលោកតាសំ មានអាយុកាលចាស់ជាងគេ កសាងសម្រាប់ដាក់តម្កល់អដ្ឋិធាតុអតីតព្រះគ្រូចៅអធិការវត្ត និងជាព្រះអនុគណខេត្ត ព្រះនាមថា លោកតាសំ ប្រហែលជាបានកសាងឡើងនៅចុងស.វ.ទី១៧ នៃគ.ស.។ ក្រោយមកក៏មានការកសាងបន្ថែមនូវចេតិយបន្តបន្ទាប់ ដែលចេតិយទី២ ជារបស់លោកតាឌួង ជាអតីតព្រះចៅអធិការវត្ត និងជាព្រះអនុគណខេត្ត ប្រហែលជាកសាងឡើងនៅស.វ.ទី១៨ នៃ គ.ស.។ ចេតិយទី៣ កសាងសម្រាប់ដាក់តម្កល់អដ្ឋិធាតុអតីតព្រះគ្រូចៅអធិការវត្ត និងជាអនុគណខេត្ត ព្រះនាមលោកតាកង ឡុង កសាងនៅស.វ.ទី១៩។ បច្ចុប្បន្ននេះ ចេតិយទាំងបី មានសភាពចាស់សឹករេចរិល បាក់បែកផ្នែកខ្លះ និងមានការជួសជុលបន្ថែមផ្នែកខ្លះ ដើម្បីជាសោភណ្ឌភាព និងដើម្បី ការពារស្ថានភាពចេតិយកុំឱ្យដួលរលំ។

### ក_ចេតិយតាសំ

ចេតិយលោកតាសំ កសាងឡើងដើម្បីដាក់តម្កល់អដ្ឋិធាតុអតីតព្រះគ្រូចៅអធិការវត្តព្រះនាម

លោកតាសំ មានទំហំ ៩ ម៉ែត្រ x ៩ ម៉ែត្រ និងកម្ពស់ប្រហែល៩.៩ម៉ែត្រស្ថិតនៅខាងជើងឆៀងខាងកើតព្រះវិហារ សាងសង់ពីឥដ្ឋ និងស៊ីម៉ងត៍ សង់លើដីរាបស្មើ មានរាងបួនជ្រុង នៅផ្នែកខឿនខាងក្រោម មានរាងមូលនៅផ្នែក កណ្តាល និងកំពូលរាងមូលថ្នាក់ៗ។ ស្ថានភាពចេតិយ មានសភាពសឹករេចរឹលស្ទែកាន់ខ្លាំង បាក់បែកផ្នែកខ្លះនៃតួចេតិយទាំងមូល និងស្ថានភាពសំណង់ ស្ថិតក្នុងគុណភាពមធ្យម (រូបទី៣)។ បើតាមការសាកសួរពីព្រះគ្រូចៅអធិការវត្តនិងចាស់ៗចំណុះជើងវត្ត ក៏ដូចជាតាមការពិនិត្យលើរចនាបថ និងស្ថានភាពសំណង់ចេតិយនេះ ប្រហែលជាកសាងនៅចុង ស.ទី១៧ នៃគ.ស.ឬដើមស.វ.ទី១៨ នៃគ.ស.។



រូបទី៣: ចេតិយលោកតាសំ

### ខ-ចេតិយតាឌួង

ចេតិយលោកតាឌួង កសាងឡើងដើម្បីដាក់តម្កល់អដ្ឋិធាតុអតីតព្រះគ្រូចៅអធិការវត្ត ព្រះនាមលោកតាឌួង មានទំហំ ២.៧០ ម៉ែត្រ x ២.៧០ ម៉ែត្រ និងកម្ពស់ប្រហែល ១១ ម៉ែត្រ ស្ថិតនៅខាងជើងព្រះវិហារ សាងសង់ពីឥដ្ឋ និងស៊ីម៉ងត៍ សង់លើដីរាបស្មើ មានរាងបួនជ្រុង កំពូលស្រួច តួចេតិយចែកចេញជាបីផ្នែក គឺផ្នែកខឿន ផ្នែកកណ្តាល និងកំពូល។ ស្ថានភាពចេតិយទ្រេតផ្អៀង មានសភាពសឹករេចរិល និងបាក់បែកផ្នែកខ្លះនៃតួចេតិយទាំងមូលស្ទើកាន់ សំណង់ស្ថិតក្នុងគុណភាពមធ្យម។ នៅផ្នែកខឿន(គ្រឹះ) នៃចេតិយ មានរៀបខឿនស៊ីម៉ងត៍ថ្មីដើម្បីទប់ទ្រតួចេតិយជៀសវាងកុំឱ្យដួលរលំ (រូបទី៤)។ បើតាមការសាកសួរពីព្រះគ្រូចៅអធិការវត្តនិងចាស់ៗចំណុះជើងវត្ត ចេតិយតាដួង សាងសង់ក្រោយចេតិយតាសំ ដូច្នេះអាយុកាលចេតិយនេះប្រហែលជាបានកសាងនៅ ស.វ.ទី១៨ នៃគ.ស.។









រូបទី៤: ចេតិយលោកតាឌួង

### គ_ចេតិយតាឡុង

ចេតិយលោកតាឡុង កសាងឡើងដើម្បីដាក់តម្កល់អដ្ឋិធាតុអតីតព្រះគ្រូចៅអធិការវត្តព្រះនាម លោកតា កង ឡុង មានទំហំ ២.៧ ម៉ែត្រ x ២.៧ ម៉ែត្រ និងកម្ពស់ប្រហែល ៥.៥ម៉ែត្រ ស្ថិតនៅខាងត្បូងឆៀងខាងកើតព្រះវិហារ សាងសង់ពីឥដ្ឋនិងស៊ីម៉ងត៍ សង់លើខឿនរាងមូល មានបង្កាន់ដៃព័ទ្ធជុំវិញ ចេតិយរាងមូល នៅផ្នែក៣/៤នៃតួចេតិយមានរូបទេពប្រណម្យតំណាងទិសទាំងបួន និងក្បាច់ភ្ញីផ្កា( ការលម្អទាំងនេះទើបសាងសង់ថ្មីបន្ថែម) ព្រហ្មមុខបួននិងមានកំពូលរាងមូលស្រួចជាថ្នាក់ៗ (រាងដូចដួងផ្កាប់)។ ស្ថានភាពចេតិយ មានសភាពសឹករេចរឹល ស្លែកាន់ ស្ថានភាពសំណង់ស្ថិតក្នុងគុណភាពមធ្យម (រូបទី៥)។ បើយោងទៅលើលេខចារឹកក្នុងចេតិយ បានបង្ហាញថាចេតិយនេះកសាងឡើងនៅ ព.ស.២៤៨២ ត្រូវនឹងឆ្នាំ ១៩៣៨ ឬ ស.វ.ទី១៩ នៃគ.ស.។









រូបទី៥: ចេតិយលោកតាឡុង

### ឃ_ចេតិយបុរាណដែលបាត់បង់

ទីតាំងគ្រឹះចេតិយដែលបានដួលរលំបាត់រូបរាង ក្រោយមកមានការសាងសង់ចេតិយថ្មីពីលើស្ថិតនៅចន្លោះកណ្ដាលរវាងចេតិយតាសំ និងចេតិយតាឱ្ធង។ ដោយសារស្ថានភាពគ្រឹះសំណង់ទ្រុឌទ្រោម និងកត្តាធម្មជាតិ ធ្វើឱ្យចេតិយនេះបានដួលរលំ (រូបទី៦)។ ក្រោយចេតិយដ៏បុរាណនេះដួលរលំ

ទៅ សាច់ញាតិជំនាន់ក្រោយបានសាងសង់ចេតិយថ្មីលើគ្រឹះចេតិយចាស់(រូបទី៧)។ អាយុកាលចេតិយដែលរលំបាត់រូបរាង អាចស្ថិតក្នុងសម័យកាលជាមួយគ្នានឹងចេតិយតាសំ និងតាឌួងដែរ គឺចុងស.វ.ទី១៧ ឬ១៨ នៃ គ.ស.។











រូបទី៦: ស្ថានភាពចេតិយពេលមិនទាន់រលំ( ឆ្នាំ២០១៤)







*រូបទី៧: ចេតិយថ្មីសង់លើគ្រឹះចេតិយចាស់*

### ង.រឿងព្រេង

ប្រវត្តិវត្តសាលាម្នាង កើតឡើងដោយរឿងនិទានតៗគ្នា ចំនួន ២រឿង។ រឿងទី១ និទានឱ្យដឹងពីព្រះគ្រូចៅអធិការវត្តបច្ចុប្បន្ន ព្រះនាម សែកួង សុខលីម ដែលព្រះអង្គបានដឹងរឿងនេះតាមរយៈការនិទានតពីបុរសម្នាក់មកពីខេត្តសៀមរាបធ្លាប់មកស្នាក់នៅវត្តនេះ។ ចំណែកឯរឿងទី២ គឺស្រង់ចេញពីសៀវភៅពិធីបុណ្យបញ្ចុះខណ្ឌសីមាពុទ្ធាភិសេក និងសម្ពោធសមិទ្ធផលនានាវត្តសាលាម្នាង ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ដែលចងក្រងនៅឆ្នាំ២០០០។

**រឿងទី១** បានដំណាលថា នៅសម័យស្តេចស្រីសូរិយោពណ៌ ទ្រង់បាននាំស្រីស្នំ ម្នំម្នាង មកក្រសាលព្រៃនៅទីតាំងវត្តសាលាម្នាងនេះ ជិតកន្លែងទឹកធ្លាក់ ជាប់នឹងឆ្នេរសមុទ្រ ដោយកាលនោះពុំទាន់មានវត្តនៅទីតាំងនេះនៅឡើយទេ ហើយទីតាំងនេះក៏ពុំមានឈ្មោះដូចសព្វថ្ងៃដែរ។ ពេលស្តេចគង់នៅទីនេះ ទ្រង់បានឱ្យគេកសាងសាលាសំណាក់អំពីឈើ សម្រាប់ឱ្យស្រីស្នំទាំងនោះស្នាក់នៅ ហៅថាសាលាសំណាក់ម្នំម្នាង។ បន្ទាប់មកទីតាំងនេះគេបានហៅឈ្មោះថាសាលាឆទានម្នំម្នាង និងក្រោយមកទៀតក៏មានការកសាងវត្តនៅទីតាំងនេះ ហើយក៏ជាប់ឈ្មោះថាវត្តសាលាម្នាង រហូតមកដល់បច្ចុប្បន្ន។ (សង្ឃដីការព្រះគ្រូចៅអធិការវត្តព្រះនាម សែកួង សុខលីម)

**រឿងទី២** បាននិទានថា កាលដើមឡើយទីតាំងវត្តសាលាម្នាងនេះ នៅជាប់ឆ្នេរសមុទ្រ ឆ្ងាយដាច់ស្រយាលពីទីប្រជុំជន ដាច់ស្រយាលពីអ្នកស្រែចម្ការដែលជាពុទ្ធបរិស័ទ រីឯទីធ្លាក៏ពុំរាបស្មើដែរ។ នៅឆ្នាំ១៤៧០ នៃគ.ស.មានស្តេចមួយអង្គ ព្រះនាម មេនមមេនាង បានយាងមកលំហែព្រះកាយតាមតំបន់ឆ្នេរសមុទ្រ បានឃើញទីតាំងនេះនៅឆ្ងាយពីពុទ្ធបរិស័ទ ដែលគោរពព្រះពុទ្ធសាសនា ពិសេសក្នុងការបំពេញកុសល និងធ្វើបុណ្យទានម្តងម្កាល។ ដោយឈ្វេងយល់យ៉ាងនេះទើបស្តេច ព្រះអង្គមានទឹកព្រះទ័យសទ្ធាជ្រះថ្លាកសាងសាលាឆទានមួយខ្នង ដើម្បីបានស្ថិតនៅជិតពុទ្ធបរិស័ទរួចព្រះអង្គបានចារឹកឈ្មោះថា សាលាព្រះមេនាង តែក្រោយ

មកក៏ប្រែទៅជា វត្តសាលាម្នាង រហូតដល់សព្វថ្ងៃ។ ក្រោយពីសាងសង់រួច ព្រះអង្គបានទៅនិមន្តព្រះសង្ឃ ពីវត្តព្រៃរមៀត ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ មកគង់នៅទីនេះ ដើម្បីឱ្យពុទ្ធបរិស័ទបានធ្វើបុណ្យទានម្តងម្កាលនៅថ្ងៃឧបោសថសីល។ នៅជំនាន់ឆ្នាំ ១៩៧៥-១៩៧៩ វត្តនេះត្រូវបានបំផ្លាញចោលស្ទើរទាំងស្រុង។ នៅឆ្នាំ១៩៨៣ មានការកសាងព្រះវិហារតូចល្មមសម្រាប់ធ្វើបុណ្យទានផ្សេងៗ លុះដល់ឆ្នាំ១៩៩៦ ដោយមានសទ្ធាជ្រះថ្លា លោកឧកញ៉ា កុក អាន និងលោកជំទាវ ឡាវ អាយប៊ួយ រួមទាំងព្រះសង្ឃ គណៈកម្មការអាចារ្យវត្ត និងពុទ្ធបរិស័ទជិតឆ្ងាយកសាងព្រះវិហារធ្វើពីបេតុងអារម៉េ ដំបូលប្រក់ក្បឿង ដែលមានបណ្តោយប្រវែង ២២ ម៉ែត្រ ទទឹង ១២ ម៉ែត្រ សង់រួចរាល់នៅឆ្នាំ១៩៩៩។(ដកស្រង់ពីពិធីបុណ្យបញ្ចុះខណ្ឌសីមាពុទ្ធាភិសេក និងសម្ពោធសមិទ្ធផលនានាវត្តសាលាម្នាង ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ឆ្នាំ២០០០)។

បើតាមមើលសាច់រឿងទាំងពីរខាងលើ ឃើញថា ប្រវត្តិដែលនាំឱ្យកើតមានការកសាងវត្តសាលាម្នាងនៅទីតាំងនេះ គឺដោយសារព្រះរាជាខ្មែរសម័យកណ្តាល ព្រះអង្គមកលំហែព្រះកាយនៅតំបន់នេះ ហើយក៏ជាដើមហេតុនាំឱ្យមានសំណង់សម្រាប់ធ្វើទីសក្ការៈបូជា រហូតកកើតជាវត្តអារាមនេះឡើង។

## ៣–ជំនឿ និងការរស់នៅរបស់អ្នកស្រុក

ស្រុកស្រែអំបិលជាស្រុកមួយមានវ័យចំណាស់នៅក្នុងខេត្តកោះកុង មានប្រពៃណីទំនៀមទម្លាប់មួយចំនួនពិសេស ដូចជាការចូលម្ធប់ (រូបទី៨) លៀងមេមត់ ឬលៀងគ្រូ នៅតែបន្តអនុវត្តមកដល់បច្ចុប្បន្ននេះ។ អ្នកស្រុកនៅតំបន់នេះ ក៏មានទំនៀមទម្លាប់ធ្វើនំម្យ៉ាងដែលប្លែកពីស្រុកដទៃ គឺនំល្វើផោម (រូបទី៩) ដែលជានំប្រចាំតំបន់ និងមានប្រវត្តិក្នុងការធ្វើយូរយារណាស់មកហើយ។ សម្រាប់ម្ហូបប្រចាំតំបន់របស់អ្នកស្រុកស្រែអំបិល គឺស្ងោរគី ដោយសារប្រជាជននៅតំបន់នេះនៅជាប់នឹងដែនសមុទ្រ ហេតុនេះការធ្វើម្ហូបអាហាររបស់អ្នកស្រុកគឺមានរបៀបរបបបែបអ្នកសមុទ្រ។ អ្វីដែលពិសេសមួយទៀត នៅក្នុងស្រុកនេះក៏មានគ្រឹះប្រាសាទបុរាណធ្វើអំពីថ្មបាយក្រៀម ដែលកសាងឡើងនៅសតវត្សទី១១ នៃគ.ស. ស្ថិតក្នុងសម័យអង្គរ មានទីតាំងនៅក្នុង បរិវេណវត្តអង្គរភ្នំខ្លុង ស្ថិតនៅភូមិខ្លុង ឃុំស្រែអំបិល ស្រុកស្រែអំបិល។ ក្រៅពីសំណង់បេតិកភណ្ឌសម័យអង្គរ ស្រុកស្រែអំបិលក៏មានសំណង់ចេតិយបុរាណសម័យកណ្តាល ស្ថិតក្នុង





រូបទី៨: ពិធីចូលម្ធប់ និងចេញម្ធប់
នៅភូមិត្រពាំង ឃុំស្រែអំបិល ស្រុកស្រែអំបិល

ទីតាំងវត្តសាលាម្នាងនេះឯង។ តាមប្រសាសន៍លោកយាយ តែ តាំងកួយ អាយុ៩២ឆ្នាំ (រូបទី១០) លោកយាយធ្លាប់បានធ្វើពិធីកោរជុក នៅអាយុ១១ឆ្នាំ និងបានធ្វើពិធីចូលម្លប់នៅអាយុ១២ឆ្នាំ ដែលមកដល់បច្ចុប្បន្ននេះស្ទើរតែបាត់បង់អស់





រូបទី៩: ការធ្វើនំល្វើផោម
នៅភូមិអន់ធ្លើត ឃុំជីខក្រោម ស្រុកស្រែអំបិល

ទៅហើយ នៅសល់តែតំបន់ខ្លះនៃខេត្តសៀមរាប និងខេត្តកំពង់ចាមប៉ុណ្ណោះ ដែលនៅប្រារព្ធពិធីនេះ។ ភស្តុតាងមួយទៀតបើតាមការបញ្ជាក់ពីអ្នកស្រុកស្រែអំបិល ទីតាំងនេះជាស្រុកដែលមានវប្បធម៌វ័យចំណាស់មួយផងដែរ។ លោកយាយបានឱ្យដឹងថាកាលជំនាន់នោះ ការធ្វើពិធីកោជុក ធ្វើឡើងទាំងក្មេងប្រុស និងក្មេងស្រីនៅមុនពេលពេញវ័យ នេះបញ្ជាក់ថាតំបន់នេះមានប្រពៃណីទំនៀមទម្លាប់ដ៏ចំណាស់ ដែលមកដល់ពេលនេះប្រពៃណីទាំងនោះបាត់បង់ស្ទើរទាំងស្រុងទៅហើយ។



រូបទី១០: កិច្ចសម្ភាសជាមួយ លោកយាយ តែ តាំងកួយ
រស់នៅភូមិសាលាម្នាង ឃុំសាលាម្នាង ស្រុកស្រែអំបិល ខេត្តកោះកុង

ប្រជាជនរស់នៅស្រុកស្រែអំបិល កាលពីសម័យមុន ជឿថាទីតាំងវត្តសាលាម្នាងជាវត្តមួយដែលសក្តិសិទ្ធិប្រចាំតំបន់។ នៅក្នុងវត្តមានជំនឿលើទីតាំងធំៗចំនួន៣ ទី១ គឺព្រះអង្គធំនៅក្នុងព្រះវិហារ (រូបទី១១) ដែលជាកន្លែងសក្តិសិទ្ធិក្នុងការបន់ស្រន់សុំបំណងប្រាថ្នាផ្សេងៗ ពិសេសការធ្វើដំណើរផ្លូវឆ្ងាយៗ ដូចជាបន់សុំទៅនៅក្រៅប្រទេសជាដើម។ កន្លែងទី២ គឺលោកតាគល់ក្រញូង(រូបទី១២) បន់ស្រន់ពេលបាត់របស់ទ្រព្យផ្សេងៗ នឹងរកឃើញវិញ និងកន្លែងទី៣ គឺព្រះអង្គកែវ(រូបទី១៣) សក្តិសិទ្ធសម្រាប់ការបន់ស្រន់សុំទឹកភ្លៀង។ មួយវិញទៀតបើតាមសង្ឃដីកា ព្រះគ្រូចៅអធិការវត្តបច្ចុប្បន្ន

បានឱ្យដឹងថា វត្តសាលាម្នាងពីមុនក៏ជាកន្លែងសម្រាប់ធ្វើពិធីលៀងគ្រូ ឬស្នងបារមី ដោយអ្នកស្រុក និងគណៈកម្មការវត្ត តែងតែរៀបចំធ្វើពិធីលៀងគ្រូ នៅក្នុងបរិវេណវត្ត១ឆ្នាំម្តង តែក្រោយមក នៅសល់ប្រារព្ធធ្វើពី៥ឆ្នាំទៅ១០ឆ្នាំម្តងៗ នៅក្នុងពិធីមានការបូជាសាច់ស្រស់ ឈាមស្រស់ មានមាន់ឆ្អាងរស់ ឈាមជ្រូក ថ្លើមជ្រូកជាដើមៗ ប៉ុន្តែបច្ចុប្បន្ននេះការគោរពជឿលើវត្តសាលាម្នាងហាក់មានសភាពថមថយ ដោយសារគេជឿថាវត្តនេះលែងសក្តិសិទ្ធដូចសម័យមុន ព្រោះតែក្រោយពីសម័យប៉ុលពតគេបានបំផ្លាញទីសក្ការៈសំខាន់ៗ ក្នុងវត្តនេះអស់ៗ មួយវិញទៀត ដោយសារវិទ្យាសាស្ត្រមានភាព



រូបទី១១: ព្រះអង្គធំក្នុងព្រះវិហារ



រូបទី១២: លោកតាគល់ក្រញូង



រូបទី១៣: ព្រះអង្គកែវ





រូបទី១៤: កិច្ចបួងសួងបារមីវត្ត

ជឿនលឿន ពេលឈឺមនុស្សម្នាច្រើនតែទៅរកពេទ្យដើម្បីព្យាបាលៗ ទោះជាយ៉ាងនេះក្តីក៏នៅតែមានប្រជាពលរដ្ឋខ្លះនៅតែបន្តគោរពជឿលើទីតាំងស័ក្តិសិទ្ធក្នុងវត្តនេះដដែល ដោយនៅតែទៅបួងសួងបន់ស្រន់សុំនេះ សុំនោះ ទៅតាមបំណងប្រាថ្នារបស់ខ្លួនៗ បើនិយាយពីពិធីលៀងគ្រូ ឬពិធីបួងសួងវិញ

តាមព្រះគ្រូចៅអធិការវត្ត មានសង្ឃដីកាថា ទោះមិនបានធ្វើពិធីលៀងគ្រូធំដូចពីមុន តែវត្តនៅមានប្រារព្ធធ្វើពិធីបួងសួងប្រចាំឆ្នាំ ក្នុង១ឆ្នាំ ប្រារព្ធធ្វើ២លើក។ លើកទី១ ធ្វើនៅមុនចូលព្រះវស្សាថ្ងៃ១៥រោច ខែជេស្ឋ (រូបទី១៤) និង លើកទី២ ថ្ងៃ១៥កើត ខែកត្តិក ធ្វើនៅយប់ពេញបូរណ៍មីក្នុងពិធីបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក និងសំពះព្រះខែ ។

មុខរបរប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅក្នុងស្រុកស្រែអំបិល តាមការសង្កេតផ្ទាល់ ក៏ដូចជាសាកសួរប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ អ្នកស្រុកប្រកបរបរធ្វើស្រែ ធ្វើចម្ការ នេសាទ លក់ដូរ និងរកអនុផលព្រៃឈើមាន រកវល្លិ៍ រកទឹកឃ្មុំ និងរកជ័រទឹក ជាដើម។ ជាពិសេសមុខរបរដែលជាប្រវត្តិសាស្ត្រនៃឈ្មោះស្រុកមួយនេះ គឺការធ្វើស្រែអំបិល នៅតែបន្តធ្វើដល់បច្ចុប្បន្ននេះ។ ដោយកសិករធ្វើស្រែអំបិលបានបង្ហូរទឹកសមុទ្រចូលស្រែធ្វើជាអំបិល និងទប់ទឹកសាបមិនឱ្យហូរចូលស្រែអំបិលរបស់ពួកគាត់។ ការធ្វើស្រែអំបិលនេះធ្វើបានតែរដូវប្រាំងប៉ុណ្ណោះ។ ស្ថានភាពប្រជាជននៅក្នុងស្រុកស្រែអំបិល មួយចំនួនធំជាអ្នកចំណូលស្រុកថ្មីមកពីខេត្តផ្សេងៗ និងមួយចំនួនទៀតជាម្ចាស់ស្រុកដើម ដែលមានកំណើតដូនតានៅស្រុកនេះផ្ទាល់តែម្ដង។

## សេចក្ដីសន្និដ្ឋាន

វត្តសាលាម្នាង គឺជាវត្តបុរាណមួយ មានវ័យចំណាស់នៅក្នុងខេត្តកោះកុង ដែលបានកសាងឡើងនៅ កំឡុងស.វ.ទី១៥ នៃគ.ស.។ ប្រវត្តិឈ្មោះវត្តមានដំណើរដើមទាក់ទងទៅនឹងរឿងនិទានតៗគ្នាអំពីការមកក្រសាលព្រៃរបស់ស្ដេចស្រីសូរិយោពណ៌ ដែលជាព្រះរាជាមួយអង្គរបស់ខ្មែរនៅសម័យកណ្ដាល បានយាងមកដល់ទីតាំងនេះ ហើយឱ្យគេកសាងសាលាសំណាក់សម្រាប់ស្រីស្នំ បន្ទាប់មកក៏មានការសាងសង់ជាសាលាឆទាន ក្រោយមកទៀតក៏កសាងជាវត្តអារាម មានកុដិធ្វើអំពីឈើ។ នៅចុង ស.វ.ទី១៧ បន្ទាប់ពីព្រះចៅអធិការវត្ត និងជាអនុគណខេត្ត បានសុគតគណៈកម្មការអាចារ្យវត្ត និងពុទ្ធបរិស័ទ បានសាងសង់ចេតិយធ្វើអំពីថ្មដំបូងគេចំនួន១ សម្រាប់ដាក់តម្កល់អដ្ឋិធាតុរបស់ព្រះអង្គដែលមានព្រះនាមថាលោកតាសំ។ បច្ចុប្បន្ននេះ ចេតិយបុរាណនៅវត្តសាលាម្នាងមានចំនួន ៣ ដែលយើងអាចមើលឃើញផ្ទាល់តាមរយៈរចនាបថ្មសំណង់ស្ថាបត្យកម្មបែបបុរាណ និងមានសភាពចាស់ខុសប្លែកពីចេតិយដទៃដែលមាននៅក្នុងវត្ត និងមានចេតិយ ចំនួន១ បានរលំបាត់រូបរាង ហើយត្រូវសាច់ញាតិជំនាន់ក្រោយសាងសង់ចេតិយថ្មីពីលើគ្រឹះចេតិយចាស់ ដែលទើបសង់នៅសម័យបច្ចុប្បន្ន ។

ការសិក្សាទីតាំងប្រវត្តិសាស្ត្រនានានៅក្នុងខេត្តកោះកុង ពិតជាមានសារៈសំខាន់ ព្រោះអាចនាំឱ្យយើងស្វែងយល់បានគ្រប់ជ្រុងជ្រោយ និងជាមូលដ្ឋានមួយច្បាស់លាស់ដើម្បីសន្និដ្ឋានពីប្រវត្តិសាស្ត្ររបស់ខេត្ត ក៏ដូចជាការរស់នៅរបស់មនុស្សនៅលើទឹកដីនៃខេត្តជាប់មាត់សមុទ្រមួយនេះ។ ជាក់ស្ដែង គ្រឹះប្រាសាទអង្គរក្នុំខ្នុង មានអាយុកាលស្ថិតនៅក្នុងសម័យអង្គរ ប្រហែល ស.វ.ទី១១ នៃគ.ស. កុលាលភាជន៍ស្រង់ពីសំពៅលិចកោះស្ដេច និង កោដ្ឋ ឬពាងបុរាណ ដែលមាននៅតាមស្ថានីយពាងបុរាណក្នុងខេត្ត មានអាយុកាលចន្លោះស.វ.ទី១៥ ដល់ ស.វ.ទី១៧ នៃគ.ស. ចំណែកឯចេតិយបុរាណដែលមាននៅក្នុងវត្តសាលាម្នាង មានអាយុកាលស្ថិតក្នុងសម័យ កណ្ដាលចន្លោះ ស.វ.ទី១៧ ដល់ ស.វ.ទី១៩ នៃគ.ស.។

# តម្បាញកន្ទេលផ្អាវ ខេត្តសៀមរាប

*រៀបរៀងដោយ៖ លោកស្រី **យ៉ាន ស្រីពេជ្រ***
*មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តសៀមរាប*

## សេចក្តីផ្តើម

*យើងអាចនិយាយបានថា សៀមរាបជាទឹកដីដែលពោរពេញដោយមរតកវប្បធម៌ដ៏សម្បូរបែប រួមមានមរតកវប្បធម៌រូបីនិងអរូបី។ ដូចយើងឃើញជាតឹកតាងស្រាប់ ប្រាង្គប្រាសាទជាច្រើនបានសាងសង់ឡើងយ៉ាងច្រើនសន្ធឹកសន្ធាប់ជាស្នាដៃល្អឯកផ្នែកស្ថាបត្យកម្មក្នុងដំណើរប្រវត្តិសាស្ត្រដ៏យូរលង់ រហូតទទួលបានការយកចិត្តទុកដាក់ការពារថែរក្សា ចុះក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ១៩៩២។ ការចុះបញ្ជីនេះពុំមែនកំណត់យកប្រាង្គប្រាសាទតែមួយមុខនោះទេ ពោលគឺរាប់បញ្ចូលទាំងទេសភាពវប្បធម៌ ទំនៀមទម្លាប់ប្រពៃណី ការរស់របស់ប្រជាជន ដែលបន្តតាំងពីបុរាណកាលមកដល់បច្ចុប្បន្ន។ ទន្ទឹមនឹងការអភិវឌ្ឍជឿនលឿនរបស់សង្គម និងមានការលាយឡំជាមួយវប្បធម៌បរទេសតាមរយៈទេសចរអន្តរជាតិដែលមកទស្សនាតំបន់អង្គរបានធ្វើឱ្យទំនៀមទម្លាប់ មុខរបរ និងសម្ភារៈប្រើប្រាស់មួយចំនួនប្រឈមនឹងការបាត់បង់ និងការប្រតិបត្តិថមថយដោយអន្ទើ។*

*ជាក់ស្តែង នៅឃុំលាងដៃ ស្រុកអង្គរធំមានសហគមន៍អ្នកស្រុកមួយចំនួនមានចំណេះផ្នែកសិប្បកម្មតម្បាញកន្ទេលផ្អាវនៅដំណើរការជាលក្ខណៈគ្រួសារ ដែលបច្ចុប្បន្នចំណេះនេះកំពុងប្រឈមនឹងការបាត់បង់។ ដោយមានការយកចិត្តទុកដាក់លើមរតកមនុស្សរស់ និងដើម្បីរក្សាចំណេះដឹងនៃសិប្បកម្មតម្បាញកន្ទេលមួយនេះ មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តសៀមរាប បានសិក្សាចងក្រងជាអត្ថបទនេះឡើងដើម្បីទុកជាឯកសារសម្រាប់ការស្រាវជ្រាវជាប្រយោជន៍ដល់យុវជននាពេលអនាគត និងដើម្បីលើកតម្កើងមរតកអរូបីដែលជាព្រលឹងជាតិឱ្យស្ថិតស្ថេរយូរអង្វែង ស្របនឹងពាក្យស្លោកមួយដែលលើកឡើងថា «អភិរក្សដើម្បីអភិវឌ្ឍន៍និងអភិវឌ្ឍន៍ដើម្បីអភិរក្ស»។*

*នៅក្នុងឃុំលាងដៃ ស្រុកអង្គរធំ មានភូមិទាំងអស់ចំនួន៨ភូមិ ហើយប្រជាជនរស់នៅទីនោះមួយភាគធំជាមនុស្សចាស់ស្ទើរតែចេះត្បាញកន្ទេលធ្វើពីរំពេក ចបូត និងផ្អាវ។ ក្នុងចំណោមភូមិទាំង៨នេះ ភូមិតាប្រុកមានចំនួនអ្នកចេះត្បាញកន្ទេលច្រើនជាងគេ។ ហេតុដូច្នេះ នាងខ្ញុំបានជ្រើសរើសករណីសិក្សា «តម្បាញកន្ទេលផ្អាវ ភូមិតាប្រុក» មកចងក្រងដោយបែងចែកជា៤ជំពូកគឺ៖*

*-ជំពូកទី១៖ រុក្ខជាតិប្រើសម្រាប់ត្បាញកន្ទេល*

*-ជំពូកទី២៖ បច្ចេកទេសត្បាញ ក្បាច់លម្អ និងរយៈពេលត្បាញ*

*-ជំពូកទី៣៖ ទីផ្សារ និងចំណូល*

*-ជំពូកទី៤៖ វត្តមានកន្ទេលក្នុងសង្គមខ្មែរ*

## ជំពូកទី១៖ រុក្ខជាតិប្រើសម្រាប់ត្បាញ

*នៅប្រទេសកម្ពុជា យើងអាចរករុក្ខជាតិច្រើនបែបយ៉ាងដើម្បីកែច្នៃយកទៅធ្វើជាកន្ទេល ដូចជា*



រូបលេខ១

ត្នោត រំចេក ចចូត កំប្លោក កក់ និងផ្អាវជាដើម។ ម្យ៉ាងទៀត ការប្រើប្រាស់កន្ទេលក៏អាស្រ័យតាមប្រភេទកន្ទេលនីមួយៗផងដែរ។ ប្រភេទកន្ទេលសាមញ្ញប្រើប្រាស់ប្រចាំថ្ងៃ គេអាចយកស្លឹកត្នោតមកត្បាញធ្វើកន្ទេល។ ឯដើមចចូតក្នុងប្រភេទពួកកក់ក៏គេតែងយកមកត្បាញកន្ទេល ហៅថាកន្ទេលចចូតដូច្នេះតែម្តង (ព្រាប ចាន់ ម៉ារ៉ា, www.yosothor.org)។ ដោយឡែកអ្នកស្រុកអន្លង់ធំឯណោះវិញ សព្វថ្ងៃគេនិយមត្បាញកន្ទេលធ្វើពីផ្អាវច្រើនជាងកន្ទេលធ្វើពីស្លឹកត្នោត និងរំចេក ដែលកាលពីមុនតម្បាញកន្ទេលទាំងពីរប្រភេទនេះមានវត្តមានច្រើនគួរសមដែរ ប៉ុន្តែបច្ចុប្បន្នកម្រនឹងប្រទះឃើញ។

ត្រង់នេះសូមបង្ហាញពីរុក្ខជាតិផ្អាវ ដែលអ្នកស្រុកអន្លង់ធំតែងតែយកមកធ្វើជាកន្ទេល គេហៅថាកន្ទេលផ្អាវ។ ផ្អាវ មានឈ្មោះជាភាសាអង់គ្លេសថា Swamp Fan palm ឬ Mangrove Fan Palm (ឈ្មោះវិទ្យាសាស្ត្រ៖ Licuala Paludosa Griff ស្ថិតក្នុងអំបូរ ARACEAE)។ ផ្អាវ ជារុក្ខជាតិមួយប្រភេទដុះនៅក្នុងព្រៃមាន ពណ៌បៃតង ដើមតូចៗ ទាបៗ ហើយនៅគែមៗធាងរបស់វាមានបន្លាស្រដៀងធាងត្នោត (រូបលេខ១) ។ ផ្អាវជារុក្ខពហុផល ផ្នែកផ្សេងៗវាអាចយកមកប្រើប្រាស់ និងបរិភោគបានដូចជា ស្លឹកផ្អាវគេអាចយកមកវេចនំ ធាងរបស់វាក្រៅពីសក



រូបលេខ២

យកធ្វើកន្ទេលហើយ គេអាចពុះធ្វើជាស្នូលធូបបានថែមទៀតផង។ គោមផ្អាវ គេអាចដាក់លាយសម្លកកូរដែលមានរសជាតិល្វីងតិចៗ និងអាចដុតលាយទឹកជ្រលក់សម្រាប់បរិភោគជាមួយត្រីអាំង យ៉ាងឆ្ងាញ់ពិសារ។ ជាងនេះទៅទៀត ដើម និងឫសផ្អាវក៏ជាឱសថព្យាបាលជម្ងឺផងដែរ។ ដើមរបស់វាប្រើសម្រាប់ព្យាបាលរបេងសួត រីឯឫសវិញប្រើជាថ្នាំព្យាបាលគ្រុន និងរក្សាគភ៌ (មជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្របុរាណ,២០០៩:៨៣)។

យោងតាមសម្តីរបស់អ្នកស្រុកអន្លង់ធំបាន ឱ្យដឹងថា ផ្អាវដែលគាត់យកមកត្បាញនោះ គឺពីដើម

ឡើយ គាត់អាចទៅរកកាប់វានៅក្នុងព្រៃក្បែរៗភូមិ ឬក៏ក្នុងបរិវេណអន្លង់ធំ ប៉ុន្តែឥលូវដោយសារការឈូសឆាយដីដាំដំឡូងមីធ្វើឱ្យបាត់បង់ផ្អាវបន្តិចម្តងៗ។ សព្វថ្ងៃដើម្បីស្វែងរកផ្អាវ អ្នកភូមិប្រមូលគ្នាទាំងប្រុសទាំងស្រីប្រហែល១៨ទៅ២០នាក់ជួលឡានឈ្នួល ឬម៉ូតូកដិះទៅកាប់ផ្អាវនៅស្រុកឆ្ងាយៗដូចជា ពាក់ស្នែង ស្រីស្នំ ។ល។ ពេលគេទៅរកផ្អាវពីក្នុងព្រៃ គឺគេត្រូវការតែកាំបិតព្រា (រូបលេខ២២) និងកាំបិតខ្វៃតែប៉ុណ្ណោះ។ ជាទូទៅ ស្រីៗប្រើកាំបិតព្រាដើម្បីកាប់ ឬលួសជាងផ្អាវតែម្តង។ ដោយឡែកអ្នកខ្លះមានគ្រួសារទៅជាមួយផង គឺថាខាងប្រុសៗចូលចិត្តប្រើខ្វៃដើម្បីត្រួសកាប់យកជាងផ្អាវព្រោះកាប់បានលឿន រីឯស្រីៗប្រើកាំបិតព្រាសម្រាប់លួសបន្ទា។ ផ្ទុយទៅវិញ ចំពោះមនុស្សចាស់ៗដែលគ្មានកម្លាំងទៅកាប់ផ្អាវនៅក្នុងព្រៃឆ្ងាយៗពីផ្ទះ ពួកគាត់បានទិញវា ពីអ្នកលក់ដែលគេដឹកយកមកលក់ដល់ភូមិ ដោយក្នុងមួយបាច់មានតម្លៃពី១២,០០០៛ ទៅ ១៥,០០០៛។

## ជំពូកទី២៖ បច្ចេកទេសត្បាញ ក្បាច់លម្អ និងរយៈពេលត្បាញ

### ក-បច្ចេកទេសត្បាញ

#### *ក.១-សកម្មភាពមុនត្បាញ*

ដំណាក់កាលដែលត្រូវឆ្លងកាត់មុននឹងចាប់ផ្តើមត្បាញកន្ទេលផ្អាវ មានដូចតទៅ៖

ជ្រើសរើសជាងផ្អាវ៖ នៅពេលកាប់ជាងផ្អាវ គេត្រូវជ្រើសរើសផ្អាវដែលមានជាងស្អាតៗ ចាស់ៗ វែងៗ ដោយមិនត្រូវយកជាងណាដែលមានស្នាមអុចៗឬមេស៊ីនោះទេ។ ក្រោយពីកាប់សកបន្ទាបានស្អាតល្អហើយគេត្រូវចងវាជាបាច់ដើម្បីងាយស្រួលក្នុងការលើកដាក់ និងដឹកជញ្ជូន (រូបលេខ២៣)។



រូបលេខ២៣

ការពុះជាងផ្អាវ៖ ជាងផ្អាវមានសណ្ឋានស្រដៀងនឹងជាងត្នោតដែរ។ យើងបែងចែកជា ២ផ្នែក គឺផ្នែកខ្នងមានរាងក្រអូមឡើង (ផ្នែកខាងលើ) និងផ្នែកពោះផតបន្តិច និងរាបស្មើ (ផ្នែកខាងក្រោម)។ របៀបពុះជាង ផ្អាវ គឺត្រូវពុះជាបីចម្រៀកស្មើៗគ្នា ដោយពុះបែងចែកឱ្យមានទំហំប្រហាក់ប្រហែលគ្នា ធ្វើយ៉ាងណាលៃយកខាងខ្នងជា២ផ្នែក និងខាងពោះ ១ផ្នែក ។ ជាទូទៅ ប្រសិនបើមានពេលគ្រប់គ្រាន់ គេត្រូវពុះជាងផ្អាវភ្លាមៗបន្ទាប់ពីយកមកដល់នៅស្រស់ៗល្អព្រោះជាងវានៅសើមងាយស្រួលពុះជៀកៗ ផ្ទុយទៅវិញ គេអាចប្រោះទឹកលើជាងវាដើម្បីកុំឱ្យដាប់ស្វិតស្រពោនស្ងួតដែលជាហេតុធ្វើឱ្យពិបាកពុះជៀកៗ ក្រោយពីពុះបានស្រេចបាច់ហើយ គេត្រូវយកវាទៅហាលសំដិលឱ្យស្ងួតបន្តិចៗ។ ដំណាក់កាលនេះ គេហៅជាងផ្អាវទាំងនោះថា បន្ទោះផ្អាវ។

បិត និងបក៖ បន្ទោះផ្អាវដែលហាលស្ងួតរួចហើយនោះ គេត្រូវយកមកបិតនឹងកាំបិតពីរទៅបីដង (លួស) យកសាច់ពោះផ្អាវចេញឱ្យស្តើងស្អាតឱ្យនៅសល់តែសម្បក ធ្វើដូចនេះគេហៅថា បិត (រូបលេខ២៤)។ វិធីម្យ៉ាងទៀត គេប្រើកាំបិតច្រិបបន្ទោះផ្អាវចំពាក់កណ្តាលផ្នែកពោះ ហើយយកជើងជាន់សង្កត់ផ្នែកម្ខាងនិងប្រើដៃបកយកសាច់ពោះផ្អាវ

ចេញទៅជ្រុងម្ខាងទៀត។ របៀបនេះ គេហៅថា បក និងភាគច្រើនជាមនុស្សចាស់ដែលពុំសូវមាន កម្លាំងដែលប្រើប្រាស់វិធីនេះ (រូបលេខ២៥)។



រូបលេខ២៤



រូបលេខ២៥

ហូត៖ បន្ទាប់ពីបិត ឬបកបានស្អាតរួចរាល់ហើយ គេត្រូវយកបន្ទោះផ្អាវទាំងនោះ (រូបលេខ២៦) ទៅហាលថ្ងៃឱ្យស្ងួតម្ដងទៀត។ ការធ្វើបែបនេះគឺដើម្បីងាយស្រួលជ្រលក់ពណ៌ ហើយមួយវិញទៀតគឺកុំឱ្យផ្អាវធាប់ផុះផ្សិត និងរក្សាទុកបានយូរ។ សិប្បករត្រូវហូតយ៉ាងសម្រិតសម្រាំង និងបែងចែកបន្ទោះផ្អាវដោយជ្រើសរើសយកបន្ទោះណា ដែលមានប្រវែងវែងៗប្រហាក់ប្រហែលគ្នាដាក់មួយបាច់ (ប្រហែលមួយក្ដាប់ដៃ។) គេហៅថារនោង។ បន្ទោះដែលមានប្រវែងខ្លី គេក៏ត្រូវហូតចងវាមួយបាច់ៗដែរ គេហៅថាចាក់។ ការបែងចែកបែបនេះ បង្កឱ្យមានភាពងាយស្រួលសម្រាប់ពេលត្បាញកន្ទេល និងជ្រលក់ពណ៌ផ្សេងៗពីគ្នា (រូបលេខ២៧)។



រូបលេខ២៦




រូបលេខ២៧

ជ្រលក់ពណ៌៖ ដំបូងឡើយគេត្រូវដាំទឹកក្នុងឆ្នាំងធំ១ដោយដាក់ទឹកឱ្យសមល្មមនឹងចំនួនលក្សណ៍ និងផ្អាវដែលយើងត្រូវជ្រលក់។ នៅពេលទឹកពុះ គេត្រូវចាក់ល័ក្តចូលហើយកូរវាបន្តិច។ នៅទីនេះ គេច្រើនប្រើល័ក្តពណ៌ក្រហម ខៀវ ស្វាយ និងរមៀត ដែលគេទិញយកមកពីផ្សារស្រាប់។ ពួកគេពុំមានប្រើល័ក្តធម្មជាតិនោះឡើយ (រូបលេខ២៨)។ មុននឹងដាក់ចូលក្នុងឆ្នាំងល័ក្ត គេត្រូវយកបន្ទោះផ្អាវដែលចងជាបាច់ៗនោះទៅជ្រលក់ក្នុងទឹកឱ្យរីកស្វាង (រីកសំពោង)សិន។ ការធ្វើបែបនេះ ដើម្បីឱ្យល័ក្តឆាប់ជ្រាបបានជ្រៅ និងជាប់ល្អ។ ក្រោយមកទើបគេយកវាទៅដាក់ត្រាំក្នុងឆ្នាំងទឹកដែលមានល័ក្តកំពុងពុះនោះប្រហែល៤ទៅ៥នាទី (រូបលេខ២៩) និងត្រូវប្រែវាត្រឡប់ចុះឡើងដើម្បីឱ្យលក្សណ៍ជាប់សព្វបានល្អ។ បន្ទាប់ពីពិនិត្យឃើញថា បន្ទោះទាំងនោះជ្រាបពណ៌ល្អហើយ គេប្រើដងឬស្សី ឬអង្កត់ឈើស្រង់វាចេញ និងយកទៅលាងទឹកដើម្បីសម្អាតល័ក្តដែលនៅជាប់ខាងក្រៅឱ្យស្អាត និងកុំឱ្យជាប់ដិតដៃនៅពេលត្បាញផង(រូបលេខ២១០)។ ក្រោយពីលាងបានស្អាតហើយ គេត្រូវយកវាទៅសម្រោះទឹកចេញមួយអន្ទើ។ ចុងក្រោយ គេត្រូវយកវាទៅសំដិលហាលថ្ងៃឱ្យស្ងួត(រូបលេខ២១១)។ ការជ្រលក់ពណ៌ គេដាក់ល័ក្តបានតែមួយពណ៌ៗ



រូបលេខ២៨



រូបលេខ២៩



រូបលេខ២១០



រូបលេខ២១០

ប៉ុណ្ណោះ ប្រសិនបើគេចង់បានពណ៌ផ្សេងគេត្រូវចាក់ទឹកចាស់ចោល ហើយដាំទឹកថ្មី និងដាក់ល័ក្តពណ៌ផ្សេងដែលគេចង់បាន។ ដោយឡែកចំពោះពណ៌សវិញ គេពុំចាំបាច់ជ្រលក់នោះទេ ព្រោះបន្ទោះផ្អាវដែលហាលស្ងួតល្អវាមានពណ៌ប្រហាក់

ប្រហែលនឹងពណ៌សស្រេចទៅហើយ។

**ក.២-សកម្មភាពត្បាញ**

គេចាប់ផ្តើមត្បាញតាំងពីព្រលឹមស្រាងៗ ព្រោះគេអាចហាលផ្អាវឱ្យត្រូវទឹកសន្សើម ដើម្បីឱ្យវាទន់ងាយស្រួលត្បាញ។ ជាពិសេសនារដូវភ្លៀងធ្លាក់ អាកាសធាតុត្រជាក់ធ្វើឱ្យផ្អាវកាន់តែទន់ និងរឹតតែងាយស្រួលត្បាញទៅទៀត។ ដូចនេះ គេពុំសូវត្បាញនៅពេលថ្ងៃទេ ព្រោះអាកាសធាតុក្តៅធ្វើឱ្យផ្អាវស្រួយឆាប់បាក់។ ក្នុងផ្អាវមួយបាច់ គេអាចត្បាញកន្ទេលបានមួយ ជួនកាលអាចបានដល់ទៅពីរគឺអាស្រ័យទៅតាមប្រវែងផ្អាវ។ ការត្បាញមានដំណាក់ការដូចតទៅ៖

ការកកន្ទេល៖ មុនដំបូង គេត្រូវកកន្ទេលផ្អាវដោយរៀបបន្ទោះផ្អាវឱ្យមានជារនោង និងចាក់។ បន្ទាប់មកគេកតែខាងរនោងឱ្យឆ្លាស់គ្នាក្បាលកន្ទុយៗ ប្រហែលបួនធ្នាប់ដៃ ដោយប្រើដៃឆ្វេង (គេហៅលើកឆ្វេង) ហើយគេកទៅតាមកម្រាស់ដែលគេចង់បាន និងបន្តរហូតទៅដល់ចុងរនោង។ ក្រោយមកទៀត គេលើកដាក់ក្រឡានៅផ្នែកខាងចាក់ដោយប្រើដៃស្តាំ (លើកស្តាំ) វិញម្តង។ ដោយឡែក សិប្បករខ្លះដែលមានភាពប៉ិនប្រសប់ និងស្ទាត់ជំនាញ គេពុំចាំបាច់កកន្ទេលក៏បានដែរ គឺគេអាចចាប់ផ្តើមត្បាញចាប់ក្បាច់យកតែម្តង។

ការត្បាញ៖ ក្រោយពីករួចរាល់ សិប្បករអាចចាំផ្តើមត្បាញចាប់ក្បាច់ដែលខ្លួនត្រូវការបាន ហើយដូចជាក្បាច់ម្នាស់ ក្បាច់គោម ក្បាច់លាត និងក្បាច់ផ្សេងៗទៀតតាមការបញ្ជាទិញរបស់អតិថិជន។ ក្នុងខណៈពេលកំពុងត្បាញ គេត្រូវយកចិត្តទុកដាក់ និងឧស្សាហ៍លាតកន្ទេល (រឹតទាញរនោង និងចាក់ឱ្យណែនល្អ) បណ្តើរៗផងដែរ ដើម្បីឱ្យសាច់កន្ទេលតឹងស្អាតល្អ និងកុំឱ្យឃ្លាតឆ្ងាយពីគ្នា។

ការវេច៖ ជាដំណាក់កាលចុងក្រោយដែល



រូបលេខ១១២

សិប្បករត្រូវធ្វើ ក្រោយពីត្បាញកន្ទេលតាមទំហំដែលខ្លួនចង់បានហើយ។ ដើម្បីវេចជាយកន្ទេលជុំវិញទាំងអស់ គេត្រូវយកផ្តៅមកជ្រៀកទំហំប៉ុនដើមធូបធ្វើជាមេ ហើយបត់ជាយកន្ទេលដែលនៅសល់ចងភ្ជាប់ជាមួយខ្សែនីឡុងដែលកាលពីមុនគេវេចដោយប្រើល្ពាក់ និងវល្លិយៀវ។ ប៉ុន្តែជួនកាល គេត្បាញកន្ទេលចប់សព្វគ្រប់ហើយគេពុំបានវេចភ្លាមៗនោះទេ។ ប្រការដែលទុកកន្ទេលចោលយូរទម្រាំនឹងបានវេច ធ្វើឱ្យជាយកន្ទេលឆាប់ផុយស្រួយងាយនឹងបាក់។ ដូច្នេះ នៅពេលដែលគេវេចជាយកន្ទេលម្តងៗ គេត្រូវឧស្សាហ៍ប្រោះទឹកដើម្បីផ្តល់សំណើមដល់វា ជៀសវាងកុំឱ្យជាយកន្ទេលបាក់។



រូបលេខ១១៣

## ខ-ក្បាច់លម្អ និងរយៈពេលត្បាញ

ការងារត្បាញកន្ទេលនេះ ជាការផ្ទេរចំណេះបន្តពីសមាជិកក្នុងគ្រួសារពីមួយជំនាន់ទៅមួយជំនាន់ទៀត ពោលគឺតាំងពីជំនាន់ជីដូន ឪពុកម្ដាយបន្តមកដល់ជំនាន់កូនៗ សម័យនោះ ពួកគាត់ចេះត្បាញតែក្បាច់សាមញ្ញ គេហៅថាក្បាច់លើកខ្សែ (រូបលេខ១១៨)។ ក្រោយមក ពួកគាត់បានទទួលការបណ្ដុះបណ្ដាលពីអង្គការអភិវឌ្ឍន៍ស្ត្រី សហការជាមួយមន្ទីរកិច្ចការនារីឱ្យចេះត្បាញកន្ទេលពោរពេញទៅដោយក្បាច់លម្អគាប់ភ្នែក និងភាពវិចិត្រនៅក្នុងនោះបន្ថែមទៀត រួមមាន៖ ក្បាច់ក្រឡាហូល និងក្រឡាម្នាស់ជាដើម (រូបលេខ១៥និង១៦) ។ ជាទូទៅគេត្បាញកន្ទេលលាតរួចមួយក្នុងរយៈពេលបីថ្ងៃ។ រីឯ កន្ទេលក្រឡាម្នាស់ ឬកន្ទេលក្រឡាហូល គេប្រើពេលប្រហែលជាមួយអាទិត្យប្រសិនបើគេធ្វើការងារនេះពេញមួយថ្ងៃជាប្រចាំ។ ចំពោះអ្នកខ្លះវិញប្រើពេលដល់ទៅជិត១ខែ ឬយូរជាងនេះបន្តិចទើបត្បាញរួច ដ្បិតពួកគាត់ឆ្លៀតធ្វើវាតែពេលទំនេរពីការងារធ្វើស្រែ លក់ដូរ ចិញ្ចឹមសត្វ។



រូបលេខ១១០



រូបលេខ១១០



រូបលេខ១១១

## ជំពូកទី៣៖ ទីផ្សារនិងចំណូល

អង្គការអភិវឌ្ឍន៍ស្ត្រី ជាទីផ្សារដ៏សំខាន់ក្នុងការទទួលទិញកន្ទេលពីអ្នកស្រុក។ ពេលដែលត្បាញរួច ពួកគាត់យកទៅលក់ឱ្យអង្គការនេះជាប្រចាំដោយគេឱ្យថ្លៃកន្ទេល និងរបស់លើកទឹកចិត្តបន្ថែមពីលើគឺមីមួយកេស និងប្រាក់២ម៉ឺនរៀលទៀត។ ជួនកាលមានអ្នកផ្សារមកទិញដល់កន្លែងផងដែរ។ ក្រៅពីនេះ ពួកគាត់អាចលក់ឱ្យអ្នកក្នុងភូមិជាមួយគ្នាដែរ ព្រោះមានអ្នកខ្លះពុំចេះត្បាញទេ។ ក្នុងកន្ទេលមួយ (កន្ទេលក្បាច់លាត) គេទិញក្នុងតម្លៃ៤ម៉ឺនរៀល។ ចំណែកឯ កន្ទេលក្បាច់ម្នាស់សម្រាប់ទំហំតូច គេទិញក្នុងតម្លៃ៧ម៉ឺនរៀល និងទំហំធំមានតម្លៃ១០ម៉ឺនរៀល។ កន្ទេលដែលមានតម្លៃថ្លៃជាងគេ ជាកន្ទេលមានក្បាច់ក្រឡាហូល ថ្លៃចាប់ពី១០ម៉ឺនរៀលឡើងទៅលើ។ ការងារនេះបានបំពេញចំណូលមួយផ្នែកទៅលើសេដ្ឋកិច្ចគ្រួសាររបស់ពួកគាត់។ មួយរយៈពេលថ្មីៗនេះផលិតផលក្នុងស្រុកមានការទទួលស្គាល់កាន់តែច្រើនពីប្រជាជនខ្មែរ។ ដោយសារតម្រូវការ

កើនឡើង និងការលើកកម្ពស់ទីផ្សារក្នុងស្រុកធ្វើឱ្យតម្បាញកន្ទេលផ្ការរឹតតែមានទីផ្សារ និងមានតម្លៃខ្ពស់ដែលជាហេតុជម្រុញឱ្យអ្នកស្រុកប្រឹងប្រែងបន្តការងារលើវិស័យនេះបន្ថែមទៀត។

## ជំពូកទី៤៖ វត្តមានកន្ទេលក្នុងសង្គមខ្មែរ

កន្ទេលបានផ្សារភ្ជាប់ទំនាក់ទំនងរវាងធម្មជាតិ និងជីវិតមនុស្សដែលតែងតែនៅជាមួយគ្នា។ វាបង្ហាញវត្តមានជាច្រើនក្នុងសង្គមខ្មែរ និងកិច្ចពិធីផ្សេងៗទៅតាមកាលទេសផ្សេងៗពីគ្នា ដូចជា៖

### ១-រុំសព

តាមរយៈកំណាយបុរាណវិទ្យាឆ្នាំ២០០៤-២០០៥ រៀបចំឡើងដោយសាលាបារាំងចុងបូព៌ា សហការជាមួយអាជ្ញាធរអប្សរានៅបារាយណ៍ខាងលិច (កោះតាមាស) បានរកឃើញតឹកតាងនៃការតាំងភូមិករនាសម័យសំរឹទ្ធ ក៏ដូចជាសម្គាល់ឃើញទីកប់សពបុរាណមួយដែលអាចមានអាយុកាលយ៉ាងហោចណាស់ក្នុងអំឡុង៣០០០ឆ្នាំមុន។ គេប្រទះឃើញ កុលាលភាជន៍ធំៗ គ្រឿងអលង្ការ ឧបករណ៍ប្រើប្រាស់ ឆ្អឹងសត្វចតុប្បាទ និងឆ្អឹងត្រីដែលកប់ នៅជាមួយសព។ ជាងនេះទៅទៀត មនុស្សសម័យនោះប្រើកន្ទេលដើម្បីរុំសាកសព (Pottier, 2004:176)។



រូបលេខ២១៧ (ប្រភពរូប៖ https://apsaraauthority.gov.kh)

### ២-ក្នុងពិធីមង្គលការ

នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍នាសម័យមុន មានពិធីមួយដែលចាស់ៗនិយមធ្វើគឺពិធីរាំសាកន្ទេល ដោយគេឱ្យអ្នកភ្លេងទៅច្រៀងរាំសាកន្ទេលនាពេលបញ្ចប់កម្មវិធី (លី ១៩៩៥:១៧៧)។ ស្វាមី និងភរិយា ទទួលកន្ទេលសែងយកទៅទុកខាងក្នុងក្រាលជាកន្ទេលដំណេក (ញឹក ១៩៦៥:៩៩)។

ដោយឡែក នៅក្នុងមង្គលការនៅតំបន់ខ្លះមានកិច្ចធ្វើធ្មេញ។ កូនកម្លោះ និងកូនក្រមុំត្រូវមានស្រូវ កញ្ចើរៀងៗខ្លួន។ នៅព្រឹកព្រលឹមថ្ងៃទីពីរ គេយកកន្ទេលមកគ្របលើស្រូវកញ្ចើទាំងពីរនោះ ដើម្បីឱ្យអ្នកទាំងពីរអង្គុយពីលើនៅពេលធ្វើធ្មេញ (www.yosothor.org)។



រូបលេខ២១៨ (ប្រភពរូប: www.facebook.com)



រូបលេខ២១៩ (ប្រភពរូប: www.yosothor.org)

### ៣-ក្រាលអាំងភ្លើង



រូបលេខ៣៣ ( ប្រភពរូប: www.google.com )

### ៤-ពេលបែនស្រូវ



រូបលេខ៣៤

( ប្រភពរូប:កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ លេខ២១០ )

## សន្និដ្ឋាន

វត្តមានកន្ទេល មានតាំងពីសម័យបុរេប្រវត្តិមកម្ល៉េះដោយផ្អែកលើកស្តុតាងបុរាណវិទ្យានឹងបន្តប្រើប្រាស់រហូតមកដល់បច្ចុប្បន្ន។ ជាការពិតណាស់ ការត្បាញកន្ទេលនេះដើមឡើយគ្រាន់តែជាកិច្ចការដែលភាគច្រើនជាស្ត្រីមេផ្ទះធ្វើសម្រាប់កំដរដៃ ដើម្បីទុកជារបស់ ប្រើប្រាស់ផ្ទាល់ខ្លួន និងសហគមន៍តែប៉ុណ្ណោះ។ អាស្រ័យដោយកត្តាសេដ្ឋកិច្ច ការត្បាញ កន្ទេលក៏មានការផ្លាស់ប្តូរពីកិច្ចការបន្ទាប់បន្សំទៅជារបរមួយដែលអាចសម្រាលដល់ការរស់នៅបានមួយផ្នែកផងដែរ។ ជាក់ស្តែង នៅក្នុងតំបន់អង្គរជាទីតាំងរាជធានីចាស់ និងមានអារ្យធម៌ដ៏ខ្ពង់ខ្ពស់ក៏មានសេសសល់នូវចំណេះត្បាញកន្ទេលផងដែរ។ ជាពិសេស ប្រជាជនភូមិតាប្រុក ក្នុងស្រុកអង្គរធំសព្វថ្ងៃនៅបន្តរក្សា និងប្រកបរបរត្បាញកន្ទេលលក់ និងប្រើប្រាស់ផ្ទាល់ខ្លួនក្រោយពីសម្រាកការងារធ្វើស្រែចម្ការ។ ត្បិតតែការងារនេះ នៅមានដំណើរការពិតមែន ប៉ុន្តែចំនួនអ្នកចេះត្បាញ និងប៉ិនប្រសប់នៅមានតិចតួចណាស់ ហើយភាគច្រើនសុទ្ធតែជាមនុស្សស្រីមានវ័យចំណាស់។ ដូចនេះយើងគួរយកចិត្តទុកដាក់ធ្វើការបណ្តុះបណ្តាលគាំទ្រ និងស្វែងរកទីផ្សារសម្រាប់ពួកគាត់។ ម្យ៉ាងទៀតគួរគិតគូរដល់ការដាំដុះរុក្ខជាតិផ្តៅឡើងវិញ ព្រោះបច្ចុប្បន្នកំពុងប្រឈមនឹងការខ្វះខាត។

កន្ទេល តែងមានវត្តមានយ៉ាងជិតស្និទ្ធជានិច្ចនៅក្នុងដំណើរជីវិតខ្មែររៀបចាប់តាំងពីពេលកើតរហូត ដល់ថ្ងៃស្លាប់បាត់បង់ជីវិត។ កន្ទេលជាវត្ថុប្រើប្រាស់មួយដែលសាមញ្ញច្នៃពីរុក្ខជាតិព្រៃ ប៉ុន្តែវាអាចបង្ហាញពីការគោរពសីលធម៌ សុជីវធម៌ សុភមង្គលលើកតម្កើងមនុស្សឱ្យខ្ពង់ខ្ពស់ និងបង្ហាញពីសង្គមមួយដែលមានអារ្យធម៌យូរអង្វែង។


### បញ្ជីឯកសារពិគ្រោះជាភាសាខ្មែរ

• ញឹក នូវ៖ ១៩៦៥, ក្បួនអាពាហ៍ពិពាហ៍, ភាគ១

• ពុទ្ធសាសនបណ្ឌិត្យ៖ ១៩៦៧, វចនានុក្រមខ្មែរ, ភ្នំពេញ

• លី សុវីរ៖ ១៩៩៩, អាពាហ៍ពិពាហ៍ខ្មែរសតវត្សទី១៩ និងដើមសតវត្សទី២០, ភាគ២

• កម្រងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ ឆ្នាំ ២០០៥,“ជំនឿ, ទំនៀមទម្លាប់”,លេខ២១០

### បញ្ជីឯកសារពិគ្រោះជាភាសាបរទេស

• *Pottier Christophe, Phin Vichear Sachara, Heng Than, Chhay Rachana, Khieu Chan,*

• *Fabrice Demter: 2004, Koh Ta Méas, Un site préhistorique dans le Baray Occidental Rapport préliminaire*

# សិប្បកម្មចម្លាក់ស្ពាន់, ស្ម័ត, តម្បាញដោយដៃអំពីរស្ម័ ជាងត្នោត, ផ្តៅ(អំពីរុក្ខជាតិ), ក្អម ថ្នាំង(អំពីដីដុត)

*មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺ*

## ១- អំពីទម្រង់សិល្បៈសិប្បកម្មដោយដៃ អំពីចម្លាក់ប្រាក់ ស្ពាន់ នៅភូមិត្រពាំងពោធិ៍ ឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ







*«សិប្បកម្មដោយដៃអំពី ចម្លាក់ប្រាក់ ស្ពាន់» ជាសិប្បកម្មមួយប្រភេទក្នុងចំណោមសិប្បកម្មដទៃទៀត ដែលសិប្បករខ្មែរយើងបានយកប្រាក់ ឬស្ពាន់ មកកែច្នៃធ្វើជាសម្ភារជាច្រើនមុខ និងគ្រឿងលម្អក្នុងពិធីផ្សេងៗ ដូចជា ជើងពាន ផ្ទិល ខ្សែក្រវាត់ កងដៃ កងជើង ស្នាប់ដៃ តុ ទូ កៅអី គ្រឿងលម្អក្នុងគេហដ្ឋាន និងសម្ភារប្រើប្រាស់ជាច្រើនមុខទៀត តាមតម្រូវការរបស់ប្រជាពលរដ្ឋខ្មែរ។ ដូច្នេះហើយ នៅក្នុងសង្គមខ្មែរ គេឱ្យតម្លៃដល់សិប្បកម្មចម្លាក់ប្រាក់ ស្ពាន់ កែច្នៃដោយដៃប្រកបដោយសោភណភាព។ របៀបនៃការផលិតចម្លាក់ប្រាក់ ស្ពាន់ មានដំណាក់កាលនីមួយៗដូចខាងក្រោម៖*

***- ដំណាក់កាលទី១៖***

*ជាដំណាក់កាលដំបូងដែលត្រូវយកជ័រចុងលាយជាមួយដីលែង និងខ្លាញ់ ដាក់ក្នុងខ្ទះដុតភ្លើងឱ្យក្តៅ រួចកូរច្របល់ជាមួយគ្នាឱ្យចូលជាល្បាយនឹងគ្នា បន្ទាប់មកយកមកចាក់ពីលើបន្ទះក្តារ ដោយទុករយៈពេល១ថ្ងៃដើម្បីឱ្យស្ងួត។*

**- ដំណាក់កាលទី២៖**

ជាដំណាក់កាលត្រូវយកប្រាក់ ឬស្ពាន់មកបិទពីលើជ័រដែលបានពាសលើបន្ទះក្តារ រួចយកវត្ថុរឹងល្មមមកដំពីលើសើៗ បន្ទាប់មកយកក្រដាសដែលមានរូបភាព ឬក្បាច់ដែលបានគូរតាមទំហំដែលចង់បាន មកបិទពីលើប្រាក់ស្ពាន់នោះ រួចកាល់ (ចម្លង) ពីលើក្បាច់ បន្ទាប់មកទៀតយើងចាប់ផ្តើមដាប់ក្បាច់តាមរូបរាងក្បាច់។










**- ដំណាក់កាលទី៣៖**

ក្រោយពីការឆ្លាក់ ឬដាប់ចេញជារូបរាងហើយ យើងត្រូវយកប្រាក់ ឬស្ពាន់នោះទៅដុត ឬរោលជាមួយនឹងភ្លើង រយៈពេល២ទៅ៣នាទី រួចយកស្ពាន់នោះដាក់ពីលើបន្ទះក្តារដែលមានជ័រម្តងទៀត បន្ទាប់មកត្រូវដាប់បំប៉ោងក្បាច់ដើម្បីឱ្យឃើញក្បាច់ផុសចេញមកស្អាត និងច្បាស់ល្អ។

**- ដំណាក់កាលទី៤៖**

ជាដំណាក់កាលចុងក្រោយដែលយើងកាត់ផ្តាច់ប្រាក់ ឬស្ពាន់ដែលបានឆ្លាក់ និងដាប់រួចចេញពីបន្ទះជ័រ រួច យកទៅត្រាំទឹកអាស៊ីត រយៈពេល ៥ ទៅ១០នាទី ដើម្បីសម្អាតកម្ទេចកាកសំណល់តូចៗ ចេញពីប្រាក់ ឬស្ពាន់នោះ និងប្រើច្រាសដុសសម្អាតឱ្យបានស្អាតល្អ បន្ទាប់មកទៀតយកប្រាក់ និងស្ពាន់មកដុតឱ្យស្ងួតជាការស្រេច។









## ២- ស្ដីពីទម្រង់សិល្បៈសិប្បកម្មដោយដៃ អំពីចម្លាក់ស្មិត នៅឃុំព្រះស្រែ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ

"សិប្បកម្មដោយដៃអំពី ចម្លាក់ស្មិត" គឺជាផ្នែកមួយក្នុងចំណោមវិស័យចម្លាក់ផ្សេងៗជាច្រើននៃសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ដែលបណ្ដាសិប្បករ បានយកគ្រឿងស្ពាន់មកស្ធ្វើជារូបព្រះបដិមាសម្រាប់គោរពបូជា រូបសំណាកផ្សេងៗ គ្រឿងក្បាច់រចនា ចម្លាក់បុរាណ វត្ថុអនុស្សាវរីយ៍ ឧបករណ៍សិល្បៈ ព្រមទាំងសម្ភារប្រើប្រាស់ប្រចាំថ្ងៃជាច្រើន។ ដូច្នេះហើយនៅក្នុងសង្គមខ្មែរត្រូវបានប្រជាពលរដ្ឋទូទៅឱ្យតម្លៃជាចម្លាក់ដ៏ប្រណីត ដែលមានភាពរឹងមាំប្រកបដោយសោភណភាពយ៉ាងល្អឥតខ្ចោះ។

កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ ក្រុមការងារការិយាល័យសិល្បៈសូនរូប និងសិល្បៈសិប្បកម្មនៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺ បានចុះសិក្សាស្រាវជ្រាវអំពីទម្រង់សិល្បៈសិប្បកម្មដោយដៃអំពីចម្លាក់ស្មិត នៅភូមិប្រកិល ឃុំព្រះស្រែ ស្រុកឧដុង្គ ក្នុងរោងសិប្បកម្មចម្លាក់របស់លោក សុខ ពិសិដ្ឋ មានវ័យ ៤២ឆ្នាំ ជាសិប្បករចម្លាក់ស្មិត ហើយលោកបានរៀបរាប់អំពីរបៀបនៃការផលិតចម្លាក់ស្មិតដែលមានដំណាក់កាលដូចខាងក្រោម៖

- **ដំណាក់កាលទី១៖** ( ការសូនរូប)

គឺជាដំណាក់កាលនៃការព្រាងរូប សូនចេញពីក្រមួន ដីឥដ្ឋ ឬស៊ីម៉ងត៍ជាដើម ឱ្យចេញបានជារូបរាងដែលតម្រូវការចង់បាន បន្ទាប់មកត្រូវរក្សាទុករូបដែលបានសូនរួចនោះឱ្យមានសភាពរឹង ដើម្បីចម្លងធ្វើជាពុម្ព។





**- ដំណាក់កាលទី២៖** (ការចម្លងពុទ្ធ)

គឺជាដំណាក់កាលនៃការចម្លងធ្វើជាពុទ្ធ





ពីម្នាងសិលា ស៊ីម៉ងត៍ ការដ័រស្មាច់រឹង ឬស៊ីលីកូន (ការបាញ់កញ្ចក់) ជាដើម ហើយពុទ្ធដែលបានចម្លងរួចត្រូវទុកវាឱ្យមានសភាពរឹងមាំងរយៈពេល ២ ទៅ ៣ថ្ងៃ។

**- ដំណាក់កាលទី៣៖** (ការបកពុទ្ធ)

គឺជាដំណាក់កាលនៃការបកពុទ្ធ ដោយត្រូវបកក្រមួនរួចរាល់បិទខ្សាច់លាយជាមួយម្នាងសិលា ហើយត្រូវយកដែកមកស្រោក់លើពុទ្ធ ចន្លោះ១តឹកពីគ្នាជុំវិញ ដើម្បីកុំឱ្យខូចទ្រង់ទ្រាយ រួចយកខ្សាច់និងម្នាងសិលាលាយចូលជាមួយគ្នាឱ្យសព្វ បន្ទាប់





មកត្រូវយកមកបិទជុំវិញដែក។

**- ដំណាក់កាលទី៤៖** (ការដុតពុទ្ធ)

គឺជាដំណាក់កាលនៃការយកពុទ្ធដែលបានចម្លងរួចរាល់ទៅដុត ដោយប្រើអុស ឬហ្គាស់ឱ្យឆ្អិនរយៈពេលពី១០ ទៅ ២៤ម៉ោង តាមទំហំរូប





ដែលយើងបានសូន។

**- ដំណាក់កាលទី៥៖** (ការស្ងួចាក់ស្ពាន់)
គឺជាដំណាក់កាលចុងក្រោយ នៅពេលដែលពុម្ព បានរៀបរាប់តាមដំណាក់កាលនីមួយៗខាងលើរួចមក យើងត្រូវយកស្ពាន់មកស្ងួដោយប្រើរយៈពេលពី ៥ ទៅ ៧ម៉ោង ហើយយកស្ពាន់ដែលបានស្ងួនោះទៅចាក់ចូលក្នុងពុម្ព ទុកមួយរយៈរហូតដល់ស្ពាន់





ចុះត្រជាក់ បន្ទាប់មកត្រូវវាយបំបែកពុម្ព ដើម្បីយករូបនៅខាងក្នុងចេញ ហើយរក្សាទុកស្ពាន់ពី ២ ទៅ៣ថ្ងៃ និងសម្អាតជាកាស្រេច។

## ៣-ទម្រង់សិល្បៈសិប្បកម្មតម្បាញដោយដៃ អំពីធាងត្នោត នៅឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

«សិប្បកម្មតម្បាញដោយដៃអំពីធាងត្នោត» ជាសិប្បកម្មមួយប្រភេទក្នុងចំណោមសិប្បកម្មតម្បាញសរសៃអំបោះ វល្លិផ្ដៅ វល្លិរពាក់ ឫស្សី... ដែលសិប្បករបានយកធាងត្នោតមកកែច្នៃចេញជាច្រើនដូចជាកន្ទ្រក កញ្ជ្រែង ទម្រធ្នាំង រាវចាន រង្វេលជាល អង្រឹង អម្រែក ខ្សែគោ និងវត្ថុអនុស្សាវរីយ៍ជាច្រើនទៀត។ ដូច្នេះហើយនៅក្នុងសង្គមខ្មែរត្រូវបានប្រជាពលរដ្ឋទូទៅឱ្យតម្លៃលើសិប្បកម្មដោយដៃ។

កាលពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារការិយាល័យសិល្បៈសូនរូបនិងសិល្បៈសិប្បកម្ម នៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺ បានចុះសិក្សាស្រាវជ្រាវអំពីទម្រង់សិល្បៈសិប្បកម្មតម្បាញអំពីធាងត្នោតនៅផ្ទះរបស់លោកស្រី

យ៉ាំង ចន្ថា មានអាយុ៥៤ឆ្នាំ ស្ថិតនៅភូមិព្រៃជ្រៃ ឃុំវាល ស្រុកគងពិសី គាត់បានប្រកបសិក្បកម្ម មួយនេះជាយូរឆ្នាំណាស់មកហើយ លោកស្រីបាន រៀបរាប់ពីរបៀបនៃតម្បាញធាងត្នោត ដែលមាន ដំណាក់កាលដូចខាងក្រោមៈ

**- ដំណាក់កាលទី១ៈ**

គឺជាដំណាក់កាលដំបូងត្រូវទៅរកធាងត្នោតចាស់ល្មមដែលអាចប្រើប្រាស់បាន រួចកាប់យកមកហាលថ្ងៃរយៈពេល១ថ្ងៃឱ្យមានសភាពស្ងួតល្មម









រួចរះស្វឹកចេញពីធាង។

**- ដំណាក់កាលទី២៖**

ជាដំណាក់កាលនៃការយកធាងត្នោតដែលបានរះស្វឹកចេញមកចៀរឬច្រៀកជាបន្ទះតូចស្តើងៗ បន្ទាប់មកយកទៅត្រាំទឹក១ម៉ោងទៅ២ម៉ោង រួច









យកមកហាលថ្ងៃឱ្យស្ងួតល្មម។

**- ដំណាក់កាលទី៣៖**

គឺជាដំណាក់កាលបន្ទាប់ ដែលត្រូវយកធាងត្នោតដែលបានហាលថ្ងៃរួមយកកាច់សកជា











បន្ទះតូចស្តើងៗល្មម នឹងអាចត្បាញបាន។

**- ដំណាក់កាលទី៤៖**

ជាដំណាក់កាលចុងក្រោយ យកជាងត្នោតដែលបានកាច់សកជាបន្ទះតូចស្តើងអាចយកមកត្បាញចេញជាទម្រង់ជាច្រើនដូចជាកន្ត្រក កញ្ច្រែង ទម្រផ្កាំង ពាវចាន រង្វេលជាល អង្រឹង អម្រែក





ខ្សែគោ និងវត្ថុអនុស្សាវរីយ៍ជាច្រើនទៀត។

## ៤- ទម្រង់សិល្បៈសិប្បកម្មដោយដៃ ក្អម ឆ្នាំងពីដីដុត នៅឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

«សិប្បកម្មដោយដៃអំពី ក្អម ឆ្នាំងពីដីដុត» ដែលភាសាបច្ចេកទេសហៅថា «កុលាលភាជន៍» សិប្បកម្មនេះជាផ្នែកមួយក្នុងចំណោមសិប្បកម្ម

ទាំងអស់ វិស័យចម្លាក់ផ្សេងៗជាច្រើននៃសិល្បៈសូនរូបនិងសិល្បៈសិប្បកម្ម ដែលសិប្បករបានប្រើប្រាស់ដីស្អិតមកកែច្នៃ ចេញជាទម្រង់ ក្អម ផ្ទាំង ចាន ក្រឡ ព្រមទាំងវត្ថុអនុស្សាវរីយ៍ជាច្រើនទៀត។ ដូច្នេះហើយនៅក្នុងសង្គមខ្មែរត្រូវបានប្រជាពលរដ្ឋទូទៅឱ្យតម្លៃសិប្បកម្មដោយដៃ។

កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ ក្រុមការងារការិយាល័យសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម នៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺ បានចុះស្រាវជ្រាវអំពីទម្រង់សិល្បៈសិប្បកម្មដោយដៃអំពីដីដុត នៅភូមិដំដែក ឃុំព្រៃញាតិ របស់លោកអ៊ុំឈ្មោះ គង់ ផង់ មានអាយុ ៦២ឆ្នាំ ជាសិប្បករធ្វើក្អម ផ្ទាំង តាំងពីឆ្នាំ១៩៧៩ ហើយលោកអ៊ុំបានរៀបរាប់ពីរបៀបនៃការផលិតក្អម ផ្ទាំងដែលមានដំណាក់កាលដូចខាងក្រោម៖

**- ដំណាក់កាលទី១៖**

គឺជាដំណាក់កាលដំបូង ត្រូវយកហាលឱ្យស្ងួតយ៉ាងយូររយៈពេល ១ ទៅ ២ថ្ងៃ បន្ទាប់មកយកដីដែលបានហាលទាំងអស់នោះមកបំបែកវាយវាឱ្យម៉ត់ រួចយកដីរែងជាមួយនឹងស្នៀ្ស ឬកញ្ច្រែង ដើម្បីយកកាត់សន្សំដែលមានសមាភាពរឹង( ថ្ម ក្រួស ) 





ចេញ។

**- ដំណាក់កាលទី២៖**

គឺជាដំណាក់កាលនៃការយកដីដែលបានរែងទាំងនោះមកច្របល់ជាមួយទឹកឱ្យសព្វចូលគ្នា បន្ទាប់មកទៀតយកដីនោះមកបែន ( ជាបន្ទះសំប៉ែតប្រវែងជាង៣តឹត) រួចយកទៅហាលថ្ងៃឱ្យរឹងល្មម







ដើម្បីយកដីនោះមកធ្វើចេញជារូបរាង។

***- ដំណាក់កាលទី៣៖***

គឺជាដំណាក់កាលដែលត្រូវធ្វើការវះមាត់ក្អម និងរូបរាងក្អម រួចយកទៅហាលថ្ងៃដើម្បីឱ្យរឹងល្មមដែលយើងអាចវះចេញជារាងបាន បន្ទាប់ពីបានហាលថ្ងៃរួចត្រូវយកមកបំប៉ោង ឱ្យចេញជារាងក្អម  រួមយកទៅហាលថ្ងៃម្តងទៀតដើម្បីឱ្យរឹង







ល្មម និងវាយបាតសម្រេចចេញជារាងក្អម។

***- ដំណាក់កាលទី៤៖***

យកក្អមដែលបានធ្វើរួចរាល់ មកហាលថ្ងៃយ៉ាងយូរពី ២ទៅ ៣ថ្ងៃ ដើម្បីឱ្យក្អមទាំងនោះបាន





រឹងមាំ។

**- ដំណាក់កាលទី៥៖**

គឺជាដំណាក់កាលចុងក្រោយ យកក្អមដែលបានហាលថ្ងៃរួចបន្ទាប់មកយើងត្រូវប្រមូលក្អមទាំងនោះយកទៅរៀបចំចូលក្នុងឡ ដោយយកចំបើងរៀបពីលើក្អម រួចដុតយ៉ាងយូររយៈពេលពី





២ ទៅ ៣ថ្ងៃ ជាការស្រេច។

## ៥- ទម្រង់សិល្បៈសិប្បកម្មតម្បាញដោយដៃអំពីរុក្ខជាតិ "វល្លិផ្ដៅ" នៅភូមិព្រៃស្រឡែងឃុំទួលអំពិល ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ

“សិប្បកម្មតម្បាញដោយដៃអំពី រុក្ខជាតិវល្លិផ្ដៅ” ជាសិប្បកម្មមួយប្រភេទក្នុងចំណោមសិប្បកម្មដទៃទៀតដែលសិប្បករខ្មែរបានយកដើមរុក្ខជាតិម្យ៉ាងឈ្មោះថា “វល្លិផ្ដៅ” យកមកកែច្នៃធ្វើជាសម្ភារជាច្រើនមុខដូចជា៖ កន្ត្រក កញ្ច្រែង តុ ទូ កៅអី និងសម្ភារប្រើប្រាស់ជាច្រើនមុខទៀត ។ល។ តាមតម្រូវការរបស់ប្រជាពលរដ្ឋខ្មែរ។ ដូច្នេះហើយនៅក្នុងសង្គមខ្មែរគេឱ្យតម្លៃដល់សិប្បកម្មវល្លិផ្ដៅ ដែលផលិតក្នុងស្រុកធ្វើដោយដៃ។

កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងារនៃការិយាល័យសិល្បៈសូនរូប និងសិល្បៈសិប្បកម្មនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺ បានចុះសិក្សាស្រាវជ្រាវទម្រង់សិប្បកម្មដោយដៃអំពីរុក្ខជាតិ «វល្លិផ្ដៅ» ដែលស្ថិតនៅផ្ទះរបស់លោក ង៉ែត ប៊ុន មានអាយុ៥៦ឆ្នាំ រស់នៅភូមិព្រៃស្រឡែង ឃុំទួលអំពិល ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។ គាត់បានប្រកបរបរសិប្បកម្មតម្បាញវល្លិផ្ដៅនេះរយៈពេលជាង ១០ឆ្នាំមកហើយ លោកបានរៀបរាប់អំពីរបៀប នៃការផលិតវល្លិផ្ដៅ ដែលមានដំណាក់កាលនីមួយៗ ដូចខាងក្រោម៖

**- ដំណាក់កាលទី១៖**

ជាដំណាក់កាលដំបូង ដែលសិប្បករបានទៅរកវល្លិផ្ដៅមានសភាពចាស់ល្មមដែលអាចប្រើប្រាស់បាន រួចយកមកហាលថ្ងៃរយៈពេល ១ថ្ងៃ ឱ្យស្ងួតល្មម បន្ទាប់មកត្រូវសកសំបក និងស្ទីកចេញ









ពីដើមវល្លិឱ្យស្អាត។

**- ដំណាក់កាលទី២៖**

ត្រូវយកវល្លិដែលបានសម្អាតរួចរាល់ទាំងនោះមកកាត់ច្រៀកតាមខ្នាតដែលត្រូវផលិត និងអាចដំឡើងជាសម្ភារប្រើប្រាស់ផ្សេងៗតាមបច្ចេកទេស







របស់សិប្បករ។

**- ដំណាក់កាលទី៣៖**

បន្ទាប់ពីបានដំឡើងរូបចេញជារូបរាង សិប្បករបានយកផលិតផលពាក់កណ្ដាលសម្រេចមកធ្វើការលាបពណ៌ ឬត្បាញវល្លិតូចៗ ដែលបានជ្រលក់ថ្នាំរួច ដើម្បីឱ្យមានសោភណភាព។

**- ដំណាក់កាលទី៤៖**

ជាដំណាក់កាលចុងបញ្ចប់ ដែលសិប្បករត្រូវយកផលិតផលសម្រេចមកដាក់តាំងលក់នៅទីផ្សារតាមតម្រូវការរបស់អតិថិជនក្នុងស្រុក។

















# ជំពូកទី២
# របាយការណ៍, គម្រោងការ

# ការរៀបចំខ្សែទស្សនាចរភ្ញៀវទេសចរតំបន់អង្គរ (សៀមរាប)

## ១- សេចក្តីផ្តើម

តំបន់អង្គរ ជារមណីយដ្ឋានបេតិកភណ្ឌមួយនៅក្នុងខេត្តសៀមរាប ដែលបុព្វបុរសខ្មែរបានសាងសង់ប្រាសាទបុរាណរាប់រយបន្សល់ទុកឱ្យកូនចៅពីមួយជំនាន់ទៅមួយជំនាន់ទៀត។ រមណីយដ្ឋានអង្គរត្រូវបានគេទទួលស្គាល់ថា ជាតំបន់ប្រវត្តិសាស្ត្រដ៏សំខាន់នៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានចុះក្នុងបញ្ជីក្នុងបេតិកភណ្ឌពិភពលោកនៅឆ្នាំ១៩៩២។ តំបន់សៀមរាបអង្គរទាំងមូលត្រូវបានបែងចែកជា៥តំបន់ ដែលមានកម្រិតការពារខុសៗគ្នាតាមព្រះរាជក្រឹត្យលេខ ០០១នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរ។ តំបន់១ ជារមណីយដ្ឋានមានប្រាសាទ (ប្រាង្គប្រាសាទប្រវត្តិសាស្ត្រ និងស្ថានីយបុរាណវត្ថុកម្រិតជាតិ)។ តំបន់២ ជាឧទ្យានបុរាណវត្ថុត្រូវការពារ (តំបន់ទ្រនាប់ដែលស្ថិតនៅជុំវិញរមណីយដ្ឋានមានប្រាសាទ)។ តំបន់៣ ជាតំបន់ទេសភាពវប្បធម៌ត្រូវការពារ (បរិស្ថានដែលបង្កើតឡើងដោយអន្តរាគមន៍របស់មនុស្ស ឆ្លងកាត់ពេលវេលា)។ តំបន់៤ ជាតំបន់ដែលមានសារប្រយោជន៍ខាងបុរាណវត្ថុវិទ្យា ឬប្រវត្តិសាស្ត្រ (រមណីយដ្ឋានដែលគេស្គាល់ទីតាំង ឬត្រូវរកទីតាំងហើយដែលជាសារៈសំខាន់នៃតំបន់នេះ គឺអាចស្គាល់តែតាមរយៈការសិក្សាស្រាវជ្រាវនៅនឹងកន្លែងប៉ុណ្ណោះ)។ តំបន់៥ ជាបរិវេណសម្រាប់អភិវឌ្ឍសង្គម សេដ្ឋកិច្ច និងវប្បធម៌នៃតំបន់សៀមរាបអង្គរ។

ជារៀងរាល់ឆ្នាំមានភ្ញៀវទេសចរទាំងភ្ញៀវជាតិនិងភ្ញៀវអន្តរជាតិយ៉ាងច្រើនកុះករ បានធ្វើដំណើរមកទស្សនាប្រាសាទក្នុងរមណីយដ្ឋានអង្គរ ដែលចំនួនភ្ញៀវទេសចរគិតជាមធ្យមប្រមាណ ៥,៧៥៨,១៤២ នាក់ (ជាអក្សរ ប្រាំលាន ប្រាំពីររយហាសិបប្រាំបីពាន់ មួយរយសែសិបពីរនាក់) ក្នុង១ឆ្នាំ គិតរយៈពេល៣ឆ្នាំ គឺពីឆ្នាំ២០២២ ដល់ ២០២៤ (ប្រភព គ្រឹះស្ថានអង្គរ)។ យោងតាមទិន្នន័យភ្ញៀវទេសចរច្រើនខាងលើនេះ នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍និងវប្បធម៌ បានធ្វើការគិតគូររៀបចំផែនការគ្រប់គ្រងលំហូរភ្ញៀវទេសចរតាមប្រាសាទនីមួយៗ ដើម្បីរក្សាបាននូវគុណតម្លៃដល់ប្រាសាទរមណីយដ្ឋានអង្គរ និងសុខសុវត្ថិភាពដល់ភ្ញៀវទេសចរផងដែរ។ ការងាររៀបចំផែនការគ្រប់គ្រងលំហូរភ្ញៀវទេសចរ ត្រូវបានអនុវត្តស្របទៅតាមផែនការមេមួយមានឈ្មោះថា *Tourism Development Plan for the Destination Siem Reap-Angkor 2021-2035 (TDP) of APSARA National Authority* ។ ក្នុងការរៀបចំការងារគ្រប់គ្រងលំហូរភ្ញៀវទេសចរនេះ ក្រុមការងាររៀបចំ ខ្សែទស្សនាចរនៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌បានធ្វើការសិក្សារៀបចំនូវខ្សែទស្សនាថ្មី ការធ្វើបច្ចុប្បន្នភាពខ្សែទស្សនា គិតគូររៀបចំជាផ្ទាំងព័ត៌មានបរិយាយពីចំនុចសំខាន់ៗរបស់ប្រាសាទ និងស្លាកសញ្ញាសំខាន់ៗជាច្រើន ដើម្បីសម្រួលដល់ការទស្សនារបស់ភ្ញៀវទេសចរ ព្រមទាំងរក្សាបាននូវគុណភាពទស្សនាប្រាសាទ ហើយក៏អាចផ្តល់នូវបទពិសោធដ៏សម្បូរបែបដល់

ភ្ញៀវទេសចរ កំលុងពេលទស្សនាប្រាសាទទៀតផង។ ការរៀបចំគម្រោងគ្រប់គ្រងលំហូរភ្ញៀវទេសចរ តាមរយៈរៀបចំខ្សែទស្សនាចរក្នុង-ក្រៅ និងជុំវិញប្រាសាទពិតជាមានសារប្រយោជន៍ច្រើនដល់ភ្ញៀវទេសចរ និងបានចូលរួមរក្សាបាននូវគុណតម្លៃរបស់ប្រាសាទ ហើយនឹងរមណីយដ្ឋានអង្គរទាំងមូល។

## ២-ការរៀបចំការងារគ្រប់គ្រងលំហូរភ្ញៀវទេសចរ

ដើម្បីគ្រប់គ្រងលំហូរភ្ញៀវទេសចរនៅក្នុងទីតាំង ឬកន្លែងណាមួយ ឬរមណីយដ្ឋានណាមួយ គឺមានគម្រោងផែនការនិងរបៀបគិតគូររៀបចំខុសប្លែកៗពីគ្នា ដោយយោងទៅតាមមជ្ឈដ្ឋាន បរិយាកាស ស្ថានភាពភ្ញៀវទេសចរ និងបរិស្ថានជាដើម។ ចំពោះតំបន់រមណីយដ្ឋានអង្គរ ដើម្បីអាចគ្រប់គ្រងលំហូរភ្ញៀវទេសចរ គឺបានជ្រើសរើសយកគម្រោងរៀបចំមួយចំនួនមកធ្វើការគិតគូរ មានដូចជារៀបចំនូវហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ ចំណត បន្ទប់ទឹក Welcome Center និងទីតាំងពិព័រណ៍ ជាដើម) គិតគូររៀបចំនូវខ្សែទស្សនាចរនៅតាមប្រាសាទ រៀបចំចាត់តាំងនូវកម្លាំងមន្ត្រី-បុគ្គលិកជំនាញឱ្យបំពេញការងារប្រចាំការតាមប្រាសាទ។ ការគិតគូររៀបចំទាំងអស់នេះ គឺក្នុងគោលបំណងជួយសម្រួលដល់ការទស្សនារបស់ភ្ញៀវទេសចរ និងរក្សាបាននូវសុវត្ថិភាពរបស់ប្រាសាទផងដែរ។ ក្នុងន័យគ្រប់គ្រងលំហូរភ្ញៀវទេសចរតាមប្រាសាទនេះ ក្រុមការងាររងទស្សនាចរនៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ ក៏បានគិតគូរជ្រើសរើសយកការរៀបចំខ្សែទស្សនាចរតាមប្រាសាទមកអនុវត្តន៍។

### ២.១- ការរៀបចំខ្សែទស្សនាចរតាមប្រាសាទ

ការងាររៀបចំខ្សែទស្សនាចរតាមប្រាសាទ ក្រុមការងារអនុវត្តទៅតាមផែនការមេ ហៅកាត់ថា TDP របស់អាជ្ញាធរជាតិអប្សរា និងអនុសាសន៍ណែនាំពីអ្នកជំនាញការ ICC-Angkor។ ទន្ទឹមនឹងនេះ ក្រុមការងារយើងក៏បានប្រើនូវវិធីសាស្ត្រដែលឆ្លងការអនុម័តពីអ្នកជំនាញការ ICC-Angkor តាំងពីឆ្នាំ២០២១មក ដើម្បីយកមកអនុវត្តន៍រៀបចំខ្សែទស្សនាថ្មីៗតាមប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ។ គោលបំណងក្នុងការរៀបចំខ្សែទស្សនាចរតាមប្រាសាទទាំងនេះ ដើម្បីលើកគុណតម្លៃប្រាសាទ សាសនា គ្រប់គ្រងលំហូរភ្ញៀវទេសចរ លើកទឹកចិត្តភ្ញៀវទេសចរឱ្យចំណាយពេលទស្សនាប្រាសាទកាន់តែយូរ និងបង្កើនការទស្សនាដ៏សំបូរបែបប្រកបដោយបទពិសោធន៍ល្អៗដល់ភ្ញៀវទេសចរ។ ស្របជាមួយគ្នានេះ យើងសូមលើកបង្ហាញពីវិធីសាស្ត្រក្នុងការរៀបចំខ្សែទស្សនាតាមប្រាសាទ គឺមាន៣ជំហាន។ ជំហានទី១ ជាការចុះសិក្សា ស្រាវជ្រាវ ប្រមូល និងវិភាគលើភ្ញៀវទេសចរ ហើយនឹងប្រាសាទ។ ជំហានទី២ ជាការរៀបចំដាក់ស្នើខ្សែទស្សនាថ្មីនៅតាមប្រាសាទ ព្រមទាំងធ្វើការពិគ្រោះយោបល់ ពិភាក្សាជាមួយស្ថាប័នរដ្ឋ និងឯកជន។ ជំហានទី៣ ជាការរៀបចំដាក់ស្នើ អនុវត្តន៍ខ្សែទស្សនាថ្មី ក្រោយទទួលបានការអនុម័តពីថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា និងអ្នកជំនាញការ ICC-Angkor។ បន្ទាប់ពីនេះ ក្រុមការងារសូមបង្ហាញពីការងារ និងសមិទ្ធិផលដែលទទួលបានពាក់ព័ន្ធនឹងការរៀបចំខ្សែទស្សនាចរតាមប្រាសាទមួយចំនួន ក្នុងឆ្នាំ២០២៥នេះ មានដូចជាប្រាសាទចៅស្រីវិបុល ប្រាសាទបន្ទាយសំរែ ប្រាសាទភ្នំបូកវត្តអារាមតាមដងស្ទឹងសៀមរាប និងជនពិការនៅប្រាសាទបន្ទាយស្រី។

ខាងក្រោមនេះជាការងាររៀបចំនិងសមិទ្ធផលដែលក្រុមការងារបានសម្រេចលើការរៀបចំខ្សែទស្សនាតាមប្រាសាទនាឆ្នាំ២០២៥នេះ៖

### ២.១.១- ខ្សែទស្សនាថ្មីនៅប្រាសាទចៅស្រីវិបុល

មុននឹងឈានដល់ការស្នើសុំខ្សែទស្សនាថ្មីនៅប្រាសាទនេះ ក្រុមការងារបានចុះសិក្សាប្រមូលព័ត៌មានអំពីភ្ញៀវទេសចរ ហើយទទួលបានលទ្ធផលដូចជាចំនួនភ្ញៀវទេសចរគិតជាមធ្យម៩នាក់ក្នុងមួយថ្ងៃ ហើយរយៈពេលទស្សនាចន្លោះពី៤០ ទៅ ៥០នាទី។ បន្ថែមពីនេះ ម៉ោងដែលភ្ញៀវនិយមទៅទស្សនា គឺ ១០ ដល់ ១១ ព្រឹក ហើយអាកប្បកិរិយារបស់ភ្ញៀវទេសចរកំលុងពេលទស្សនា គឺថតរូបភាព សម្រាក ស្ដាប់មគ្គុទ្ទេសក៏ពន្យល់ជាដើម។ មួយវិញទៀត ក្រុមការងារក៏ប្រមូលព័ត៌មានពីប្រាសាទទាក់ទងនឹងខ្សែទស្សនាបច្ចុប្បន្ន ចំនុចទាក់ទាញរបស់ប្រាសាទ និងផែនទីហានិភ័យ។

ខ្សែទស្សនានេះ លើកទឹកចិត្តឱ្យភ្ញៀវទេសចរចាប់ផ្ដើមការទស្សនាចូលតាមច្រកខាងលិច ដោយអាច ទស្សនាខ្លោងទ្វារខាងលិច ដែលបានជួសជុលដោយអាជ្ញាធរជាតិអប្សរាពីឆ្នាំ២០២០ដល់២០២២។ បន្តពីនេះ ភ្ញៀវទេសចរអាចឡើងភ្នំមានកម្ពស់ប្រមាណ ២០ ម៉ែត្រ ដើម្បីទៅដល់ប្រាសាទ។ ពេលដល់ប្រាសាទ ភ្ញៀវទេសចរអាចទស្សនាវត្តបុរាណមួយ ដែលមានអាយុកាលប្រមាណ ១០០ឆ្នាំមកហើយ។ បន្ទាប់មកភ្ញៀវអាចទស្សនាបរិវេណជុំវិញប្រាសាទ រួចបន្តចុះទៅផ្នែកខាងត្បូង ដើម្បីទស្សនាអគារកាកបាទ ខ្លោងទ្វារខាងត្បូង

ហើយក៏បន្តទៅទស្សនាស្រះទឹកបុរាណមួយ ដែលមានប្រវែង ៦០០ម គុណ ៤៥០ម។ ជាចុងក្រោយ ភ្ញៀវទេសចរអាចបញ្ចប់ការទស្សនាប្រាសាទតាមច្រកចេញខាងលិច ដោយត្រូវចំណាយទស្សនាប្រាសាទនេះ ប្រមាណ ៤០នាទី។










*សំណើខ្សែទស្សនាថ្មីនៅប្រាសាទចៅស្រីវិបុល*

### ២.១.២- ខ្សែទស្សនាចរថ្មីនៅប្រាសាទបន្ទាយសំរែ

ការស្នើសុំខ្សែទស្សនាថ្មីនៅប្រាសាទនេះ ក្រុមការងារបានចុះសិក្សាប្រមូលព័ត៌មានអំពីភ្ញៀវទេសចរ ហើយទទួលបានលទ្ធផលដូចជា ចំនួនភ្ញៀវទេសចរគិតជាមធ្យម ១៧០នាក់ក្នុងមួយថ្ងៃ ហើយរយៈពេល ទស្សនាចន្លោះពី២៥ ទៅ៣០នាទី។ បន្ថែមពីនេះ ម៉ោងដែលភ្ញៀវនិយមទៅទស្សនា គឺ ១០ព្រឹក ដល់ ១ រសៀល ហើយអាកប្បកិរិយារបស់ភ្ញៀវទេសចរកំលុងពេលទស្សនាគឺ ថតរូបភាព សម្រាក ជជែកគ្នា ស្តាប់មគ្គុទ្ទេសក៍ពន្យល់ជាដើម។ មួយវិញទៀត ក្រុមការងារក៏ប្រមូលព័ត៌មានពីប្រាសាទ ទាក់ទងនឹងខ្សែទស្សនាបច្ចុប្បន្ន ចំណុចទាក់ទាញ










*សំណើខ្សែទស្សនាថ្មីនៅប្រាសាទបន្ទាយសំរ៉ែ*

របស់ប្រាសាទ និងផែនទីហានិភ័យ។

ខ្សែទស្សនានេះមានរយៈពេល ៤០នាទី ដោយភ្ញៀវទេសចរអាចចាប់ផ្តើមការទស្សនានៅច្រកចូលខាងជើង ព្រោះច្រកនេះមានហេដ្ឋារចនាសម្ព័ន្ធដូចជាចំណតរថយន្ត និងបន្ទប់ទឹក។ បន្ទាប់មកភ្ញៀវទេសចរបន្តការ ទស្សនាដោយដើរតាមផ្លូវលំមានចាក់គ្រួសក្រហមចំងាយប្រមាណ៣០ម៉ែត្រដើម្បីទៅដល់មុខប្រាសាទ។ បន្ទាប់មកភ្ញៀវទេសចរបានទៅដល់កំពែងទី២ខាងក្រៅនៃច្រកខាងជើង ហើយអាចទស្សនាចម្លាក់ស្ថិតនៅលើហោជាង

ដែលបង្ហាញអំពីរឿងរាមកេរ្តិ៍ខ្មែរ ត្រង់ឈុតព្រះរាមប្រយុទ្ធជាមួយក្រុងរាពណ៍។ ភ្ញៀវទេសចរអាចបន្តការទស្សនាដោយបត់ទៅខាងឆ្វេងដៃ ដោយដើរស្របតាមកំពែងទី២ ដើម្បីចូលទៅក្នុងប្រាសាទតាមច្រកសំខាន់ គឺច្រកខាងកើត។ ពេលទៅដល់មុខខាងកើត ភ្ញៀវទេសចរអាចមើលឃើញពានហាន និងកម្រាលថ្មបាយក្រៀមដែលមានប្រវែងប្រហែល៣០០ម៉ែត្រ ហើយក៏បត់ត្រឡប់ទៅច្រកចូលប្រាសាទ នឹងបន្តដំណើរចូលទៅខាងក្នុងតាមកំពែងទី២។ មុនចូលទៅដល់ខាងក្នុងកំពែងទី១ ភ្ញៀវទេសចរអាចទស្សនានិងអាចថតរូបដ៏ស្រស់ស្អាតនៅខាងមុខច្រកចូលកំពែងទី២ រួចបន្តចូលទៅដល់ក្នុងកំពែងទី១។ ភ្ញៀវទេសចរអាចមើលឃើញចម្លាក់ដ៏ស្រស់ស្អាតស្ថិតនៅលើហោជាងស្ថិតនៅខាងឆ្វេងដៃ និយាយពីរឿងកូរសមុទ្រទឹកដោះ បន្ទាប់មកបន្តការទស្សនាទៅខាងក្នុងកំពែងទី១ ភ្ញៀវទេសចរអាចមើលប្រទះឃើញប្រអប់ថ្មបុរាណ ដែលមានរូបរាងអាចសន្និដ្ឋានបានថាម្ឈូស និងត្រូវបានជួសជុលដោយអាជ្ញាធរជាតិអប្សរានៅឆ្នាំ២០១៩។ ទន្ទឹមនឹងនេះភ្ញៀវទេសចរអាចបន្តទៅទស្សនាតួប៉មកណ្តាល ដែលអាចឃើញបណ្ណាល័យខាងត្បូង និងទស្សនាចម្លាក់ស្រស់ស្អាតដែលស្ថិតនៅហោជាងខាងលិចបង្ហាញពីសាច់រឿងរាមកេរ្តិ៍ត្រង់ឈុតនាងសីតាបញ្ជាក់ពីភាពស្មោះសរ។ បន្ទាប់មកទៀតភ្ញៀវទេសចរអាចទស្សនាទិដ្ឋភាពជុំវិញតួប៉មកណ្តាល រួចភ្ញៀវទេសចរបត់ទៅខាងស្តាំដៃ ដើម្បីអាចទស្សនាចម្លាក់នៅលើហោជាងបង្ហាញពីសាច់រឿងព្រះច័ន្ទ និងព្រះសូរិយា។ ភ្ញៀវទេសចរ

ចេញទៅច្រកខាងលិច ហើយអាចទស្សនាចម្លាក់រឿងរាមកេរ្តិ៍ ត្រង់ឈុតចម្បាំងក្រុងលង្ការ។ ភ្ញៀវទេសចរអាចបន្តស្វែងយល់ពីកំពលថ្មបាយក្រៀមច្រកខាងលិច ដែលមានចំងាយប្រហែល ៤០០ ម៉ែត្ររួចដើរស្របតាមកំពែងទី២ទៅទិសខាងជើងដើម្បីបញ្ចប់ការទស្សនា។

### ២.១.៣- ខ្សែទស្សនាចរថ្មីនៅប្រាសាទភ្នំបូក

ការស្នើសុំខ្សែទស្សនាថ្មីនៅប្រាសាទនេះ ក្រុមការងារបានចុះសិក្សាប្រមូលព័ត៌មានអំពីភ្ញៀវទេសចរ ហើយទទួលបានលទ្ធផលដូចជាចំនួនភ្ញៀវទេសចរគិតជាមធ្យម២៥នាក់ក្នុងមួយថ្ងៃ ហើយរយៈពេលទស្សនាចន្លោះពី១ ម៉ោង និង ៣០នាទី។ បន្ថែមពីនេះ ម៉ោងដែលភ្ញៀវនិយមទៅទស្សនា គឺ ៩ ដល់ ១១ ព្រឹក ហើយអាកប្បកិរិយារបស់ភ្ញៀវទេសចរអំឡុងពេលទស្សនាគឺ ថតរូបភាពសម្រាកស្រូបខ្យល់អាកាសបរិសុទ្ធពីលើកំពូលភ្នំ





ជជែកគ្នា ទស្សនាទិដ្ឋភាពជុំវិញស្តាប់មគ្គុទ្ទេសក៍ពន្យល់ជាដើម។ មួយវិញទៀត ក្រុមការងារក៏ប្រមូលព័ត៌មានពីប្រាសាទទាក់ទងនឹងខ្សែទស្សនាបច្ចុប្បន្ន



ចំនុចទាក់ទាញរបស់ប្រាសាទ និងផែនទីហានិភ័យ។

ខ្សែទស្សនានេះមានរយៈពេល១ម៉ោង៤០នាទី ដោយចាប់ផ្តើមពីចំណតជើងភ្នំ ហើយភ្ញៀវទេសចរឡើងតាមជណ្តើរ អំឡុងពេលឡើងភ្នំ ភ្ញៀវទេសចរអាចរីករាយនឹងទេសភាពភូមិស្រុក និងលំនៅឋានប្រជាជននៅក្បែរជើងភ្នំ។ ពេលឡើងដល់លើភ្នំ ភ្ញៀវទេសចរនឹងបានទស្សនាព្រះវិហារបុរាណដែលជាសំណង់ដ៏សំខាន់ត្រូវបានសាងសង់ក្នុងឆ្នាំ ១៩៦២។ បន្ទាប់មកបន្តទៅទស្សនាប្រាសាទ ទីតាំងដែលភ្ញៀវទេសចរអាចទស្សនារូបចម្លាក់ និងដើមចំប៉ីដុះលើប៉មប្រាសាទ។ បន្ទាប់មកភ្ញៀវទេសចរអាចធ្វើដំណើរចេញទៅខាងជើង ហើយបន្តទៅខាងក្រោយប្រាសាទ ដើម្បីទស្សនាចម្លាក់លិង្គដ៏ធំមួយដែលមានទម្ងន់ ១២តោន និងត្រូវបានអាជ្ញាធរជាតិអប្សរាជួសជុលឡើងវិញនៅឆ្នាំ២០២១។ បន្ទាប់មកទៀត ភ្ញៀវទេសចរអាចត្រលប់មកផ្នែកខាងត្បូងវិញ ដើម្បីទៅដល់ជណ្តើរសម្រាប់ចុះទៅចំណតរថយន្តវិញ។ ម្យ៉ាងវិញទៀត ភ្ញៀវអាចចុះតាមផ្លូវមួយទៀតនៅខាងក្រោយប្រាសាទ ប៉ុន្តែផ្លូវនេះវែងជាងជណ្តើរ។

ចំពោះខ្សែទស្សនានេះ គឺលើកទឹកចិត្តភ្ញៀវ

(Duration : 1h 40mins)

# PROPOSAL OF NEW ITINERARY OF VISIT




*សំណើខ្សែទស្សនាថ្មីនៅប្រាសាទភ្នំបូក*

(Distance : 8.0 km)

# PROPOSAL OF COMBINED ITINERARY OF VISIT




*សំណើខ្សែទស្សនាភ្ជាប់ទីតាំងទាក់ទាញនៅជុំវិញភ្នំបូក*




*សំណើខ្សែទស្សនាថ្មីនៅប្រាសាទភ្នំបូក*

ទេសចរដែលបញ្ចប់ការទស្សនាប្រាសាទបន្ទាយសំរែបន្តទៅទស្សនាភ្នំបូក និងទីតាំងទាក់ទាញផ្សេងទៀត។ ក្រោយចប់ការទស្សនានៅប្រាសាទភ្នំបូក ភ្ញៀវទេសចរអាចជ្រើសរើសខ្សែទស្សនាភ្ជាប់ពីភ្នំបូក បន្តទៅទស្សនាទំនប់តានៀវ ហើយបន្តទៅទស្សនាប្រាសាទទ ដោយត្រូវប្រើរយៈចម្ងាយប្រមាណ ៤,២ គ.ម.។

ជម្រើសខ្សែទស្សនាមួយទៀត គឺភ្ញៀវទេសចរអាចចាប់ផ្តើមពីចេញភ្នំបូក ដោយបន្តតាមគន្លងផ្លូវកៅស៊ូ ទៅប៉ែកខាងជើងប្រមាណ ៩៤០ម អាចទស្សនាប្រាសាទត្រពាំងចំបក់រួចអាច បន្តទៅទស្សនាប្រាសាទលាក់នាង ដែលមានសភាពស្រស់ស្អាតគួរជាទីគយគន់ ដែលមានរយៈចម្ងាយប្រមាណ ២,១៧០ គ.ម.។ ចុងក្រោយភ្ញៀវទេសចរអាចបញ្ចប់ការទស្សនានៅត្រឹមប្រាសាទលាក់នាង ហើយត្រឡប់មកក្រុងសៀមរាបវិញ។

### ២.១.៤- បច្ចុប្បន្នភាពខ្សែទស្សនាវត្តអារាមតាមដងស្ទឹងសៀមរាប

ការស្នើសុំរៀបចំបច្ចុប្បន្នភាពខ្សែទស្សនាវត្តតាមដងស្ទឹងនេះ ក្រុមការងារបានចុះសិក្សាអង្កេត និងរាប់ចំនួនភ្ញៀវទេសចរដោយផ្ទាល់នៅតាមទីតាំងវត្តអារាមចំនួន ៦ ដោយគិតជាមធ្យមក្នុង១ថ្ងៃ រយៈពេល៧ថ្ងៃ ហើយទទួលបានលទ្ធផលដូចជា វត្តពជបូណ៌ ១២០នាក់ វត្តថ្មី ១៥៧នាក់ វត្តកេសរារាម ៩៤នាក់ វត្តដំណាក់២៣០នាក់ វត្តព្រហ្មរ័ត្ន ១៩២នាក់ និងវត្តព្រះឥន្ទកោសីយ៍ ១០០នាក់។ សរុបជាមធ្យមភាគ ភ្ញៀវទេសចរមានប្រមាណ ១៨៣នាក់ក្នុង០១ថ្ងៃ ដោយភ្ញៀវខ្មែរ ៥៦% អាស៊ី ១២% និងផ្សេងៗ ៣២%។

ភ្ញៀវទេសចរចំណាយពេលទស្សនាប្រមាណ ២០នាទី។ បន្ថែមពីនេះ ម៉ោងដែលភ្ញៀវនិយមទៅទស្សនា គឺ៨ ព្រឹក ដល់ ៦ ល្ងាច ហើយអាកប្បកិរិយារបស់ភ្ញៀវទេសចរកំលុងពេលទស្សនាគឺ ថតរូបភាព ស្តាប់ មគ្គុទ្ទេសក៏ពន្យល់ ទស្សនាគំនូរ ទស្សនារចនាសម្ព័ន្ធវត្តអារាម ប្រគេនចង្ហាន់ព្រះសង្ឃជាដើម។ មួយវិញទៀត ក្រុមការងារក៏ប្រមូលព័ត៌មានពីវត្តអារាមទាក់ទងនឹងទីតាំងគួរទស្សនា ចំណុចសំខាន់ៗរបស់វត្តអារាមជាដើម។










សំណើខ្សែទស្សនាវត្តអារាមតាមដងស្ទឹងសៀមរាប

**១-ខ្សែទស្សនាវត្តតាមបណ្តោយស្ទឹងសៀមរាប៖** ដែលមានចម្ងាយ២គីឡូម៉ែត្រ ដោយខ្សែមួយនេះចាប់ផ្តើម ទស្សនាពីព្រះអង្គចេក ព្រះអង្គចមដែលជាទីកន្លែងសក្ការៈលេចធ្លោមួយនៅក្នុងខេត្តសៀមរាបដោយប្រជាជនខ្មែរមិនដែលរំលងឡើយជាទីកន្លែងបួងសួងសុំសេចក្តីសុខ និងបន់ស្រន់ផ្សេងៗ រួចបន្តទៅទស្សនាព្រះរាជ ដំណាក់ៗ បន្ទាប់មកភ្ញៀវទេសចរអាចទៅទស្សនាស្ទឹងសៀមរាប ដែលមានប្រភពទឹកភ្ជាប់ជាមួយស្ទឹងពួក ភ្នំគូលែន និងក្បាលស្ពាន ដែលហូរកាត់តំបន់អង្គរ។ បន្ទាប់មកភ្ញៀវទេសចរអាចបន្តទៅទស្សនាវត្តរាជបូណ៌ ជាបូជនីយដ្ឋាននិងបុរាណដ្ឋានដ៏ល្បីមួយនៅក្នុងខេត្តសៀមរាប ដោយទេសចរអាចទៅទស្សនាព្រះវិហារដែលជាមរតកវប្បធម៌ដ៏ល្អឯកមួយពោរពេញទៅដោយក្បូរក្បាច់រចនាដែលរួមមានព្រះពុទ្ធបដិមា និងរូបគំនូរ គឺសុទ្ធតែជាទីចាប់អារម្មណ៍បំផុតសម្រាប់អ្នកទេសចរ រួមទាំងទស្សនាសាលាឆាន់បុរាណមួយខ្នងដែលមានអាយុកាលប្រមាណ ៩០ឆ្នាំ ដែលទទួលបានការជួសជុលពីអាជ្ញាធរជាតិអប្សរានៅឆ្នាំ២០២១ លើសពីនោះទៀតភ្ញៀវទេសចរក៏អាចទស្សនាសារមន្ទីរដែលមានតាំងវត្ថុសិល្បៈសរុបប្រមាណ ២,៥៧៥ វត្ថុ មានអាយុកាលចាប់ពីសម័យបុរេប្រវត្តិ រហូតដល់សម័យក្រោយអង្គរ។ បន្ទាប់មកទេសចរអាចបន្តដំណើរទៅទស្សនាវត្តព្រះព្រហ្មរ័ត្នជាអារាមមួយដ៏ចំណាស់ ដែលស្ថិតនៅតាមដងស្ទឹងសៀមរាបផ្នែកខាងលិច។ ភ្ញៀវអាចទស្សនាសំណង់ព្រះវិហារដែលមានចម្លាក់ព្រះពុទ្ធចូលនិព្វាន ព្រមទាំងសំណង់កុដិឈើពីរខ្នង សង់ខ្ពស់ផុតពីដី ដំបូលប្រក់ក្បឿង ដែលមានទម្រង់ស្ថាបត្យកម្មពីរផ្សេងគ្នា មួយជាទម្រង់កុដិដំបូលកឹង និងមួយទៀតជាទម្រង់កុដិបុិត។

(Option 2 : Distance : 2 Km, Duration : Half Day)

## COMBINED ITINERARY FOR VISITING PAGODAS AND ANCIENT TEMPLE




**២- ខ្សែទស្សនាភ្ជាប់វត្ត និងប្រាសាទ៖** ដែលមានចម្ងាយ២គីឡូម៉ែត្រ ដោយខ្សែមួយនេះចាប់ផ្តើមទស្សនាពីព្រះអង្គចេក ព្រះអង្គចមដូចទៅនឹងខ្សែទស្សនាទី១ដែរ បន្ថែមពីនោះ ភ្ញៀវអាចបន្តទៅទស្សនាវត្តកេសរារាម ជាកន្លែងដ៏ទាក់ទាញមួយក្នុងខេត្តសៀមរាប។ វាជាកន្លែងដែលមានភាពស្រស់ស្អាត និងមានប្រវត្តិដ៏ជ្រាលជ្រៅ។ វត្តនេះជាសំណង់ដ៏រស់រវើក និងចម្រុះពណ៌ជាមួយនឹងផ្ទាំងគំនូរ និងរូបចម្លាក់ដ៏អស្ចារ្យ។ ជាងនេះទៅទៀតទីតាំងនេះមានស្តូបរក្សាទុកអដ្ឋិធាតុជនរងគ្រោះ

ក្នុងរបបខ្មែរក្រហម ដែលធ្វើឱ្យវាក្លាយជាកន្លែងចងចាំផងដែរ។ បន្ទាប់មក ភ្ញៀវទេសចរអាចបន្តទៅទស្សនាវត្តព្រះឥន្ទ្រកោសីយ៍ ដែលជាកន្លែងចម្រុះដ៏គួរឱ្យចាប់អារម្មណ៍នៃមរតកវិញ្ញាណបុរាណ និងសម័យទំនើបរបស់កម្ពុជា។ ភ្ញៀវអាចមើលឃើញវត្តព្រះពុទ្ធសាសនា និងប្រាសាទបុរាណខ្មែរដែលត្រូវបានកសាងឡើងក្នុងសតវត្សទី ១០ ក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័នទី២ ដើម្បីឧទ្ទិសដល់ព្រហ្មញ្ញសាសនា។

ខ្សែទស្សនានេះមិនត្រឹមតែឱ្យភ្ញៀវទេសចរយល់ដឹងពីសំណង់ស្ថាបត្យកម្មរបស់វត្តទេ ថែមទាំងដើម្បីយល់ដឹងពីជំនឿ និងការគោរពបូជារបស់ប្រជាជនខ្មែរទៅលើព្រះពុទ្ធសាសនាផងដែរ។

### ២.១.៥- បច្ចុប្បន្នភាពខ្សែទស្សនាជនពិការនៅប្រាសាទបន្ទាយស្រី

ការស្នើសុំរៀបចំបច្ចុប្បន្នភាពខ្សែទស្សនាជនពិការនៅប្រាសាទបន្ទាយស្រីនេះ ក្រុមការងារបានចុះសិក្សាអង្កេត ប្រមូលព័ត៌មាន និងរាប់ចំនួនភ្ញៀវទេសចរដែលប្រើរទេះរុញ រទេះរុញកុមារ និងមនុស្សចាស់។ ការចុះសិក្សារៀបចំខ្សែទស្សនាសម្រាប់ជនពិការនេះ គឺយោងទៅតាមអនុសាសន៍ណែនាំរបស់ ICC-Expert កាលពីឆ្នាំ២០២៤ ដោយស្នើឱ្យក្រុមការងារបច្ចេកទេសរៀបចំខ្សែទស្សនា ធ្វើការគិតគូរពីខ្សែទស្សនាតាមប្រធានបទ ព្រមទាំងខ្សែទស្សនាសម្រាប់ជនពិការភាព និងមនុស្សជាដើម។ ស្របតាមអនុសាសន៍ណែនាំរបស់ ICC-Expert ក្រុមការងារជំនាញបានជ្រើសរើសយកប្រាសាទបន្ទាយស្រីមកសិក្សារៀបចំជា Pilot Project ជំហានដំបូងគេ។ ចំពោះទិន្នន័យភ្ញៀវទេសចរជនពិការនៅប្រាសាទបន្ទាយស្រី ក្នុងឆ្នាំ២០១០ ដល់ ២០១១ គិតជាមធ្យមក្នុង១ខែ គឺ ៧នាក់ ហើយក្នុងឆ្នាំ២០២៣ មានភ្ញៀវទេសចរជាមនុស្សចាស់ និងជនពិការប្រមាណ ១១នាក់ និងរទេះរុញកុមារ ២៥នាក់ គិតជាមធ្យមក្នុង១ខែ។ ក្នុងឆ្នាំ២០២៤ គឺភ្ញៀវមនុស្សចាស់និងជនពិការមានប្រមាណ ១៩នាក់ និងរទេះរុញកុមារ ៣៨នាក់ គិតជាមធ្យមក្នុង១ខែ។ អាកប្បកិរិយារបស់ភ្ញៀវទេសចរជនពិការ មនុស្សចាស់ និងរទេះរុញ គឺចូលចិត្តទស្សនាទិដ្ឋភាពប្រាសាទ ថតរូបភាព និងមើលចម្លាក់រឿង។ មួយវិញទៀត ក្រុមការងារក៏ប្រមូលព័ត៌មានពីប្រាសាទទាក់ទងនឹងខ្សែទស្សនាបច្ចុប្បន្ន ចំនុចទាក់ទាញរបស់ប្រាសាទ និងផែនទីហានិភ័យ។







## ខ្សែទស្សនាសម្រាប់ជនពិការ ដែលប្រើរយៈពេល២ម៉ោង និង២០នាទី




សំណើរៀបចំបច្ចុប្បន្នភាពខ្សែទស្សនាជនពិការនៅប្រាសាទបន្ទាយស្រី


## ខ្សែទស្សនាសម្រាប់ជនពិការ ដែលប្រើរយៈពេល២ម៉ោង និង២០នាទី





ខ្សែទស្សនានេះ សម្រាប់ជនពិការ រទេះរុញ កូនក្មេង និងចាស់ជរា ដែលត្រូវបានចាប់ផ្ដើមពី មជ្ឈមណ្ឌលស្វាគមន៍ ជាកន្លែងដែលភ្ញៀវទេសចរ អាចទទួលបានព័ត៌មានមូលដ្ឋាន។ ប្រសិនបើអ្នកទស្សនាចង់ស្វែងយល់អំពីប្រាសាទមុននឹងទៅដល់ប្រាសាទផ្ទាល់ គឺភ្ញៀវទេសចរអាចបន្តទៅទស្សនា មជ្ឈមណ្ឌលតាំងពិព័រណ៍ ជាកន្លែងដែលអ្នកទស្សនា អាចទទួលបានព័ត៌មានត្រឹមត្រូវ ដោយសារមជ្ឈមណ្ឌលនេះផ្ដល់ព័ត៌មានលើ៤ប្រធានបទសំខាន់ៗដូចជា ប្រវត្តិសាស្ត្រទំនើប ស្ថាបត្យកម្ម រចនាបថ និងសាសនា។ ក្រោយទស្សនាមជ្ឈមណ្ឌលពិព័រណ៍រួច ភ្ញៀវទេសចរ អាចចាប់ផ្ដើមទៅទស្សនាប្រាសាទតាមច្រកចូល ខាងកើត នៃកំពែងទី៤ ដែលមានចម្លាក់រឿងនៅលើផ្តែរ ហើយក៏បន្តការទស្សនាតាមច្រកចូលថ្មី ស្ថិតនៅខាងជើងជាប់នឹងច្រកចូលសំខាន់ រួចដើរបន្តទៅកាន់អគារវែងដែលមានចម្លាក់រឿង អវតារ

ទី៤នៃព្រះវិស្ណុ។

បន្ទាប់ពីទស្សនាចម្លាក់រឿង នរសិង្ហ ភ្ញៀវទេសចរអាចទស្សនាចម្លាក់រឿងលើហោជាង នៅផ្ទាល់ដីពីមុខខាងជើងនៃច្រកចូលកំពែងទី៣ និងអាចទស្សនាបន្ថែមលើផ្ទាំងសិលាចារឹក រួចដើរត្រឡប់ដើម្បីបន្តទៅកាន់ពានទស្សនាប៉ែកខាងជើងប្រាសាទ ដែលមានបង្ហាញពីទិដ្ឋភាពធម្មជាតិ និងបរិវេណប្រាសាទខាងក្នុង។ បន្ទាប់មកភ្ញៀវទេសចរអាចឆ្ពោះទៅកាន់ច្រកខាងលិច ដើម្បីស្តាប់ភ្លេងរបស់ក្រុមតន្ត្រីជនពិការដោយសារគ្រាប់មីន និងទស្សនាទិដ្ឋភាពប្រាសាទពីខាងក្រោយប្រាសាទ។ កំលុងពេលចាកចេញពីប្រាសាទ ភ្ញៀវទេសចរអាចគយគន់ទិដ្ឋភាពប្រាសាទពីជ្រុងចំហៀង និងដើរទៅទិសខាងត្បូង រួចបញ្ចប់ការទស្សនានៅចំណត។

ខ្សែទស្សនានេះ ចំណាយពេលទស្សនាប្រមាណ ២ ម៉ោង និង ២០នាទី។

**២.២- ការរៀបចំហេដ្ឋារចនាសម្ព័ន្ធនិងបរិក្ខារ**

ការរៀបចំខ្សែទស្សនាតាមប្រាសាទ ក្រុមការងារបច្ចេកទេសនៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ បានធ្វើការរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដូចជាជណ្តើរ បង្កោលរបា កម្រាលផ្លូវដើរ និងខ្សែរបា។ ទន្ទឹមនឹងនេះ ក៏មានរៀបចំជាបរិក្ខារចាំបាច់ ដូចជាផ្ទាំងព័ត៌មានប្រវត្តិសាស្ត្រប្រាសាទ ចម្លាក់រឿង ចំណុច ទស្សនារបស់ប្រាសាទ សត្វ រុក្ខជាតិ និងខ្សែទស្សនា។ ការរៀបចំទាំងនេះ មានគោលបំណងសម្រួលការ ទស្សនាដល់ភ្ញៀវទេសចរ និងអនុវត្តខ្សែទស្សនាថ្មីតាមប្រាសាទផងដែរ។










## ៣- សេចក្តីសន្និដ្ឋាន

រមណីយដ្ឋានអង្គរជាអត្តិភាពបេតិកភណ្ឌពិភពលោក ដែលតម្រូវឱ្យមានការគ្រប់គ្រងលំហូរភ្ញៀវដ៏មានប្រសិទ្ធភាព ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន (ដូចជាការខូចសំណង់បុរាណឬការបំពុល) កែលម្អបទពិសោធទេសចរណ៍និងធានាសុវត្ថិភាពដល់ភ្ញៀវទេសចរ។ បញ្ហាប្រឈមពេលមានលំហូរភ្ញៀវទេសចរកើនឡើង ជាពិសេសរដូវកាលមាន

ភ្ញៀវច្រើន ដែលបណ្តាលឱ្យមានការប្រមូលផ្តុំនៅតំបន់ពេញនិយម ដូចជាប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ប្រាសាទតាព្រហ្ម ប្រាសាទបន្ទាយស្រី ប្រាសាទនាគព័ន្ធ និងប្រាសាទភ្នំបាខែង។ ដើម្បីធ្វើឱ្យការគ្រប់គ្រងលំហូរអាចមានភាពល្អប្រសើរ អាជ្ញាធរជាតិអប្សរា និងអ្នកពាក់ព័ន្ធក៏ពិភាក្សារកដំណោះស្រាយមួយចំនួន រួមមានការរៀបចំឱ្យមានប្រព័ន្ធបញ្ជាទិញសំបុត្រអនឡាញ កម្មវិធីតាមទូរសព្ទដៃ (Visit Angkor Application) ការកំណត់អាទិភាពសម្រាប់ភ្ញៀវទេសចរក្រុម និងការបែងចែកពេលវេលាទស្សនាជាដើម។ បន្ថែមពីនេះ ក៏មានការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរឱ្យមានគុណភាព និងលើកកម្ពស់ការចូលរួមរបស់អ្នកភូមិក្នុងការបញ្ចេញមតិយោបល់ផងដែរ។

ការស្រាវជ្រាវបញ្ជាក់ថា ការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងលំហូរភ្ញៀវទេសចរដោយផ្អែកលើ ចីរភាព និងយុត្តិធម៌សង្គម អាចជួយរក្សាតម្លៃបេតិកភណ្ឌអង្គរ និងជានាប្រយោជន៍ដល់អ្នកភូមិ និងវិស័យទេសចរណ៍ជាយថាហេតុ។ យ៉ាងណាមិញ ការគិតគូររៀបចំខ្សែទស្សនាចរតាមប្រាសាទ ក៏ជាផ្នែកមួយដែលចូលរួមគ្រប់គ្រងលំហូរភ្ញៀវទេសចរក្នុងតំបន់អង្គរផងដែរ។ ការរៀបចំខ្សែទស្សនាចរតាមប្រាសាទបានជួយសម្រួលដល់ការគ្រប់គ្រងលំហូរភ្ញៀវទេសចរមួយចំនួនផងដែរ ដោយអាចផ្តល់ឱ្យភ្ញៀវទេសចរទទួលបាននូវសុវត្ថិភាព គុណភាពក្នុងការទស្សនាប្រាសាទ និងចំណេះដឹងបន្ថែមទាក់ទងនឹងប្រាសាទរចនាបថជំនឿនិងសាសនាទៀតផង។ ទន្ទឹមនឹងនេះ ការងារស្រាវជ្រាវក៏បានផ្តល់ឱកាសឱ្យយើងប្រមូលបាននូវទិន្នន័យភ្ញៀវទេសចរត្រឹមត្រូវ ច្បាស់លាស់ដែលចេញ និងចូលទស្សនាប្រាសាទ និងអាចកំណត់ទីតាំងកកស្ទះក្នុងប្រាសាទព្រមទាំងអាចបញ្ចៀសនូវការកកស្ទះភ្ញៀវទេសចរជាដើម។

សរុបមក ការគ្រប់គ្រងលំហូរភ្ញៀវទេសចរនៅរមណីយដ្ឋានអង្គរ ទាមទារឱ្យមានការសហការរួមគ្នាពីគ្រប់ភាគីពាក់ព័ន្ធដោយផ្តោតលើវិធានការបច្ចេកវិទ្យា នីតិវិធី និងការចូលរួមពីសហគមន៍។ ដំណោះស្រាយដែលមានភាពវែកញែក និងស៊ីជម្រៅនឹងជួយធានាអត្ថិភាពយូរអង្វែងរបស់រមណីយដ្ឋានអង្គរនេះ។

## សកម្មភាពនិងការរៀបចំខ្សែទស្សនាតាមប្រាសាទដើម្បីគ្រប់គ្រងលំហូរភ្ញៀវទេសចរ























# របាយការណ៍សង្ខេបស្តីពីកិច្ចគាំពារបេតិកភណ្ឌរូបីនិងអរូបី របស់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកណ្តាល

## ១-កិច្ចគាំពារបេតិកភណ្ឌវប្បធម៌រូបី

- បានចុះប្រគល់ទទួលវត្ថុបុរាណ រួមមាន៖

• សិលាចារឹក ១ផ្ទាំងនៅស្រុកអង្គស្នួល រក្សាទុកនៅមន្ទីរ

• ព្រះបដិមាលោហៈ២អង្គ និងកោដិពីដីដុត ១វត្ថុ នៅស្រុកខ្សាច់កណ្តាល រក្សាទុកនៅមន្ទីរ។





- បានសហការចុះពិនិត្យនិងផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌវត្ថុបុរាណក្រៅឃ្លាំង រួមមាន៖

• នៅលើទួលបុរាណ ក្នុងឃុំស៊ីធរ ស្រុកខ្សាច់កណ្តាល ចំនួន៥៧វត្ថុ

• នៅសារមន្ទីរស្រែអំពិល ឃុំឈើទាល ស្រុកកៀនស្វាយ ចំនួន ១២៨វត្ថុ

• នៅវត្តព្រះនាគ ឃុំធក់ឈើនាង ស្រុកអង្គស្នួល ចំនួន១៣៨វត្ថុ លើចំនួន១៥២វត្ថុ ក្នុងបញ្ជីឆ្នាំ២០១៦ ដោយវត្ថុមួយចំនួនបានបាត់រូបរាងលុបលេខ និងចុះលេខស្ទួន

• នៅវត្តអម្ពររង្សី ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ចំនួន ៧វត្ថុ ដូចក្នុងបញ្ជីឆ្នាំ២០២២។













- បានចុះបញ្ជីវត្ថុបុរាណក្រៅឃ្លាំង រួមមាន ៖
    - នៅតាមទួលបុរាណក្នុងឃុំស៊ីធរ ស្រុកខ្សាច់កណ្ដាល ចំនួន ១១វត្ថុ
    - នៅវត្តព្រះវិហារសួគ៌ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ចំនួន ១២វត្ថុ









- បានធ្វើការបោសសម្អាត អនាម័យ និងសោភណភាព នៅព្រះសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យស្រុកពញាឮ ។













- បានចូលរួមចុះវាស់វែងធ្វើប្លង់កម្មសិទ្ធិស្ថានីយបុរាណ( ដីរដ្ឋ) ក្នុងក្រុង/ស្រុក ចំនួន៩ បានចំនួន ១២៣ស្ថានីយបុរាណ។

- បានចុះពិនិត្យ និងចុះបញ្ជីស្ថានីយបុរាណរកឃើញថ្មី ចំនួន១១លើក មាន២១ស្ថានីយបុរាណ។

-បានចុះបោះបង្គោលសម្គាល់ស្ថានីយបុរាណទួលថ្ម ក្នុងសង្កាត់សំពៅពូន ក្រុងសំពៅពូន ចំនួន ៧បង្គោល។

- បានចុះពិនិត្យនិងបញ្ឈប់ការស្តារស្រះទឹក និងចាក់ដីនៅស្ថានីយបុរាណ ទួលយាយក្រប៊ី ស្ថិតក្នុងភូមិព្រែកស្វាយ២ ឃុំឈើទាល ស្រុកកៀនស្វាយ។







-បានរៀបចំពិធីផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ ក្រោមប្រធានបទ«យុវជនដើម្បីបេតិកភណ្ឌជាតិ» នៅវិទ្យាល័យ ហ៊ុន សែន សេរីភាព ក្រុងតាខ្មៅ ដោយមានការចូលរួមពីលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស ចំនួន ១០៦នាក់ ស្រី ៥០នាក់។









## ២- កិច្ចគាំពារបេតិកភណ្ឌវប្បធម៌អរូបី

-បាននិងកំពុងបន្តបង្ហាត់របាំសិស្សថ្នាលថ្មីចំនួន ១០០នាក់ ស្រី៨៥នាក់ រៀងរាល់ថ្ងៃអាទិត្យ។ បានដឹកនាំក្រុមរបាំជូនពរ និងឆៃយ៉ាំ ចេញសម្តែង ចំនួន ១៣លើក។





- បានប្រារព្ធមិទ្ទីងអបអរសាទរទិវាវប្បធម៌ជាតិ ៣ មីនា លើកទី២៦ ឆ្នាំ២០២៤ ក្រោមប្រធានបទ "យុវជន ដើម្បីវប្បធម៌ជាតិ" នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ នៅសាលប្រជុំ មជ្ឈមណ្ឌលគរុកោសល្យ ភូមិភាគ ហ៊ុន សែន ខេត្តកណ្ដាល (ក្រុងតាខ្មៅ) ក្រោមអធិបតីភាព ឯកឧត្តមអភិបាលនៃគណៈ អភិបាលខេត្ត វត្តមានចូលរួមចំនួន ៤០០នាក់ ស្រី ២៥៥នាក់ ។









- បានសហការរៀបចំពិធីសង្ក្រាន្ត នៅក្រុងតាខ្មៅ អបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ដោយមានការរៀបចំ រូបសំណាកនាគ, ពិធីបើកព្រឹត្តិការណ៍សង្ក្រាន្ត មានការ សម្តែងសិល្បៈចំនួន ១០ផែន, ការលេងល្បែងប្រជាប្រិយ តន្ត្រីស្តរដី, ទស្សនីយភាពល្ខោនបាសាក់, ពិធីសាសនា និងបណ្តែតប្រទីប។







- បានរៀបចំមហោស្រពសិល្បៈមហាជនចម្រុះខេត្តកណ្តាល លើកទី៦ ឆ្នាំ២០២៤ ថ្ងៃទី១៩-២០ ខែកញ្ញា ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្តាល ក្រោមអធិបតីភាព លោក នុត ពុធដារ៉ា អភិបាលរងខេត្ត តំណាងដ៏អភិបាលនៃគណៈអភិបាលខេត្ត សរុបវត្តមាន ២៦០នាក់ ស្រី១៤៥នាក់ ។
















- បានបើកសិក្ខាសាលាស្តីពីចម្លាក់ខ្មែរ នៅមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកណ្ដាល ដែលមានសិក្ខាកាមចូលរួម ចំនួន៧០នាក់ ស្រី១០នាក់។





-បានបង្ហាត់បង្រៀនចម្លាក់ខ្មែរដល់សិក្ខាកាមចំនួន១១នាក់ នៅរៀងរាល់ថ្ងៃសុក្រ។









-បានចូលរួមនិងសិក្សាស្វែងយល់អំពីការរៀបចំពិធីបុណ្យភ្ជុំបិណ្ឌ នៅវត្តព្រះវិហារសួគ៌ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ដោយមានកម្មវិធីបំបោលសេះ ១២គូ, បំបោលក្របី ១៥គូ, បោកចំបាប់ ៤៧គូ និងប្រណាំងទូក ៣គូ។









- បានសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យ និងបញ្ជ្រាបការយល់ដឹងអំពីវប្បធម៌ សីលធម៌សង្គម ការជួញដូរមនុស្សផ្លូវភេទ ការប្រើប្រាស់គ្រឿងញៀន និងការរំលោភសិទ្ធិស្ត្រីនិងកុមារ ដល់ទីតាំងអាហារដ្ឋាន KTV ចំនួន ៣៥ទីតាំង ក្នុងក្រុង/ស្រុកចំនួន១៣ ដោយមានអ្នកចូលរួមសរុប ៨០៩នាក់ ស្រី ៥៩២នាក់។





-បានសហការជាមួយនាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងអាជ្ញាធរមូលដ្ឋាន ចាក់បញ្ចាំងភាពយន្តក្នុងកម្មវិធីដំណើរភាពយន្តចល័តកម្ពុជា-ចិនដំ ផ្ទើម លើកទី៨ ឆ្នាំ២០២៤ នៅតាមទីតាំងចំនួន ៦ ក្នុងស្រុកកណ្ដាលស្ទឹង, ខ្សាច់កណ្ដាល, ស្អាង និង ក្រុងតាខ្មៅ មានអ្នកចូលរួមប្រមាណ ២០០០នាក់។








## ជំពូកទី៣

# សកម្មភាព, ព្រឹត្តិការណ៍



# ព្រឹត្តិការណ៍មហោស្រពចាប៉ីដងវែងទូទាំងប្រទេសឆ្នាំ២០២៥




មហោស្រពចាប៉ីដងវែងទូទាំងប្រទេសឆ្នាំ២០២៥ក្រោមប្រធានបទ «ទំពាំងស្នងឫស្សី» បានប្រារព្ធពិធីបើកនាថ្ងៃទី១១ និងបិទនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៥ ក្រោមអធិបតីភាព ឯកឧត្តម **ហាប់ ទូច** រដ្ឋលេខាធិការប្រចាំការ តំណាងលោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។



ឯកឧត្តម **ហាប់ ទូច** រដ្ឋលេខាធិការប្រចាំការ
ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

មហោស្រពចាប៉ីដងវែង ធ្វើឡើងក្នុងគោលបំណងថែរក្សា ការពារ និងលើកស្ទួយទម្រង់សិល្បៈចាប៉ីដងវែង ដែលជាមរតកវប្បធម៌ជាតិដ៏មានតម្លៃពុំអាចកាត់ថ្លៃបាន។ ជាលទ្ធផល យើងបានរកឃើញបេក្ខជនឆ្នើមចំនួន៣រូប ដែលទទួលបានជ័យលាភីក្នុងវគ្គផ្តាច់ព្រ័ត្រ ក្នុងនោះ៖

- លោក ម៉ុ មឿន មកពីខេត្តសៀមរាប ជយលាភីលេខ១ ទទួលបានពានចាប៉ីមាស អមដោយប្រាក់រង្វាន់។
- លោក វណ្ណា គឹមស៊ាន មកពីខេត្តសៀមរាប ជយលាភីលេខ២ ទទួលបានពានចាប៉ីប្រាក់ អមដោយប្រាក់រង្វាន់។
- លោក កែវ ពិសាល មកពីខេត្តកំពង់ឆ្នាំង ជយលាភីលេខ៣ ទទួលបានពានចាប៉ីសំរិទ្ធ អមដោយប្រាក់រង្វាន់។



លោក ម៉ើ មឿន មកពីខេត្តសៀមរាប ជយលាភីលេខ១





លោក វណ្ណា គឹមស៊ាន មកពីខេត្តសៀមរាប ជយលាភីលេខ២





លោក កែវ ពិសាល  មកពីខេត្តកំពង់ឆ្នាំង ជយលាភីលេខ៣





• ចំណែកបេក្ខជន២រូបទៀត គឺលោក ចាប ជី មកពីខេត្តសៀមរាប និងលោក ម៉ម ភិរក្ស មកពីខេត្តប៉ៃលិន ទទួលបានចំណាត់ថ្នាក់កិត្តិយស ទទួលបានប្រកាសនីយបត្រ និងប្រាក់រង្វាន់លើកទឹកចិត្ត៕

# ជោគជ័យដ៏ត្រចះត្រចង់នៃ មហោស្រពល្ខោនយីកេឆ្នាំ២០២៥ ក្រោមប្រធានបទ"គុណធម៌និងកតញ្ញូ"




រាជធានីភ្នំពេញ៖ សាលសន្និសីទចតុម្មុខ ពោរពេញទៅដោយសំឡេង និងទស្សនីយភាពដ៏រស់រវើកនៃសិល្បៈបុរាណខ្មែរ កាលពីចុងខែវិច្ឆិកាកន្លងទៅនេះ ខណៈដែល មហោស្រពល្ខោនយីកេទូទាំងប្រទេសឆ្នាំ២០២៥ បានបញ្ចប់ទៅដោយជោគជ័យ និងមានការគាំទ្រយ៉ាងខ្លាំងក្លា។

មហោស្រពយីកេ បានប្រារព្ធឡើងរយៈពេល ៤ថ្ងៃ ចាប់ពីថ្ងៃទី២០ ដល់ទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ក្រោមប្រធានបទ"គុណធម៌និងកតញ្ញូ" មហោស្រពនេះត្រូវបានរៀបចំឡើងដោយនាយកដ្ឋានសិល្បៈទស្សនីយភាព អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីលើកស្ទួយ និងថែរក្សាមរតកសិល្បៈដូនតា។

ម្ចាស់ជយលាភីមកពីបណ្តាខេត្ត ឆ្លងកាត់ការជម្រុះយ៉ាងសម្រិតសម្រាំងពីបណ្តាខេត្តចំនួន៧។ ក្រុមសិល្បៈឆ្នើមចំនួន៥ ត្រូវបានជ្រើសរើសសម្រាប់ការប្រកួតវគ្គផ្តាច់ព្រ័ត្រ។ ជាលទ្ធផល៖

- ជយលាភីលេខ១៖ បានទៅលើ ក្រុមខ្ញុំស្រលាញ់វប្បធម៌នៃស.ស.យ.ក. មកពីខេត្តកំពង់ស្ពឺ។
- ជយលាភីលេខ២៖ បានទៅលើ ក្រុមរស្មីអូរក្រសារ មកពីខេត្តកែប។
- ជយលាភីលេខ៣៖ បានទៅលើ ក្រុមសាមុតមកពីខេត្តបន្ទាយមានជ័យ។





សិល្បៈបុរាណក្នុងសម័យឌីជីថល ចំណុចពិសេសនៃមហោស្រពឆ្នាំ២០២៥គឺការផ្សព្វផ្សាយយ៉ាងទូលំទូលាយ។ ក្រៅពីអ្នកចូលទស្សនាផ្ទាល់ជាង៥០០នាក់ក្នុងមួយថ្ងៃ ការផ្សាយផ្ទាល់តាមរយៈកិច្ចសហការជាមួយ AMS និងផេកផ្លូវការរបស់ក្រសួងទទួលបានអ្នកទស្សនារាប់សែននាក់។ ជាពិសេសនៅថ្ងៃទី២២ ខែវិច្ឆិកា ផេក AMS ទទួលបានការចូលទស្សនារហូតដល់ ១៩៥ ០០០ដង បូករួមនឹង ៦០.០០០ដងទៀត ពីបណ្តាញផេកផ្លូវការរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។



ព្រឹត្តិការណ៍នេះ បង្ហាញឱ្យឃើញថា "ល្ខោនយីកេ"នៅតែមានឥទ្ធិពលនិងប្រជាប្រិយភាព ទទួលបានការស្រលាញ់ពេញចិត្តពីសំណាក់ប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈ។







ព្រឹត្តិការណ៍នេះបានបិទបញ្ចប់ក្រោមអធិបតីភាព ឯកឧត្តម **ហាប់ ទូច** រដ្ឋមន្ត្រីស្តីទីនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលបានកត់សម្គាល់នូវភាពជោគជ័យនិងការសាទរយ៉ាងក្រៃលែងចំពោះការរៀបចំនេះ។

# ពិធីបើកឆ្នាំទេសចរណ៍កម្ពុជា-ចិនឆ្នាំ២០២៥



*រាជធានីភ្នំពេញ៖ នារាត្រីថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំម្សាញ់ ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៥ សិល្បករ សិល្បការិនី នាយកដ្ឋានសិល្បៈទស្សនីយភាព និងសិល្បករ សិល្បការិនី ខេត្តជាំងស៊ូ នៃសាធារណរដ្ឋប្រជាមានិតចិន បានសម្តែងទស្សនីយភាពសិល្បៈចម្រុះរួមគ្នា ក្នុងពិធីបើក «ឆ្នាំទេសចរណ៍ កម្ពុជា-ចិន ២០២៥» អមដោយការសម្តែងសិល្បៈពិសេស «សម្រស់កម្ពុជា-ជាំងស៊ូ» ក្រោមអធិបតីភាពឯកឧត្តម* **វង្សី វិស្សុត** *ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី* **ហ៊ុន ម៉ាណែត** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម* ***XU KUN LIN*** *អភិបាលខេត្តជាំងស៊ូ នៃសាធារណរដ្ឋប្រជាមានិតចិន ឯកឧត្តម* **វ៉ាង វិនពីន** *ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃស្ថានទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម* **ហួត ហាក់** *រដ្ឋមន្ត្រីក្រសួងទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត-រដ្ឋទូត ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំអន្តរក្រសួង ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ បណ្តាអង្គភាពសារព័ត៌មានជាតិ-អន្តរជាតិ និង អ្នកផលិតមាតិកាជាច្រើនរូបទៀត។*





# ការសម្ដែងសិល្បៈក្នុងពិធីបើកនិងបិទពិព័រណ៍កម្ពុជា នៅប្រទេសជប៉ុនលើកទី៩ ឆ្នាំ២០២៥

ក្រុងតូក្យូ៖ កាលពីថ្ងៃទី ៣ ដល់ ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៥ សិល្បករ សិល្បការិនី នៃនាយកដ្ឋានសិល្បៈទស្សនីយភាពនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានចូលរួមសម្ដែងកម្មវិធីបើក និងបិទពិព័រណ៍កម្ពុជានៅប្រទេសជប៉ុន ដែលប្រារព្ធធ្វើឡើងនៅទីលាន YOYOGI PARK ទីក្រុងតូក្យូ ប្រទេសជប៉ុន។



ព្រឹត្តិការណ៍វប្បធម៌ដ៏មានសារៈសំខាន់នេះ ប្រព្រឹត្តិទៅក្រោមអធិបតីយភាព ឯកឧត្តម **ទុយ រី** ឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅប្រទេសជប៉ុន ឯកឧត្តម ***MIYAJI TAKUMA*** អនុរដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន ឯកឧត្តម ***IMAMURA MASAHIRO*** អតីតប្រធានសហព័ន្ធមិត្តភាពជប៉ុនកម្ពុជា និង ជាទីប្រឹក្សាសម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សមាគមនិស្សិតប្រចាំនៅប្រទេសជប៉ុន និងទស្សនិកជនចូលរួមពិធីបើកប្រមាណជាង ៥ ម៉ឺននាក់ និងកម្មវិធីបិទប្រមាណជិត១០ ម៉ឺននាក់។





# ព្រឹត្តិការណ៍បុណ្យទន្លេលើកទី៩ ឆ្នាំ២០២៥ នៅខេត្តតាកែវ



ក្រុងដូនកែវ ខេត្តតាកែវ៖ នារាត្រីថ្ងៃសៅរ៍ ៩រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៥ សិល្បករ សិល្បការិនីនៃនាយកដ្ឋានសិល្បៈទស្សនីយភាពនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានបង្ហាញផ្ទាំងទស្សនីយភាពរបាំទំនើបចម្រុះ «ទន្លេមេបុណ្យ» និងល្ខោនយីកេ «រឿងប្រវត្តិភ្នំបុរី» ដើម្បីចូលរួមអបអរសាទរក្នុងព្រឹត្តិការណ៍ «បុណ្យទន្លេលើកទី៩» ឆ្នាំ២០២៥ ក្រោមប្រធានបទ «គុណតម្លៃនៃទន្លេផ្សារភ្ជាប់វប្បធម៌និងទេសចរណ៍ធម្មជាតិ» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ក្រៅពីនេះ ក៏មានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម **ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឯកឧត្តម **ឌី សំណាង** អភិបាលនៃគណៈអភិបាលខេត្តតាកែវ ឯកឧត្តម លោកជំទាវ គណៈកម្មការអន្តរក្រសួងរៀបចំព្រឹត្តិការណ៍បុណ្យទន្លេ ថ្នាក់ដឹកនាំក្រសួងស្ថាប័នពាក់ព័ន្ធ លោកលោកស្រី មន្ត្រីរាជការនៃមន្ទីរអង្គភាពជុំវិញខេត្ត វិស័យឯកជន សាធារណជនជាតិ និងអន្តរជាតិជាច្រើនរូបទៀត។






# ការសម្ដែងល្ខោនបាមោជ្ជទ័យ រឿងកុលាបប៉ៃលិន នៅ សាលសន្និសីទចតុម្មុខ







រាជធានីភ្នំពេញ៖ នាល្ងាចព្រហស្បតិ៍ ១០រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥ សិល្បករ សិល្បការិនី នាយកដ្ឋានសិល្បៈទស្សនីយភាព នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានសម្ដែងទស្សនីយភាពល្ខោនបាមោជ្ជទ័យ រឿង“កុលាបប៉ៃលិន” ជូនថ្នាក់ដឹកនាំ និងសាធារណជនទស្សនា នៅសាលសន្និសីទចតុម្មុខ។

ព្រឹត្តិការណ៍វប្បធម៌ដ៏កម្រ អមដោយពិព័រណ៍សិប្បកម្មខ្មែរមួយនេះ ប្រព្រឹត្តិទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងវត្តមាន ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា និងភ្ញៀវកិត្តិយសជាច្រើនរូបទៀត។

# អធិបតីក្នុងពិធីសម្ពោធពិព័រណ៍«ស្នាដៃមរតកមនុស្សរស់»



នាព្រឹកថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៥ នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌នៃ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានរៀបចំពិធីបើកពិព័រណ៍ “ស្នាដៃមរតកមនុស្សរស់”។ ពិធីនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **ហាប់ ទូច** រដ្ឋលេខាធិការប្រចាំការ និងជាតំណាងដ៏ខ្ពង់ខ្ពស់ លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយមានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំ ព្រឹទ្ធាចារ្យសិល្បៈមរតកមនុស្សរស់ ភ្ញៀវកិត្តិយស និងសិស្សានុសិស្សយ៉ាងច្រើនកុះករ។





“មរតកមនុស្សរស់” គឺជាបុគ្គល ឬក្រុមមនុស្សដែលមានចំណេះដឹង ជំនាញ និងទេពកោសល្យកម្រិតកំពូល ដែលជាគន្លឹះដ៏សំខាន់ក្នុងការថែរក្សា និងជានានូវនិរន្តរភាពនៃបេតិកភណ្ឌវប្បធម៌អរូបី











របស់ជាតិ។ ពិព័រណ៍នេះត្រូវបានរៀបចំឡើងនៅសារមន្ទីរខ្មែងខ្មែរ នៃនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ ដោយមានដាក់តាំងបង្ហាញនូវស្នាដៃ ជីវប្រវត្តិសង្ខេប និងវត្តមានរបស់ព្រឹទ្ធាចារ្យមរតកមនុស្សរស់ចំនួន ១៥ រូប។ មកដល់បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជា បានចេញព្រះរាជក្រឹត្យទទួលស្គាល់មរតកមនុស្សរស់ចំនួនពីរលើករួចមកហើយ ដែលសរុបមាន ២៦ រូប ដែលជាសសរស្តម្ភដ៏រឹងមាំក្នុងការថែរក្សា និងបន្តវេននូវជំនាញសិល្បៈវប្បធម៌ដ៏កម្រ។

គោលបំណងសំខាន់ៗនៃពិព័រណ៍នេះរួមមាន៖

- ផ្តល់ឱកាសឱ្យសាធារណជន ជាពិសេសយុវជន និងសិស្សានុសិស្ស បានសិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពីស្នាដៃ និងទេពកោសល្យដ៏ប៉ិនប្រសប់របស់មរតកមនុស្សរស់នៃកម្ពុជា។
- បង្កើនការយល់ដឹងអំពីតម្លៃនៃបេតិកភណ្ឌវប្បធម៌អរូបី។
- បណ្តុះស្មារតីស្រឡាញ់ ស្ញើចសរសើរ និងជំរុញការចូលរួមបន្តវេនថែរក្សាការពារ និងលើកស្ទួយវប្បធម៌ជាតិឱ្យបានគង់វង្ស។

សូមបញ្ជាក់ជូនថា ពិព័រណ៍ «ស្នាដៃមរតកមនុស្សរស់» បើកជូនសាធារណជនចូលទស្សនាដោយសេរី ចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៥ ចាប់ពីម៉ោង ៩:០០ ព្រឹក ដល់ម៉ោង ៤:៣០ រសៀល នៅសារមន្ទីរខ្មែងខ្មែរ។

# ពិធីសម្ពោធពិព័រណ៍រូបថតក្រោមប្រធានបទ៖
# «រួមគ្នាលើកតម្កើងមរតកវប្បធម៌អរូបី»



នាព្រឹកថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ ក្រោមការដឹកនាំរបស់អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំពិធីសម្ពោធបើកពិព័រណ៍រូបថតក្រោមប្រធានបទ “រួមគ្នាលើកតម្កើងមរតកវប្បធម៌អរូបី”។ ពិធីនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **ឆិត ថាវរិទ្ធ** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយមានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំ ម្ចាស់ស្នាដៃរូបថត ភ្ញៀវកិត្តិយស និងសាធារណជនយ៉ាងច្រើនកុះករ។

ពិព័រណ៍នេះរៀបចំឡើងនៅ សារមន្ទីខ្ទែង ខ្មែរ នៃនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ ដោយមានដាក់តាំងបង្ហាញស្នាដៃរូបថតចំនួន ៦០ សន្ទឹក ដែលត្រូវបានសម្រាំងយ៉ាងយកចិត្តទុកដាក់ពីគណៈកម្មការជំនាញៗ។ព្រឹត្តិការណ៍នេះមានគោលបំណងសំខាន់ៗ ដូចជា៖















- បង្កើតវេទិកាអប់រំ និងផ្សព្វផ្សាយ៖ បំផុសការយល់ដឹងអំពីតម្លៃមិនអាចកាត់ថ្លៃបាននៃមរតកវប្បធម៌អរូបីជាតិ។

- លើកទឹកចិត្តយុវជន៖ ជំរុញឱ្យសិស្សានុសិស្ស និងសាធារណជនចូលរួមការពារ និងដឹងគុណចំពោះវប្បធម៌ជាតិ តាមរយៈសិល្បៈនៃការថតរូប។

- អបអរសាទរបេតិកភណ្ឌជាតិ៖ បង្ហាញពីភាពសម្បូរបែបនៃវប្បធម៌អរូបីរបស់កម្ពុជាទៅកាន់ពិភពលោក។

ជាពិសេស ក្រៅពីការទស្សនាផ្ទាល់ សាធារណជនក៏អាចចូលរួមបោះឆ្នោតជ្រើសរើស «ស្នាដៃរូបថតប្រជាប្រិយបំផុត» ទាំងតាមរយៈការមកទស្សនាផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ដើម្បីស្វែងរកម្ចាស់ជ័យលាភីលេខ ១, លេខ ២ និងលេខ ៣។

សូមបញ្ជាក់ថា ពិព័រណ៌នេះបានបើកជូនសាធារណជនចូលទស្សនាដោយសេរី ចាប់ពីថ្ងៃទី ២៤ ដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥ នៅសារមន្ទីរខ្ញែងខ្មែរ។

# សិល្បៈចាក់ចេក៖ មរតកវប្បធម៌ដ៏រស់រវើក



នារសៀល ថ្ងៃសៅរ៍ ៩កើត ខែមិគសិរ ឆ្នាំម្សាញ់ ព.ស២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥ នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ដឹកនាំដោយអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានរៀបចំពិធីបើក «ពិព័រណ៍សិល្បៈចាក់ចេក» ក្រោមអធិបតីភាព លោកជំទាវ **ឡុងឌី សាន់ណារ៉ា** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមានការចូលរួមពី ឯកឧត្តម **ហ៊ី ទីរៈ** ប្រធានសសយកវិស័យវប្បធម៌និងវិចិត្រសិល្បៈ ឯកឧត្តម **ខួន សុខៈ** សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី ប្រធានស.ស.យ.ក រាជធានីភ្នំពេញ ឯកឧត្តម **ឈុំ ម៉េងហុង** អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ មន្ត្រីរាជការ និងភ្ញៀវជាតិ-អន្តរជាតិ។

គោលបំណងរៀបចំកម្មវិធីនេះ គឺដើម្បីជាការក្រើនរំលឹក និងជានានិរន្តភាពនៃសិល្បៈចាក់ចេក តាមរយៈការលើកកម្ពស់ការយល់ដឹងជាសាធារណៈ បង្កើតបទពិសោធន៍ជាក់ស្តែង ផ្ទេរចំណេះដឹងដោយផ្ទាល់អំពីដំណើរការនៃការឆ្លាក់ដល់ទស្សនិកជន ជំរុញចំណាប់អារម្មណ៍របស់យុវជន និងសិស្សានុសិស្សចំពោះសិល្បៈហត្ថកម្មបុរាណ ដើម្បីជានាឱ្យមានការបន្តរៀនសូត្រ និងការបន្តជំនាន់ លើកទឹកចិត្ត

















ដល់ព្រឹទ្ធាចារ្យសិល្បៈករ ការទទួលស្គាល់ជំនាញ និងស្នាដៃរបស់ពួកគាត់ ជំរុញឱ្យមានឱកាសពិភាក្សា អំពីបញ្ហាប្រឈម និងកិច្ចការអភិរក្សនៃសិល្បៈចាក់ចេក។

សូមបញ្ជាក់ថា ពិព័រណ៍ «សិល្បៈចាក់ចេក» បានបើកជូនសាធារណជនចូលទស្សនាដោយសេរី ចាប់ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៥ ចាប់ពីម៉ោង១៩ និង៣០នាទី ដល់ម៉ោង ២១និង ៣០នាទី នៅវិថីថ្មើរជើង ទល់មុខវត្តឧណ្ណាលោម។

# មហោស្រពភាពយន្តអន្តរជាតិកម្ពុជាលើកទី១៤ ឆ្នាំ២០២៥




## ១- សេចក្តីផ្តើម

តាមរយៈកិច្ចប្រឹងប្រែងរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងការចូលរួមសហការ គាំទ្រពីដៃគូពាក់ព័ន្ធនានា ឆ្នាំនេះគឺ ជាឆ្នាំទី១៤ ដែលមហោស្រពភាពយន្តអន្តរជាតិកម្ពុជារៀបចំឡើង ហើយគឺជាព្រឹត្តិការណ៍ភាពយន្តដ៏ធំនៅកម្ពុជា និងតំបន់អាស៊ាន ដែលបាននាំមកនូវភាពយន្តដ៏សម្បូរបែប បង្កប់ដោយខ្លឹមសារអប់រំ និងទស្សនទានល្អៗ ព្រមទាំងជាស្ពានដ៏សំខាន់ក្នុងការនាំយកសមិទ្ធិករភាពយន្តនានាមកពីគ្រប់ទិសទី ចូលមកកាន់ឧស្សាហកម្មភាពយន្តកម្ពុជា។

មហោស្រពភាពយន្តអន្តរជាតិកម្ពុជា បានបំពេញតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតបរិស្ថានភាពយន្តដ៏ សំបូរបែប និងរស់រវើកនៅក្នុងប្រទេសកម្ពុជា ព្រមទាំងបានរួមចំណែកយ៉ាងសំខាន់ដល់ការក្នុងការជុំរុញព្រះរាជាណាចក្រកម្ពុជាជាដែនដីស្វាគមន៍ការថតភាពយន្តជាតិ និងអន្តរជាតិ ព្រមទាំងជួយលើកកម្ពស់កិត្តិនាមកម្ពុជាឱ្យល្បីរន្ទឺលើឆាកអន្តរជាតិ ក្នុងបរិបទសុខសន្តិភាព ស្ថេរភាពនយោបាយ ព្រមទាំងការអភិវឌ្ឍនៅគ្រប់ហេដ្ឋារចនាសម្ព័ន្ធជារូបវន្ត ក្រោមគោលនយោបាយឈ្នះៗ។

## ២- កម្មវិធីលម្អិតអំពីមហោស្រព

កម្មវិធីបើកមហោស្រពភាពយន្តអន្តរជាតិកម្ពុជាលើកទី១៤ បានប្រព្រឹត្តទៅនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឯកឧត្តម **ខៀវ កាញារីទ្ធ** និងលោកជំទាវ និងឯកឧត្តម លោកជំទាវ ឯកអគ្គរដ្ឋទូត លោក លោកស្រីតំណាងដៃគូសហការ អ្នកឧបត្ថម្ភ ផលិតករ សមិទ្ធករភាពយន្ត ព្រមទាំងភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិប្រមាណជាង










៦០០នាក់ នៅសាលមហោស្រពចតុម្មុខ។ ក្នុងឱកាសនោះក៏មានការអញ្ជើញចូលរួមពីលោកស្រី **ឧត្តម សុភី** ទូតសុច្ឆន្ទៈមហោស្រពភាពយន្តអន្តរជាតិកម្ពុជាលើកទី១៤ និងលោកស្រី **វីកតូរៀ ប៊ូស៊ីស** អ្នកបង្កើតភាពយន្តពិភពនិម្មិត VR Experience “ជីវិតកូនថ្លៃ កូនត្រូវតែរស់” (STAY ALIVE MY SON)។

ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៩ ខែមីនា មហោស្រពភាពយន្តអន្តរជាតិកម្ពុជាលើកទី ១៤ បាននាំមកនូវការចាក់បញ្ចាំងភាពយន្ត ចំនួន១៥១ ចំណងជើង ដែលបើកឱ្យទស្សនិកជនចូលទស្សនាដោយឥតគិតថ្លៃ នៅគ្រប់រោងភាពយន្តធំៗ និងទីតាំងជាច្រើនទៀតក្នុងរាជធានីភ្នំពេញ ដែលរួមមានរោងភាពយន្ត Legend Olympia និង Legend Exchange Square រោងភាពយន្ត Major Cineplex Aeon 1 និង Major Cineplex Aeon3 វិទ្យាស្ថានបារាំង មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា សណ្ឋាគារ Rosewood ភ្នំពេញ និងរោងភាពយន្ត Fable។

កម្មវិធីផ្សេងៗ ដែលបានរៀបចំឡើងក្នុងឱកាសមហោស្រព

**១-** សៀវភៅមានចំណងជើង “ជីវិតកូនថ្លៃ កូនត្រូវតែរស់” របស់លោក **ពិន យ៉ាថៃ** ត្រូវបានផលិតជាភាពយន្តតាមទម្រង់បច្ចេកវិទ្យា ពិភពនិម្មិត ឬ Virtual Reality ហើយត្រូវបានសម្ដែងដោយតារាល្បីសញ្ជាតិបារាំង-កម្ពុជា កញ្ញា **ELODIE YUNG** និងបង្កើតឡើងដោយសមិទ្ធិករភាពយន្តអាមេរិកាំង លោកស្រី **Victoria Bousis** ។

**២-** ការរំលឹកដល់ការចូលកាន់កាប់របស់ខ្មែរក្រហម។ មហោស្រពភាពយន្តអន្តរជាតិកម្ពុជាឆ្នាំនេះបានដាក់បញ្ចូលនូវខ្សែភាពយន្តសំខាន់ៗជាច្រើន ដែលបង្ហាញពីពេលវេលាដ៏ខ្មៅងងឹតបំផុតនៃទីក្រុងភ្នំពេញ។ កម្មវិធី “១៩៧៥-២០២៥៖ ពិភពអន្ទការទៅរកពន្លឺក្នុងរឿងកម្ពុជា” គឺជាការរំលឹកខួប






លើកទី៥០ នៃការឡើងកាន់អំណាចរបស់ខ្មែរក្រហម នៅកម្ពុជាដែលជាការចាប់ផ្តើមនៃជំពូកដ៏ខ្មៅងងឹតបំផុតមួយក្នុងប្រវត្តិសាស្ត្រនាឆ្នាំ ១៩៧៥ ក្រោមការដឹកនាំរបស់ប៉ុលពត។

**៣-** កម្មវិធីបញ្ចាំងភាពយន្ត “ស្ត្រីគ្មានព្រំដែនៈ រឿងរ៉ាវស្ត្រីជុំវិញពិភពលោក” ដើម្បីអបអរសាទរភាពធន់ កម្លាំង និងថាមពលផ្លាស់ប្តូររបស់ស្ត្រីមកពីវប្បធម៌ផ្សេងៗគ្នា និងឆ្លងទ្វីប។ ស្ត្រីបានក្លាយជាចំណុចស្នូលនៃគ្រប់សង្គមទាំងការបង្កើតប្រវត្តិសាស្ត្រ វប្បធម៌ និងវឌ្ឍនភាព។ ពីភាពជាអ្នកដឹកនាំក្នុងគ្រួសារ និងសហគមន៍ រហូតដល់ការច្នៃប្រឌិតផ្នែកវិទ្យាសាស្ត្រ នយោបាយ និងសង្គម ស្ត្រីបានរួមចំណែកដល់មូលដ្ឋានគ្រឹះនៃអរិយធម៌។

**៤-** ចក្ខុវិស័យនៃកម្ពុជា (GLIMPSE OF CAMBODIA) បានបង្ហាញខ្សែភាពយន្តចំនួន ១០ ចំណងជើង ព្រមទាំងការចាក់បញ្ចាំងលើកដំបូងនៅកម្ពុជា ភាពយន្តរឿង “LOOT” ផលិតដោយ DON MILLAR ។ ភាពយន្ត “LOOT” គឺជាការស៊ើបអង្កេតលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តកាលពីអតីតកាល និងសកម្មភាពបច្ចុប្បន្នដើម្បីប្រគល់ត្រឡប់មកវិញនូវសម្បត្តិបេតិកភណ្ឌវប្បធម៌របស់កម្ពុជា ។ ការបញ្ចាំងភាពយន្ត និងការពិភាក្សាជាក្រុមលើប្រធានបទ បេតិកភណ្ឌវប្បធម៌កម្ពុជា និងការប្រគល់មកវិញនូវវត្ថុបុរាណដែលបានត្រូវលួច បានត្រូវធ្វើឡើង នៅក្នុងសាលាភូមិន្ទវិចិត្រសិល្បៈ។

**៥-** ភពផែនដីដ៏ស្រស់ស្អាត (BEAUTIFUL PLANET) ផ្តោតសំខាន់លើឆ្នាំនេះផ្តោតលើទឹកនៃជីវិតដែលប្រមូលផ្តុំនូវបណ្តុំនៃការគូសបញ្ជាក់ពីសារៈសំខាន់នៃទឹកជាប្រភពនៃជីវិតធនធានអាហារដ៏សំខាន់ និងជាការ តភ្ជាប់បរិស្ថានសម្រាប់សហគមន៍ជនជាតិដើមភាគតិច។ ភាពយន្តដ៏ស្រស់ស្អាតនេះរួមមានរឿងរ៉ាវពីខេត្តតាមដងទន្លេមេគង្គ រឿងរ៉ាវ














*ក្នុងតំបន់មេគង្គដោយអង្គការ OXFAM និងរឿងសម្លេងជនជាតិដើម។ ភាពយន្តជាង ៣០ពីសហគមន៍ និងការអប់រំភាពជាអ្នកដឹកនាំកម្ពុជា និងអន្តរជាតិ ដែលចងក្រងឯកសារពីបញ្ហាសហសម័យ និងបញ្ហាប្រឈមនានាជុំវិញពិភពលោក។ ប្រធានបទរួមមាន សត្វព្រៃ និងជីវៈចម្រុះ បញ្ហាជនជាតិដើមភាគតិច និងសហគមន៍កម្ពុជា និងទស្សនៈពីបណ្ដាប្រទេសអាស៊ីអាគ្នេយ៍។*

**៦-** *កម្មវិធីជុំវិញទន្លេមេគង្គ (THE MEKONG DISCOVERY DAYS) ប្រព្រឹត្តទៅនៅ CJCC ( បន្ទប់អង្គរ-គីហ្សូណា) នៅថ្ងៃទី២៤ ដល់ថ្ងៃទី២៥ ខែមីនា ដោយមានការចូលរួមសម្ពោធបើកកម្មវិធីដោយ ឯកឧត្តម* **ឌិត ទីណា** *រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងមានការចាក់បញ្ចាំងភាពយន្តខ្លាតវែង កិច្ចពិភាក្សា ពិព័រណ៍រូបថត បទបង្ហាញ និងវេទិកាជាមួយដៃគូនានាដូចជា UNDP WHO ស្ថានទូតអូស្ត្រាលី អង្គការអភិរក្សអន្តរជាតិមជ្ឈមណ្ឌល Pulitzer ។*

**៧-** *កម្មវិធីសិក្ខាសាលា ជាផ្នែកមួយនៃមហោស្រពភាពយន្តអន្តរជាតិកម្ពុជាលើកទី១៤ “សិល្បៈនៃការបំលែងអត្ថបទភាពយន្តឱ្យទៅជារូបភាព” ៖ ការសហការរវាងអ្នកដឹកនាំរឿង អ្នកកាត់ត និងអ្នកកែពណ៌រូបភាព ក្នុងការបង្កើតភាពយន្តដ៏ទាក់ទាញ ដើម្បីស្វែងយល់អំពីសិល្បៈនៃការបង្កើតភាពយន្ត ដែលមានទស្សនីយភាពដ៏គួរឱ្យចាប់អារម្មណ៍។*





## ៣- លទ្ធផលមហោស្រពភាពយន្ត អន្តរជាតិកម្ពុជាលើកទី១៤

ក្នុងរយៈពេល០៩ថ្ងៃ គិតពីថ្ងៃទី២១ ដល់ថ្ងៃទី២៩ ខែ មីនា ការបញ្ចាំងខ្សែភាពយន្ត ១៥១ ចំណងជើងនិងកម្មវិធីផ្សេងៗបានប្រព្រឹត្តទៅដោយរលូន នៅតាមទីតាំងទាំង១០កន្លែង ដែលបានគ្រោងទុក ហើយបានទទួលលទ្ធផលគួរជាទីមោទន ។

- មានអ្នកចូលរួមគាំទ្រនិងទស្សនាខ្សែភាព-យន្តដោយផ្ទាល់សរុបចំនួនជាង ១៦,០០០ដង/នាក់ និង ទស្សនិកជន Online ចំនួន២៤៣,០០០ នាក់ ។

- ភ្ញៀវកិត្តិយសអន្តរជាតិ ជាអ្នកដឹកនាំរឿង ជាផលិតករ ជាសិល្បករ ជាអ្នកសារព័ត៌មាន ជាដៃគូសហការណ៍ដែលបានមកដល់ព្រះរាជាណាចក្រកម្ពុជាមានចំនួន៣៥ នាក់។

- តារាងកម្មវិធីបញ្ចាំងកុន ចំនួន ជិត២០,០០០ ច្បាប់ ដែលបានបោះពុម្ព ត្រូវបានចែកចាយដល់មហាជនក្នុងរាជធានីភ្នំពេញ ។

- គេហទំព័ររបស់មហោស្រព (www.cambodiaiff.com) និង Facebook ផ្លូវការរបស មហោស្រពភាពយន្តមជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញ និងទទួលការថតភាពយន្ត និងនាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ មានអ្នកចុចចូលចំនួន ៤០៥,០០០នាក់ និងអ្នកចូលអាន ចំនួន ២៦៨,០០០ នាក់។

- មានការ Download យកកម្មវិធីមហោស្រពតាម Online មានចំនួន ២៨,០០០ដង ។

- សារព័ត៌មានជាតិ និង អន្តរជាតិចំនួន១៨ បានចុះអត្ថបទពីសកម្មភាពពីមហោស្រពភាពយន្តអន្តរជាតិកម្ពុជាលើកទី១៤ ហើយទទួលបានការចាប់អារម្មណ៍ចំនួន ១,១៥២,០០០ នាក់។




## ៤- សេចក្តីសន្និដ្ឋាន

មហោស្រពភាពយន្តអន្តរជាតិកម្ពុជា លើកទី១៤ ឆ្នាំ២០២៥ នេះ គឺជាការជួយជំរុញ និងលើកកម្ពស់ឧស្សាហកម្មភាពយន្តកម្ពុជាឱ្យមានការរីកចម្រើន រួមចំណែកដល់ការផ្សព្វផ្សាយពីកត្តាសុខសន្តិភាព ស្ថេរភាពនយោបាយរបស់កម្ពុជា និងជាពិសេសបានបង្ហាញពីសម្បត្តិបេតិកភណ្ឌវប្បធម៌-រូបី អរូបី និងសម្បត្តិធម្មជាតិកម្ពុជា ទៅកាន់ពិភពលោក ព្រមទាំងជាការផ្តល់ឱកាសដល់អ្នកអាជីពក្នុងវិស័យភាពយន្ត ក្នុងការចែករំលែកបទពិសោធន៍ផ្លាស់ប្តូរយោបល់គ្នា រកចំណុចខ្លាំង បង្កើនគុណភាពភាពយន្តកម្ពុជា ដើម្បីអាចប្រកួតប្រជែងជាមួយនឹងការរីកចម្រើន ឥតឈប់ឈរនៃទីផ្សារភាពយន្តក្នុងតំបន់។ ជាមួយគ្នានេះ កម្ពុជាបាននិងកំពុងក្លាយជាទីតាំងសម្រាប់ថតខ្សែភាពយន្ត កាន់តែមានភាពទាក់ទាញស្របតាមចក្ខុវិស័យនៃគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌ ក្នុងការជំរុញកម្ពុជា ឱ្យក្លាយជាដែនដីនៃការថតភាពយន្តជាតិ និងបរទេស។

## ១- សេចក្តីផ្តើម

ការបណ្តុះបណ្តាលជំនាញភាពយន្តគឺជាយន្តការគន្លឹះនិងអាទិភាពដើម្បីលើកកម្ពស់សមត្ថភាពធនធានមនុស្ស សំដៅរួមចំណែកអភិវឌ្ឍឧស្សាហកម្មភាពយន្តប្រកបដោយប្រសិទ្ធភាពនិងនិរន្តភាព។

ក្រោមគំនិតផ្តួចផ្តើម និងការគាំទ្រយ៉ាងពេញទំហឹងពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នាយកដ្ឋានសិល្បៈភាពយន្តនិងផ្សព្វផ្សាយវប្បធម៌ សហការជាមួយ CineHub ព្រមទាំងដៃគូឯកជននានា បានបើកវគ្គបណ្តុះបណ្តាលជំនាញភាពយន្តខ្លីកម្ពុជា (Cambodia Film Lab) ជារៀងរាល់ឆ្នាំគិតចាប់តាំងពីឆ្នាំ២០១៦ ដោយផ្តោតលើជំនាញសំខាន់ៗក្នុងវិស័យភាពយន្តដូចជា ជំនាញសរសេរអត្ថបទនិពន្ធភាពយន្ត ជំនាញដឹកនាំរឿង ជំនាញថតភាពយន្ត ជំនាញសម្តែង ជំនាញកាត់តនិងតំឡើងរូបភាព និងជំនាញបច្ចេកទេសសំឡេង ជាដើម។ វគ្គបណ្តុះបណ្តាលនេះបានអនុញ្ញាតឱ្យសិក្ខាកាមការសិក្សារយៈពេល០៣ខែទៅលើផ្នែកទ្រឹស្តីនិងការអនុវត្តជាក់ស្តែងជាមួយសម្ភារៈបច្ចេកទេស ព្រមទាំងការរៀបចំផលិតស្នាដៃភាពយន្តខ្លីចន្លោះពី២ទៅ៣ចំណងជើង ដើម្បីវាយតម្លៃទៅលើកម្រិតយល់ដឹងនិងសមត្ថភាពរបស់សិក្ខាកាម។

## ២- អំពីវគ្គបណ្តុះបណ្តាលភាពយន្តខ្លីកម្ពុជា ជំនាន់ទី៨ ឆ្នាំ២០២៥

ក្រោយពីទទួលបានគោលការណ៍អនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នាយកដ្ឋានសហការជាមួយ ក្រុម CineHub, ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (Cambodia Tourism Board), មូលនិធិជប៉ុន៖ ការិយាល័យភ្នំពេញ (Japan Foundation: Liaison office in Phnom Penh) បានរៀបចំបើកវគ្គបណ្តុះបណ្តាលភាពយន្តខ្លីកម្ពុជាលើកទី០៨ ឆ្នាំ២០២៥ (The 8th Cambodia Film Lab 2025) ដោយផ្តោតសំខាន់លើជំនាញសរសេរអត្ថបទនិពន្ធភាពយន្ត (Script Writing) អ្នកដឹកនាំរឿង (Film Directing) អ្នកថតភាពយន្ត (Cinematography) អ្នកយកសម្លេង រចនាសម្លេង (Sound recording-Sound designer) និងជំនាញមួយ ចំនួនទៀតដែលទាក់ទងនឹងការផលិតភាពយន្តដូចជាការរៀបចំតុបតែងលម្អរឆាក (Production designer), ការចាត់ចែងផលិត (Production Manager), ជំនួយការដឹកនាំរឿង (Assistant Director), ជំនួយការថត (Assistant Camera), កាត់ត-តម្លើងរូបភាព (Editing), ការកែពណ៌-ពន្លឺ(Color Grading)...។ល។ វគ្គសិក្សានេះមានរយៈពេល៣ខែ គិតចាប់ពីខែកក្កដាដល់ខែកញ្ញា ឆ្នាំ២០២៥ រៀបចំនៅនាយកដ្ឋានសិល្បៈភាពយន្តនិងផ្សព្វផ្សាយវប្បធម៌ ដែលមានបេក្ខជនចូលរួមចំនួន៤៤រូប ។

ពិធីបើកវគ្គបណ្តុះបណ្តាលជាផ្លូវការបានរៀបចំធ្វើនៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៥ នៅនាយកដ្ឋានភាពយន្តនិងផ្សព្វផ្សាយវប្បធម៌ ក្រោមអធិបតីភាព លោក **ម៉ុក មូរក្ស** ប្រធាននាយកដ្ឋាន និងកម្មវិធីបិទវគ្គបណ្តុះបណ្តាលបានរៀបចំធ្វើនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥ នៅរោងភាពយន្ត














សកម្មភាពនៃពិធីបើកវគ្គ និងបិទវគ្គ ព្រមទាំងការចែកវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាជូនសិក្ខាកាម

*Legend Exchange Square* ក្រោមអធិបតីភាព ឯកឧត្តម **ឯក ម៉ុនថា** អនុរដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **លោកជំទាវបណ្ឌិតសភាចារ្យ** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាអ្នកឧបត្ថម្ភ ដៃគូសហការ លោកគ្រូ អ្នកគ្រូ និងសិក្ខាកាម សរុប ១៥៧ រូប ។

## ៣- សកម្មភាពបណ្ដុះបណ្ដាល

កម្មវិធីសិក្សានេះចែកចេញជា២ដំណាក់កាលដូចខាងក្រោម៖

**១- ដំណាក់កាលនៃការរៀបចំសរសេរអត្ថបទនិពន្ធភាពយន្ត *(Script Writing)***

ការសរសេរអត្ថបទនិពន្ធភាពយន្ត (Script writing) គឺជាដំណាក់កាលដំបូងនិងមានសារសំខាន់ក្នុងការបញ្ជ្រាបនូវគំនិតនៃការនិពន្ធសាច់រឿងទៅតាមបរិបទសង្គមនិងការបំផុសនូវគំនិតអប់រំឱ្យមាននៅក្នុងសាច់រឿង។ ជំនាញនេះដឹកនាំបង្ហាត់បង្រៀនដោយ គ្រូបង្គោល កញ្ញា **សុធា អ៊ីណោស** (កម្ពុជា) ដោយបង្រៀនក្នុងរៀនផ្ទាល់ និងលោកស្រី **DATE Soramy** (ជប៉ុន) បង្រៀនប្រព័ន្ធអនឡាញក្នុងរយៈពេល០៤សប្តាហ៍

- **សប្ដាហ៍ទី១៖** ការសិក្សា និងវិភាគលើស្នាដៃភាពយន្តខ្លី (Analysis short film and write review)
- **សប្ដាហ៍ទី២៖** ការបង្កើតសាច់រឿងពីចំណុចសូន្យ (Story from nothing and develop a short story concept.)
- **សប្ដាហ៍ទី៣៖** សសរស្តម្ភទាំង៣ នៃការបង្កើតសាច់រឿង (3 pillars of story: Events, Character, Setting)
- **សប្ដាហ៍ទី៤៖** ការបង្កើតឯកសារភាពយន្តខ្លី ( Telling your story: Create proposal of your project: Pitch, logline, Synopsis and Treatment)

ក្រោយពីការសិក្សារយៈពេល០៤សប្ដាហ៍លើការសរសេរអត្ថបទភាពយន្ត សិក្ខាកាមត្រូវសិក្សាលើជំនាញសំខាន់ផ្សេងៗទៀតក្នុងរយៈ៨សប្ដាហ៍ដូចខាងក្រោម ៖

- **ជំនាញដឹកនាំរឿង** (Directing) បង្ហាត់ដោយលោក **ចាប សោមច័ន្ទរិទ្ធិ**
- **ជំនាញថតភាពយន្ត** (Cinematography) និងជំនួយការថតទី០១ (1st Assistant Camera) បង្ហាត់ដោយ លោក **នៅ សុវណ្ណរ័ត្ន**។ ជំនាញថតនេះចាំបាច់ត្រូវយល់ដឹងលើជំនាញបច្ចេកទេសពាក់ព័ន្ធ ដូចជា ឯកទេសផ្នែកពន្លឺ (Lighting) និងឯកទេសជំនួយការថត (Grip)
- **ជំនាញបច្ចេកទេសថតសម្លេង** (Sound on Set and Sound Mixing) បង្ហាត់ដោយលោក **ខណ្ណា សេរីរតនៈ**
- **ជំនួយការដឹកនាំរឿងទី១** (1st assistant director) បង្ហាត់ដោយ លោក **គីជិត រិទ្ធា**
- **អ្នករៀបចំតុបតែងឆាក** (Arts & Set director) បង្ហាត់ដោយ កញ្ញា **គង់ ស្រីណែត**
- **ការចាត់ចែងផលិត** (Producing) បង្ហាត់ដោយ លោក **អ៊ុក បញ្ញាលី** និង លោក **គឹមហាន ពុទ្ធា**
- **កាត់ត-តម្លើងរូបភាព និង កែព័ណ៌** (Editing & Color grading) បង្ហាត់ដោយលោក **សារិន សៅម៉ូរ៉ា**

**២- ដំណាក់កាលនៃរៀបចំមុនការថត និងការចុះអនុវត្តថតភាពយន្ត**

ក្រោយឆ្លងកាត់ការវគ្គសរសេរអត្ថបទនិពន្ធនិងវគ្គសំខាន់ៗខាងលើរួចមក ក្រុមការងារដឹកនាំការបណ្ដុះបណ្ដាល ព្រមទាំងលោកគ្រូអ្នកដែលជាអ្នកបង្ហាត់បង្រៀន បានពិនិត្យ និងសម្រេចជ្រើសរើស អត្ថបទនិពន្ធសាច់រឿងខ្លីចំនួន២ចំណងជើង ដែលមានខ្លឹមសារល្អ ក្នុងចំណោមស្នាដៃដ៏ទៃទៀតដែលសរសេរដោយសក្ខាកាម មករៀបចំ






*សកម្មភាពបណ្តុះបណ្តាលក្នុងថ្នាក់ លើជំនាញនិពន្ធអត្ថបទភាពយន្ត, ដឹកនាំរឿង, ថតភាពយន្ត*

ដើម្បីផលិតជាភាពយន្តខ្លីខ្លាតខ្លី ក្នុងនោះមាន៖

- ភាពយន្តរឿង "គ្រលុក" (Pothole)
- ភាពយន្តរឿង "ផ្កាម្រេច" (Peper Flower)

ក្រុមការងារក៏បានធ្វើការបែងចែកសិក្ខាកាមទាំងអស់ជា២ក្រុម ហើយក្រុមនីមួយៗត្រូវផលិតភាពយន្តខ្លីខាងលើមួយចំណងជើង ដោយមានរយៈពេល ចន្លោះពី៥ ទៅ១៥នាទី។ ការផលិតភាពយន្តខ្លីចែកចេញជា៣ ដំណាក់កាល ដូចខាងក្រោម៖

- **ដំណាក់កាលមុនការផលិត** (Pre-Production Stage)៖ គឺជាដំណាក់កាលរៀបចំក្រុមការងារតាមផ្នែកនីមួយៗ ព្រមទាំងការរៀបចំគម្រោងថវិកាផលិត ការពិនិត្យជ្រើសរើសទីកន្លែងថត ការជ្រើសរើសតួសម្តែង ការរៀបចំសម្លៀកបំពាក់ និងសម្ភារៈតុបតែងលម្អរឆាក ការបំលែងអត្ថបទនិពន្ធទៅជាប្លង់ថត (Script Breakdown and Block shot) ការរៀបចំកម្មវិធីថតលម្អិត។ល។

- **ដំណាក់កាលផលិត** (Production Stage)៖ គឺជាដំណាក់កាលចុះថតផ្ទាល់នៅតាមទីតាំងដែលបានកំណត់ ដោយមានការដឹកនាំសម្របសម្រួលដោយគ្រូបង្គោល កញ្ញា **សុធា អ៊ីណែស** លោក **ចាប សោមច័ន្ទរិទ្ធិ** លោក **នៅ សុវណ្ណរ័ត្ន** លោក **វណ្ណ សេរីរតនៈ** ព្រមទាំងក្រុមការងារសម្របសម្រួលទីតាំងនៃ ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (Cambodia Tourism Board)។ សូមបញ្ជាក់ថា ក្រោមជំនួយឧបត្ថម្ភរបស់ CTB ទីតាំងថតទាំងអស់គឺរៀបចំនៅក្នុងដែនដីខេត្តកំពត។

- **ដំណាក់កាលក្រោយការផលិត** (Post-Production Stage)៖ គឺជាដំណាក់កាលដែលបាន





សកម្មភាពរៀបចំកម្មវិធីថត ក្នុងដំណាក់កាលមុនការផលិត





សកម្មភាពនៃការដឹកនាំសម្របសម្រួលការផលិតភាពយន្តខ្លីលើទីតាំងថតជាក់ស្តែង



សកម្មភាពនៃការកាត់ត ដំឡើងរូបភាព និងផ្គុំសំឡេងភាពយន្ត

បញ្ចប់ការថត រួចរាល់តាមទីតាំងនិងកាលវិភាគកំណត់ ហើយក្រុមនីមួយៗចាប់ផ្តើមយករូបភាពវីដេអូដែលថតរួចមកធ្វើការកាត់ត តំឡើងរូបភាព និងផ្គុំសម្លេងដោយត្រូវធ្វើជា៣វគ្គដូចខាងក្រោម៖

- ក្រុមនីមួយៗត្រូវជួបគ្រូបង្ហាត់ផ្នែក កាត់តផ្គុំរូបភាព ចំនួន១ថ្ងៃ ដើម្បីចាប់ផ្តើមតំរៀបរូបភាព

- ក្រុមនីមួយៗត្រូវជួបគ្រូបង្ហាត់ផ្នែកនិពន្ធ និងផ្នែកដឹកនាំរឿង ចំនួន១ថ្ងៃ ដើម្បីពិនិត្យលើរូបដែលតំរៀបផ្គុំរួច និងស្តាប់ការណែនាំលើផ្នែកបច្ចេកទេស និង ខ្លឹមសារ អត្ថន័យសិល្បៈ និងការតភ្ជាប់ រូបភាពពីប្លង់មួយទៅប្លង់មួយទៀត។

- ក្រុមនីមួយៗត្រូវគ្រូបង្ហាត់ផ្នែកផ្គុំសម្លេង (Sound mixing) ដើម្បីពិនិត្យជ្រើសរើសសម្លេង តន្ត្រី សូរស័ព្ទសម្លេងបរិយាកាសផ្សេងៗដើម្បីដាក់បញ្ចូលទៅតាម ទម្រង់នៃឈុតឆាកនីមួយៗ ដូចជា សម្លេងសត្វស្វាប សត្វល្អិតពេលរាត្រី ទឹកហូរ ទឹករលក ផ្គររន្ទះ...ជាដើម។ល។

## ៤- សេចក្តីសន្និដ្ឋាន

ពីមួយឆ្នាំទៅមួយឆ្នាំ វគ្គបណ្តុះបណ្តាលភាពយន្តខ្លីកម្ពុជា បានក្លាយជាវេទិការដ៏មានសារសំខាន់ និងជាចំណុចប្រសព្វ ដែលផ្សារភ្ជាប់យុវជនកម្ពុជាមកពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើការជួបជុំ ផ្លាស់ប្តូរយោបល់គ្នា ជាមួយនឹងការចែករំលែកនូវបទពិសោធន៍ថ្មីៗក្នុងវិស័យភាពយន្ត ហើយក៏ជាវេទិកាអប់រំ និងបំផុសទេពកោសល្យ គំនិតច្នៃប្រឌិត នៃការផលិតភាពយន្តខ្នាតខ្លីនៅកម្ពុជាផងដែរ។

វគ្គបណ្តុះបណ្តាលភាពយន្តខ្លីកម្ពុជា ពិតជាបានផ្តល់នូវឱកាស និងចំណេះដឹងជាមូលដ្ឋានបន្ថែមទៀតលើបច្ចេកទេសជំនាញនៃការផលិតភាពយន្តដល់យុវជនរបស់កម្ពុជា ទាំងការសិក្សាលើទ្រឹស្តីនិងការអនុវត្តផលិតភាពយន្តជាក់ស្តែង។ សកម្មភាពទាំងនេះមិនត្រឹមតែជាសកម្មភាពជំរុញលើកទឹកចិត្តដល់យុវជនដើម្បីបញ្ចេញនូវគំនិតច្នៃប្រឌិត ចែករំលែកព័ត៌មាន និងរឿងរ៉ាវដែលមនុស្សភាគច្រើនពុំធ្លាប់បានដឹង ពុំធ្លាប់បានលឺ និងពុំធ្លាប់បានឃើញក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួន តាមរយៈអេក្រង់ ឬផ្ទាំងសំពត់ស ហើយគឺជាជំហ៊ានដំបូងដែលនាំពួកគេឱ្យក្លាយជាផលិតករភាពយន្ត ព្រមទាំងបានរួមចំណែកយ៉ាងសំខាន់ក្នុងគោលនយោបាយយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងការពង្រឹងនិងពង្រីកការអប់រំនិងការបណ្តុះបណ្តាលសិល្បៈវប្បធម៌ ព្រមទាំងលើកស្ទួយឧស្សាហកម្មវប្បធម៌និងច្នៃប្រឌិត សំដៅរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

# ការរួមចំណែក
# លើកស្ទួយការតែងនិពន្ធ ការបោះពុម្ព និងការអានជាតកម្ពុជា៖

### ពិព័រណ៍សៀវភៅកម្ពុជា, ទិវាជាតិអ្នកនិពន្ធ,
### ការប្រឡងស្នាដៃតែងនិពន្ធអក្សរសិល្ប៍ពានរង្វាន់ព្រះនាងឥន្ទ្រទេវី ឆ្នាំ២០២៥



## ក- ពិព័រណ៍សៀវភៅកម្ពុជាលើកទី១២

ពិព័រណ៍សៀវភៅកម្ពុជា គឺជាព្រឹត្តិការណ៍មួយយ៉ាងសំខាន់និងមានសារប្រយោជន៍ខ្លាំងណាស់ ព្រោះជាវេទិកាជួបជុំរវាងអ្នកនិពន្ធ អ្នកអាន អ្នកបោះពុម្ពផ្សាយ អង្គការ សមាគម បណ្ណារក្ស អ្នកស្រាវជ្រាវ សិស្ស និស្សិតនិងសាធារណជនទូទៅ ដែលធ្វើការពាក់ព័ន្ធជាមួយសៀវភៅ តាមរយៈកិច្ចជំនួបនេះ គឺជួយឱ្យពួកគេបានជជែកពិភាក្សា ដកស្រង់ នូវបទពិសោធនិងស្វែងយល់ពីគ្នាទៅវិញទៅមកនៅចំណុចល្អនិង ចំណុចខ្វះខាត តម្រូវការ និងផលវិបាកទាំងភាគីអ្នកអាន អ្នកនិពន្ធ ព្រមទាំងជាកម្លាំងថាមពលដ៏សំខាន់ដើម្បីជួយជំរុញនិងបណ្តុះ ទឹកចិត្តកូនខ្មែរឱ្យមានទម្លាប់ស្រឡាញ់ចូលចិត្តការអាននិងការសរសេរ។ កម្មវិធីពិព័រណ៍សៀវភៅនេះបានក្លាយជាព្រឹត្តិការណ៍វប្បធម៌មួយដ៏សំខាន់ក្នុងការផ្សព្វផ្សាយនិងជំរុញលើកទឹកចិត្តឱ្យប្រជាជនខ្មែរឱ្យមានទម្លាប់ក្នុងការអានសៀវភៅ និងស្គាល់ពីគុណតម្លៃនៃការអានដើម្បីអភិវឌ្ឍន៍ចំណេះដឹងនិងការងារ។

ពិព័រណ៍សៀវភៅកម្ពុជារៀងរាល់ឆ្នាំ ធ្វើឡើងក្នុងគោលបំណងនិងសកម្មភាពដូចខាងក្រោម៖

***គោលបំណង :**

**១-** ជួយផ្សព្វផ្សាយការបោះពុម្ពសៀវភៅគ្រប់ប្រភេទដើម្បីឱ្យមាន ទីផ្សារទាំងក្នុងនិងក្រៅប្រទេស។

**២-** ជំរុញឱ្យប្រជាជនខ្មែរមានទម្លាប់ក្នុងការអានសៀវភៅហើយ ជាសារមួយបញ្ជូនទៅដល់យុវជនឱ្យស្គាល់ពីគុណតម្លៃនៃការអាន ដើម្បីអភិវឌ្ឍន៍ចំណេះដឹងនិងបង្កើនគំនិតសម្រាប់ ការសិក្សានិងការងារ។

**៣-** បង្កើនកម្មវិធីនិទានរឿងនិងគូរគំនូររូបភាពផ្សេងៗដល់កុមារ ដើម្បីបណ្តុះទឹកចិត្តកុមារឱ្យស្រលាញ់និងចូលចិត្តសៀវភៅតាំងពី នៅតូចៗ

**៤-** គាំទ្រឧស្សាហកម្មបោះពុម្ពផ្សាយនៅកម្ពុជានិងនៅក្នុង ពិភពលោក

**៥-** លើកទឹកចិត្តកវីនិពន្ធ អ្នកនិពន្ធ អ្នក-



ស្រាវជ្រាវ វិចិត្រករខ្មែរ ដើម្បីបង្កើតស្នាដៃថ្មីៗបន្ថែមទៀត។

***សកម្មភាព :**

-ការដាក់តាំងពិព័រណ៍សៀវភៅដែលមានការចូលរួមពីអ្នកនិពន្ធ កវីនិពន្ធ គ្រឹះស្ថានបោះពុម្ពផ្សាយ និងបណ្ណាគារនានាក្នុងព្រះរាជាណាចក្រកម្ពុជា (សៀវភៅមួយចំនួនដាក់លក់ក្នុងតម្លៃពិសេស) វេទិកាស្តីពីការបោះពុម្ពផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក, ការធ្វើបទបង្ហាញនានាទាក់ទងទៅនឹងអក្សរសាស្ត្រ អក្សរសិល្ប៍ខ្មែរ និងវិទ្យាសាស្ត្រ ការនិពន្ធសៀវភៅ និងការអភិវឌ្ឍការ អាន ការជួបពិភាក្សា និងការទទួលយកបទពិសោធពីអ្នកនិពន្ធល្បីៗ និងមានការចុះហត្ថលេខាពីអ្នកនិពន្ធព្រមទាំងវិចិត្រករ កម្មវិធីនិទានរឿង និងល្បែងសិក្សាសម្រាប់កុមារ ការប្រគំតន្ត្រី និងសំណួរចម្លើយចាប់យករង្វាន់ផ្សេងៗ។

*ពិព័រណ៍សៀវភៅកម្ពុជា រៀបចំឡើងដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា អង្គការ សមាគមវិស័យឯកជន និងដៃគូពាក់ព័ន្ធមួយចំនួនទៀត បានប្រារព្ធពិធីបើកពិព័រណ៍សៀវភៅកម្ពុជា លើកទី១២ កាលពីព្រឹកថ្ងៃព្រហស្បតិ៍ ៦រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័កព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥ ក្រោមអធិបតីភាពឯកឧត្តម **ខៀវ កាញារីទ្ធ** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាអ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម

***ពិព័រណ៍សៀវភៅឆ្នាំ២០២៥ មាន៖**

- អ្នកចូលរួមឧបត្ថម្ភ : ៨ស្ថាប័ន
- ដៃគូសហការ : ១២ស្ថាប័ន
- ស្តង់សរុប២៩៧(មកពី១៦៩ស្ថាប័ន)
- សាធារណជនចូលរួមទស្សនានិងទិញសៀវភៅប្រមាណ៩៥ ០០០នាក់។

## ខ- ទិវាជាតិអ្នកនិពន្ធលើកទី២

រាជរដ្ឋាភិបាល បានកំណត់យកថ្ងៃទី៧ ខែធ្នូ ជាទិវាជាតិអ្នកនិពន្ធ គឺជាសមិទ្ធផលដ៏ត្រចះត្រចង់ជាប្រវត្តិសាស្ត្រដើម្បីឆ្លើយតបទៅនឹងគុណតម្លៃនៃកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ



និង សមាគមអ្នកនិពន្ធខ្មែរ ក៏ដូចជាអ្នកនិពន្ធ កវីនិពន្ធ និងរៀមច្បងទាំងអស់ដែលបានលះបង់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតីប្រកបដោយសុច្ឆន្ទៈ មនសិការជាតិ ក្នុងបុព្វហេតុរួមចំណែកយ៉ាងសកម្មក្នុងការលើកស្ទួយវិស័យអក្សរសាស្ត្រ អក្សរសិល្ប៍ជាតិបោះជំហានទៅមុខទៀតប្រកបដោយកិត្យានុភាពនិងសុខដុមភាព។

*ឆ្នាំនេះ «ទិវាជាតិអ្នកនិពន្ធ» បានកំណត់យកប្រធានបទ «អ្នកនិពន្ធ គឺជាទូតសុច្ឆន្ទៈក្នុងការអភិរក្ស និងអភិវឌ្ឍវប្បធម៌ដើម្បីសន្តិភាព» យើងកត់សម្គាល់ឃើញថា មានការចូលរួមគាំទ្រនិងលើកទឹកចិត្តពីរាជរដ្ឋាភិបាល ស្ថាប័នរដ្ឋ អង្គការ សមាគម សង្គម





ស៊ីវិល និងសាធារណជនយ៉ាងផុលផុស។

ក្នុងឆ្នាំ២០២៥នេះ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានរៀបចំអបអរសាទរទិវាជាតិអ្នកនិពន្ធ ដោយតាំងបង្ហាញស្នាដៃកវីនិពន្ធ អ្នកនិពន្ធឆ្នើម ដែលជាម្ចាស់ពានអក្សរសិល្ប៍ក្នុងស្តង់អ្នកនិពន្ធ ចំនួន៥ក្នុងនោះមានពានរង្វាន់អក្សរសិល្ប៍សំខាន់ៗ ដូចជា ពានរង្វាន់ព្រះនាងឥន្ទ្រទេវី, ពានរង្វាន់អក្សរសិល្ប៍ព្រះសីហនុរាជ, ពានរង្វាន់អក្សរសិល្ប៍៧មករា, ពានអក្សរសិល្ប៍ទន្លេមេគង្គ, និងពានរង្វាន់អក្សរសិល្ប៍អាស៊ីអាគ្នេយ៍។

ក្នុងឱកាសនោះ យើងបានប្រគល់ប័ណ្ណថ្លែងអំណរគុណដល់កវីនិពន្ធ អ្នកនិពន្ធឆ្នើមចំនួន១០រូប និងរៀបចំកិច្ចពិភាក្សាវេទិកាតុមូលនូវប្រធានបទចំនួន២៖

**១-** បទពិសោធនៃការបង្កើតស្នាដៃនិពន្ធដើម្បីប្រឡងពានរង្វាន់អក្សរសិល្ប៍នានា

**២-** វឌ្ឍនភាពនិងបញ្ហាប្រឈមវិស័យតែងនិពន្ធនៅកម្ពុជា ដោយក្នុងប្រធានបទនីមួយៗមានវាគ្មិនកិត្តិយសចំនួន៥រូប។

## គ- ការប្រឡងស្នាដៃតែងនិពន្ធអក្សរសិល្ប៍

## ពានរង្វាន់ព្រះនាងឥន្ទ្រទេវីលើកទី១១

ក្នុងឱកាសទិវាជាតិអ្នកនិពន្ធក៏មានការប្រគល់ជយលាភីស្នាដៃតែងនិពន្ធពានរង្វាន់ព្រះនាងឥន្ទ្រទេវីឆ្នាំ២០២៥(លើកទី១១)ផងដែរ។



កវីនិពន្ធ អ្នកនិពន្ធ ដែលជាប់ចំណាត់ថ្នាក់ជយលាភីឆ្នាំ២០២៥ មានចំនួន១០រូប (ផ្នែកប្រលោមលោកខ្នាតខ្លីចំនួន៥រូប និង ផ្នែកកំណាព្យរឿងចំនួន៥រូប) ក្នុងចំណោមបេក្ខជនដែលបានដាក់ស្នាដៃប្រកួតប្រជែងចំនួន៨៧ ក្នុងនោះប្រលោមលោកខ្នាតខ្លីចំនួន៦៣ស្នាដៃ និងប្រលោមកំណាព្យ (កំណាព្យរឿង) ចំនួន២៤ស្នាដៃ។



***ផ្នែកប្រលោមលោកខ្នាតខ្លី**

- ជយលាភីលេខ១ : រឿង«លំចង់បឹងរាំង» និពន្ធដោយកញ្ញា កប វណ្ណហួច រាជធានីភ្នំពេញ

- លេខ២: រឿង«ចិញ្ចៀនត្បូងទទឹម» និពន្ធដោយលោកស្រី ផាន់ សុផល ខេត្តបាត់ដំបង

- លេខ៣ : រឿង«ចិត្តវិកល» និពន្ធដោយលោក មឿង ពិសិត ខេត្តពោធិ៍សាត់

- លេខ៤: រឿង«ភក្តីវៃក្មេនដែនស្នេហ៍សោមាន» និពន្ធដោយលោក សុវណ្ណ សិរីវុឌ្ឍ រាជធានីភ្នំពេញ

- លេខ៥ : រឿង«នារីក្រោយកាមេរ៉ា» និពន្ធដោយកញ្ញា ជា សុលីនី រាជធានីភ្នំពេញ។

*** ផ្នែកកំណាព្យរឿង(ប្រលោមកំណាព្យ)**

- លេខ១ : រឿង«សោកំណាក្រោយភ្លៀងរលឹម» និពន្ធដោយលោក មឿន សំណាង ខេត្តឧត្តរមានជ័យ

- លេខ២ : រឿង «ត្រើយជីវិត» និពន្ធដោយកញ្ញា ហែន វីរិនី រាជធានីភ្នំពេញ

- លេខ៣ : រឿង«សសិសោភា គន្ធាផ្កាស្នេហ៍» និពន្ធដោយលោក សុវណ្ណ សិរីវុឌ្ឍ រាជធានីភ្នំពេញ

- លេខ៤ : រឿង«គ្រូកិច្ចសន្យា» និពន្ធដោយលោក ជួន ខ្មៅ ខេត្តព្រះសីហនុ

- លេខ៥ : រឿង «កូនបណ្តាំ» និពន្ធដោយលោក ទៀង ធន ខេត្តព្រៃវែង។







# ជំពូកទី៤

# អក្សរសិល្ប៍, កម្សាន្ត




ដើមពុទ្រា

# រឿងដើមពុទ្រាឧត្តមា



*និពន្ធដោយៈ លោកស្រី **គង់ ច័ន្ទវ៉ាន់ណេង***
*ជយលាភីលេខ ១ ផ្នែកប្រលោមលោកខ្លាតខ្លី*
*ពានរង្វាន់ព្រះនាងឥន្ទ្រទេវី ឆ្នាំ២០២៤*

*រៀបចំដោយៈ*
***ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ***

ម៉ោង ៨:០០យប់នាថ្ងៃនេះនៅតែងងឹតដូចម៉ោង ៨:០០យប់រាល់ថ្ងៃដែរ តែរលឹមផ្សេងក្រូចនៅបន្តធ្លាក់រពុយៗកំដរខ្ញុំដែលកំពុងញាប់ដៃញាប់ជើងបញ្ចប់ការងារ។ ល្ងាចមិញភ្លៀងធំ នាំមកទាំងភាពត្រជាក់និងសំរាមមកជាមួយដែរ។ ដូច្នេះខ្ញុំត្រូវតែបោស ដើម្បីភាពស្អាតបាតនៅមុខផ្ទះ ព្រោះផ្ទះខ្ញុំជាផ្ទះលក់អីវ៉ាន់ចាប់ហួយ បើមិនស្អាត គេនឹងមិនចូលទិញឡើយ។

«បងម៉ា! ហេតុអីក៏មិនជួលគេគាស់ដើមពុទ្រាហ្នឹងទៅ? វាងាប់ហើយមើលទៅ!» ចន្ទ្រារុញធុងទឹកកកចូលទៅក្នុងផ្ទះផង ងាកមកសួរខ្ញុំផង។ ចន្ទ្រាជាអ្នកនៅជាមួយខ្ញុំ។ នាងជួយលក់ដូរផង និងជួយមើលម៉ាក់ផង។ នាងប្រៀបដូចជាសមាជិកគ្រួសារម្នាក់របស់ខ្ញុំទៅហើយ។ ដើមពុទ្រាដែលនាងនិយាយហ្នឹង ដុះនៅខាងមុខផ្ទះហើយខ្ញុំដាក់ធុងទឹកកកទុកក្លាស្បេរកេសជ្ជៈលក់ក្រោមដើមវារាល់ថ្ងៃ។ ឥឡូវនេះវាលែងមានស្លឹកបៃតងហើយសល់តែស្លឹកក្រៀមៗត្រៀមនឹងជ្រុះអស់រលីងពីដើមប៉ុណ្ណោះ ហើយសូម្បីតែទឹកភ្លៀងក៏មិនអាចជួយស្រោចស្រង់ជីវិតវាបានដែរ គឺនៅសល់តែដើមជ្រ្កឹងៗដែលពុកផុយដោយសារមេស៊ី។ ខ្ញុំញញឹមស្ងួតមិនតបនឹងចន្ទ្រានោះទេ ព្រោះនាងក៏ដើរចូលទៅក្នុងផ្ទះបាត់ហើយដែរ ដូច្នេះខ្ញុំអាចគេចវេះពីចម្លើយនេះបាន។ ផ្លូវមុខផ្ទះខ្ញុំស្ងាត់អ្នកធ្វើដំណើរហើយ ហើយជាទូទៅខ្ញុំនិងចន្ទ្រាតែងតែបិទតូបច្រើរនេះ។ ចន្ទ្រាទទួលបន្ទុកជញ្ជូនអីវ៉ាន់ចូលទៅខាងក្នុងផ្ទះ ចំណែកខ្ញុំទទួលបន្ទុកបោសសំរាមទាំងឡាយដែលខ្យល់បើុងមកមុខផ្ទះ។ សំឡេងម៉ូតូមួយគ្រឿងឈប់ក្បែរខ្ញុំចម្ងាយមួយម៉ែត្រ ដោយអ្នកបើកបរជាបុរសអាយុប្រហែលសាមប្លាយ។

«ចែបិទតូបនៅ? យកប៊ីយែរមួយកេស! ម៉ាកអីក៏បាន!» បុរសម្នាក់នោះសួរមកខ្ញុំដោយសំឡេងវែងអន្ទាយ និងមានភាយក្លិនស្រាមកជាមួយផង។ ជាទូទៅ ទោះកំពុងបិទតូបក៏ដោយ តែបើមានអ្នកមកទិញ គឺខ្ញុំនៅតែលក់ឱ្យជានិច្ច។

«បិទហើយ! ហើយកន្ទែងខ្ញុំគ្មានលក់ស្រាទេ! ចាំទុកផង!» ខ្ញុំនិយាយដោយសំឡេងស្មើ ដៃកាន់អំបោសដងវែងរឹតតែមាំទៅទៀត។ ពូនោះមើលខ្ញុំ

បែបមិនពេញចិត្ត ហើយជិះម៉ូតូលឿនស្ទេវចេញទៅ។ ខ្ញុំបន្តបោសផ្លូវមុខផ្ទះទៀត តែបានបន្តិចខ្ញុំក៏ងើយមើលសភាពផ្ទះខ្លួនឯង ដែលជាផ្ទះល្វែងកម្ពស់ពីរជាន់ឈរយ៉ាងរឹងមាំនៅលើដីដែលមានទីធ្លាធំមួយកន្លែង។ ផ្ទះនេះមិនត្រឹមតែមានឈ្មោះជាផ្ទះទេ តែជាទីជម្រកដ៏កក់ក្ដៅមួយ ទោះបីដីងងឹតក្ដីឡើង ខ្ញុំឃើញអីវ៉ាន់ណែនផ្ទះរកផ្លូវដើរសឹងមិនឃើញក៏ដោយ។ ខ្ញុំចោលក្រសែភ្នែកសម្លឹងទៅស្លាកយីហោដែលបន្ទុបខ្លួននៅលើសំយ៉ាបស័ង្កសីខាងមុខផ្ទះ ដែលមានអក្សរធំៗថា «ឧត្តមាលក់គេសជ្ជៈ»។

មានរឿងចម្លែកពីរយ៉ាងនៃផ្ទះលក់ចាប់ហួយរបស់ខ្ញុំ ដែលអ្នកភូមិតែងតែឆ្ងល់។ រឿងចម្លែកទីមួយនោះគឺអ្នកភូមិពិបាកអានឈ្មោះរបស់ខ្ញុំ! ខ្លះអាន «អ៊ុ-ដម-មៀ» ខ្លះអាន «អ៊ុ-ដ-ម៉ា» តែឈ្មោះដែលត្រឹមត្រូវនោះគឺអានតាមបែបបាលី «អ៊ុត-តៈ-ម៉ា»។ មែនហើយ! ឧត្តមា ឬ អ៊ុត-តៈ-ម៉ា គឺជាឈ្មោះរបស់ខ្ញុំ! ដូច្នេះហើយទើបគ្រប់គ្នានៅផ្ទះខ្ញុំ ហៅខ្ញុំថាតៈម៉ា ឬបងម៉ា។ ខណៈផ្ទះលក់ចាប់ហួយផ្សេងមានឈ្មោះសាមញ្ញៗ ងាយហៅ ងាយចាំ តែផ្ទះខ្ញុំបែរជាមានឈ្មោះពិបាកហៅទៅវិញ។ នេះក៏ព្រោះតែប៉ាខ្ញុំគឺជាសាស្ត្រាចារ្យភាសាវិទ្យានៅសាកលវិទ្យាល័យមួយកន្លែង ដូច្នេះឈ្មោះកូនទាំងបីរបស់គាត់គឺសុទ្ធតែបើកវចនានុក្រមភាសាខ្មែរដើម្បីរកអត្ថន័យល្អៗមកដាក់ឱ្យ។

ខ្ញុំគឺកូនស្រីច្បង ឈ្មោះពេញ សុជា ឧត្តមា មានន័យថា ភាពខ្ពង់ខ្ពស់ ល្អប្រសើរ។

ប្អូនប្រុសបន្ទាប់ខ្ញុំឈ្មោះ សុជា ជេដ្ឋា មានន័យថា ចម្រើនបំផុត។

ចំណែកប្អូនស្រីពៅឈ្មោះ សុជា មុទិតា ដែលមានន័យថា ដំណើរមានចិត្តរីករាយទៅរកសេចក្ដីសុខរបស់អ្នកដទៃពុំរើសមុខ គឺការមានចិត្តជួយត្រេកអរមិនច្រណែន មិនឈ្នានីស ក៏ជាធម៌ទី៣នៃព្រហ្មវិហារធម៌ទាំង៤ដែរ។

រៀបរាប់ឈ្មោះប៉ុណ្ណឹងបានហើយ ងាកមករឿងចម្លែកទីពីរវិញម្ដង។ «ឧត្តមាលក់គេសជ្ជៈ» មានលក់ស្ទើរតែគ្រប់យ៉ាងលើកលែងតែគ្រឿងស្រវឹង។ ប្លែកអត់? ផ្ទះលក់ចាប់ហួយប៉ុនណាណី បែរជាគ្មានលក់ស្រាបៀរ ខណៈផ្ទះលក់ចាប់ហួយផ្សេងៗជាច្រើនកំពុងតែកើបលុយចំណេញពីរបរនេះ។ ការពិតទៅ មុនពេលខ្ញុំចូលមកគ្រប់គ្រងរបរមួយនេះ ផ្ទះយើងក៏មានលក់គ្រឿងស្រវឹងដូចគេដូចឯងដែរ ថែមទាំងអាចរកប្រាក់ចំណេញបានច្រើនទៀតផង ពិសេសឱ្យតែកៀកថ្ងៃបុណ្យទានដូចជាចូលឆ្នាំចិន ចូលឆ្នាំខ្មែរ ឬភ្ជុំអីហ្នឹង។ គេសជ្ជៈនេះខុសគេខុសឯងត្រង់ថា លក់ដាច់ដោយមិនបាច់ប្រឹងធ្វើទីផ្សារពេកក៏បាន។ តែចាប់ពីខ្ញុំចូលមកគ្រប់គ្រងមុខរបរនេះជំនួសម៉ាក់ និងលើកស្លាកយីហោ «ឧត្តមាលក់គេសជ្ជៈ» មក ទំនិញដែលខ្ញុំបង្វិលឱ្យក្រុមហ៊ុនវិញ និងលុបចេញពីបញ្ជីអីវ៉ាន់ ឈប់បន្តលក់ទៀតគឺស្រាហ្នឹងហើយ។ កាលឈប់លក់ដំបូងៗ សឹងតែដាច់ម៉ូយទៅហើយ។ អ្នកទិញសុខចិត្តទៅទិញផ្ទះផ្សេងដែលមានគ្រប់យ៉ាង ហើយផ្ទះខ្លះលក់ដេញដើងគ្នាមានសេវាកម្មដឹកស្រាបៀរដល់ផ្ទះទៀតផង មិនពិបាកអ្នកផឹកត្រូវជិះម៉ូតូមកទិញនាំតែការផឹកស៊ីលែងរលូនឡើយ។ ខ្ញុំឈឺ! ឈឺណាស់! អាណោចអធ័មណាស់ដែលត្រូវមកឃើញអំពើខុសពីសីល៥ តែស្របច្បាប់ទាំងនេះ!

ចន្ទ្រារៀបអីវ៉ាន់រួចអស់ហើយ នាងក៏ចូល

សម្រាកមុន នៅសល់តែខ្ញុំដែលឈរសម្លឹងមើលដើមពុទ្រាដែលគ្មានជីវិតមួយដើមនោះ។ មែន! វាមិនសល់ជីវិត តែវាសល់រូបរាងនិងអនុស្សាវរីយ៍របស់ខ្ញុំនិងប៉ា។ ប៉ាជាអ្នកដាំពុទ្រាមួយដើមនេះតាំងពីខ្ញុំនៅតូច ហើយមិនទាន់មានប្អូនៗ។ រាល់ឆ្នាំ ពុទ្រានេះតែងតែហុចផ្លែឱ្យខ្ញុំនិងម៉ាក់បេះលក់ផ្គួបជាមួយអីវ៉ាន់ច្រើនមុខទៀតនៅផ្ទះរបស់យើង។ ខ្ញុំឈរស្រក់ទឹកភ្នែកម្នាក់ឯងក្រោមភ្លៀងរលឹមផ្សែងក្រូច ហើយនឹកដល់រឿងរ៉ាវកាលពី៦ឆ្នាំមុន...

ល្ងាចនោះ មេឃរលឹមស្រិចៗប៉ះនឹងដំបូលស័ង្កសីប្រក់លើផ្ទះឈើមួយកន្លែងនៅរាជធានីភ្នំពេញដែលជាថ្នាក់រៀនសិល្បៈបុរាណ។ ថ្នាក់រៀននេះបើកដោយព្រឹទ្ធាចារ្យចូលនិវត្តន៍មួយក្រុមបង្រៀនមិនយកកម្រៃ។ ប៉ុន្តែទោះបីមិនយកកម្រៃសម្រាប់សិស្សដែលមានលទ្ធភាពនៅតែអាចបរិច្ចាគសម្រាប់ទ្រទ្រង់ថ្នាក់រៀនបាន។ ខ្ញុំនិងសិស្ស៣នាក់ទៀតដែលសុទ្ធតែជាអ្នកស្រឡាញ់សិល្បៈគំនូរ កំពុងរៀនគូរគំនូរប្រេងក្រោមការពន្យល់របស់លោកគ្រូ។ ខ្ញុំស្រឡាញ់ការគូររូបណាស់! បើក្រពះមិនសំខាន់ ខ្ញុំមិនបាច់ញ៉ាំបាយ ហើយគិតតែគូររូបរហូតក៏បានដែរ។ គំនូរនិងចម្លាក់ មិនត្រឹមតែជាអាជីពទេ តែជាព្រលឹងជាតិ! សាកស្រមៃមើលបើនៅលើជញ្ជាំងប្រាសាទគ្មានគំនូរនិងចម្លាក់ គ្មានក្បាច់ គ្មានរចនា ម៉្លេះយើងគ្មានដួងព្រលឹងដែលលាក់ខ្លួននៅពីក្រោយវណ្ណកម្មដ៏ពិចិត្រទាំងនោះទេ។ ខ្ញុំក៏ស្រលាញ់ខាងចម្លាក់ដែរ ប៉ុន្តែខ្ញុំចង់រៀនខាងគំនូរឱ្យចេះស្ទាត់សិន សឹមចាប់ផ្ដើមរៀនខាងចម្លាក់តាមក្រោយ។ ដ្បិតថាខ្ញុំកំពុងរៀនថ្នាក់ទី១២ ជាឆ្នាំប្រឡង តែខ្ញុំចេះបែងចែកពេលវេលាសិក្សាច្បាស់លាស់ណាស់ រហូតដល់តំណែងលេខមួយតែងតែបានមកលើខ្ញុំស្ទើរតែរាល់ខែ និងបានប័ណ្ណសរសើរស្ទើរតែរាល់ខែ រាល់ឆមាស និងរាល់ឆ្នាំ។ ម៉ាក់ប៉ាមិនជំទាស់រឿងខ្ញុំឆ្លៀតរៀនជំនាញគំនូរបន្ថែមនៅពេលយប់នោះទេ ព្រោះគាត់ទុកចិត្តទំនួលខុសត្រូវរបស់ខ្ញុំ។

រាល់ដងខ្ញុំគូរគំនូរប្រាសាទបុរាណ តែថ្ងៃនេះខ្ញុំចង់គូររូបអ្នកគ្រប់គ្នានៅក្នុងផ្ទះរបស់ខ្ញុំ មានប៉ា ម៉ាក់ ជេដ្ឋា និងមុទិតា។ ប៉ុន្តែថ្ងៃនេះ ខ្ញុំចាប់ផ្ដើមគូររូបរបស់ប៉ាមុនគេ។ ភ្លាមនោះ ទូរសព្ទខ្ញុំរោទ៍! គ្រប់គ្នាសម្លឹងមកខ្ញុំដែលជាមេខ្លោងបង្កសំឡេងរំខានដល់ពួកគេ។ ខ្ញុំប្រញាប់រត់ចេញទៅកៀនម្ខាង ដើម្បីទទួលទូរសព្ទប៉ាទាំងញញឹម។ ថ្មើរនេះប៉ាប្រហែលជាចេញពីសាលាបង្រៀនហើយ គាត់ប្រាកដជានឹងសួរខ្ញុំថា«ចង់ញ៉ាំអីអត់? ប៉ាទិញផ្ញើ!»។ រាល់លើកដែលគាត់តេមកម៉ោងថ្មើរនេះ គឺបែបនេះ!

ខ្ញុំចុចទទួលទូរសព្ទប៉ាទាំងរីករាយ ហើយក្នុងចិត្តត្រៀមចម្លើយរួចជាស្រេចថាខ្ញុំនឹងញ៉ាំបបរសាមចូក។ ខ្ញុំនិងប៉ាចូលចិត្តបបរសាមចូកដូចគ្នា។

«អាឡូប៉ា!»ខ្ញុំនិយាយទាំងញញឹមញញែម។

«អាឡូអូន! អូនជាកូនម្ចាស់ទូរសព្ទមែនអូន?» ជាសំឡេងមនុស្សស្រីម្នាក់ និយាយក្នុងសំឡេងស្រទន់មកកាន់ខ្ញុំ។ សំឡេងគាត់ស្រទន់ តែខ្ញុំបុកទ្រូងរួចទៅហើយ។

«ចាស! ខ្ញុំគឺកូនគាត់! ម៉េចវិញបង? ហើយប៉ាខ្ញុំទៅណា?» ខ្ញុំសួរដោយបារម្ភ។

«អូនត្រៀមចិត្តណា! ប៉ាអូនគ្រោះថ្នាក់ចរាចរណ៍ឥឡូវគាត់កំពុងសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ! អូន

ជួយមកមន្ទីរពេទ្យឥឡូវមកណា!»

ឮហើយខ្ញុំស្ទុតចិត្តស្ទើរទន់ជើងដួល តែអារម្មណ៍មួយទៀតប្រាប់ខ្លួនឯងថា ខ្ញុំមិនអាចដួលបានទេ។ ប៉ាសម្រាន្តលើគ្រែពេទ្យរួចហើយ ខ្ញុំមិនអាចដេកដួលម្នាក់ទៀតបានទេ។

ខ្ញុំសុំគ្រូចេញពីរៀនមុន ហើយជិះម៉ូតូសំដៅទៅមន្ទីរពេទ្យ។ រយៈពេលបីម៉ោងដែលខ្ញុំឈរចាំខាងក្រៅបន្ទប់សង្គ្រោះបន្ទាន់ រង់ចាំក្រុមគ្រូពេទ្យដែលកំពុងជួយសង្គ្រោះប៉ា។ ពួកយើងជាកូន ជាប្រពន្ធបានត្រឹមតែឈរ បន់ស្រន់ទេព្ដាសុំឱ្យប៉ារួចផុតគ្រោះថ្នាក់។

បន្តិចក្រោយមកគ្រូពេទ្យបញ្ចប់ការវះកាត់ ហើយបញ្ជូនប៉ាទៅបន្ទប់ប្រពោធនកម្ម ឬ ICU ព្រោះត្រូវតាមដានអាការគាត់យ៉ាងយកចិត្តទុកដាក់។ គេមិនឱ្យពួកយើងចូលទៅជិតទេ តែយើងអាចមើលតាមកញ្ចក់ពីចម្ងាយបាន។ ប៉ាមានអុកស៊ីសែនខ្ទប់ច្រមុះ ហើយគាត់មិនទាន់ដឹងខ្លួនទេ។

លុះស្អែកឡើង គ្រូពេទ្យប្រាប់ថាអនុញ្ញាតឱ្យសាច់ញាតិម្នាក់ចូលទៅសួរសុខទុក្ខប៉ាបាន ព្រោះប៉ាដឹងខ្លួនហើយ គ្រាន់តែមិនទាន់នឹងន។ ខ្ញុំសុំម៉ាក់និងប្អូនៗ ឱ្យខ្លួនឯងចូលមើលមុនគេ ព្រោះខ្ញុំពិតជាចង់ប្រាប់ប៉ាឱ្យឆាប់ជាសះស្បើយ ប៉ាត្រូវហូបបបរសាមចូកជាមួយកូន ប៉ាត្រូវមើលរូបគំនូររបស់ប៉ាដែលកូនបានគូររួច។

ក្នុងខ្លួនខ្ញុំឥតមានកម្លាំងទេ តែជើងនៅតែបោះជំហានទៅមុខសំដៅទៅគ្រែប៉ា។ ប៉ាបើកភ្នែកបានតិចៗ ពេលគាត់ឃើញខ្ញុំ គាត់រង្គើដៃហាក់ដូចចង់បក់ដៃហៅខ្ញុំចូលទៅជិត។ ខ្ញុំស្ទុះទៅជិតប៉ា ឃើញទឹកភ្នែកគាត់ហូរ។ ប៉ានិយាយម្ដុបៗ ព្រោះពេទ្យដកប្រភេទអុកស៊ីសែនខ្ទប់ច្រមុះនិងមាត់ មកជាប្រភេទដោតក្នុងច្រមុះវិញហើយ។ ខ្ញុំឱនក្បាល និងដាក់ត្រចៀកទៅជិតមាត់ប៉ាដើម្បីស្ដាប់។

«ទោះមានរឿងអី.... កុំឈប់រៀនណាកូន!» ឮពាក្យពេចន៍ប៉ាហើយ កូនសមុទ្រដ៏តូចមួយគូដែលត្រូវបានអ្នកផងហៅថា«ទឹកភ្នែក»ច្រាលរលកហូរហៀរពេញផែនថ្ពាល់ទាំងគូរបស់ខ្ញុំ។ ដង្ហើមខ្ញុំដកមិនចង់ដល់គ្នាព្រោះតែខ្ញុំព្យាយាមទប់ ខ្លាចបង្កសំឡេងរំខានដល់អ្នកជំងឺផ្សេង ហើយខ្លាចពេទ្យលែងឱ្យមកជិតប៉ាទៀត។ ដៃខ្ញុំក្រសោបប្រអប់ដៃប៉ាជាប់ ហើយខ្ញុំឱនថើបដៃប៉ា។

«កូនសន្យា!»

តបនឹងប៉ាមិនទាន់ចប់ស្រួលបួលផងសំឡេងម៉ាស៊ីនលាន់ឮទីតៗ ដង្ហើមប៉ាកាន់តែដង្ហក់។ ខ្ញុំងើបមុខទាំងស្ងួនស្ងោសម្លឹងទៅប៉ា ឃើញមានឈាមច្រាលចេញពីមាត់គាត់។ គ្រូពេទ្យបីបួននាក់រត់មកកាន់គ្រែប៉ា ក្នុងនោះមានគ្រូពេទ្យម្នាក់ទាញខ្ញុំចេញពីបន្ទប់។ ទោះកាលនោះខ្ញុំមិនដឹងថាគ្រូពេទ្យទាញខ្ញុំចេញក្នុងគោលបំណងអី តែខ្ញុំ ម៉ាក់ និងប្អូនៗ បានត្រឹមហូរទឹកភ្នែក សម្លឹងប៉ាតាមកញ្ចក់ប៉ុណ្ណោះ។ គ្រូពេទ្យរួតរះសង្គ្រោះប៉ា ព្រោះពួកគាត់ដឹងច្បាស់ណាស់ថាពួកយើងត្រូវការប៉ាប៉ុនណា តែគួរឱ្យស្ដាយដែលមច្ចុរាជក៏ត្រូវការប៉ាដែរ គេត្រូវការប៉ា ដាងពួកខ្ញុំត្រូវការប៉ាទៅទៀត។

រូបភាពថ្ងៃនោះខ្ញុំចាំមិនភ្លេចឡើយ។ ការដែលឈរមើលមនុស្សដែលខ្លួនស្រឡាញ់ចាកចេញទៅរស់នៅភពផ្សេងមួយទៀត ប្រៀបដូចជាការដាំដើមពុទ្រាមួយដើម ផ្ដល់ផ្លែ ផ្ដល់ម្លប់ តែសុខៗក៏ត្រូវមនុស្សស្រវឹងមកកាប់ដើមដាច់បុិតអ៊ីចឹង គឺធ្វើអ្វីមិនបាន

ឡើយ បានត្រឹមតែឈរមើលហើយស្តាយស្រណោះ។ រឹតតែអាក្រក់ជាងហ្នឹងទៀតនោះគឺ មនុស្សស្រវឹងនោះមិនបានកាប់ដើមពុទ្រាដែលគ្រាន់តែជារុក្ខជាតិហូបផ្លែមួយដើមនោះទេ គឺគេបើកបរ ហើយបុកប៉ាខ្ញុំ។ ប៉ាមិនស្លាប់លើដងផ្លូវ តែប៉ានៅតែស្លាប់នៅមន្ទីរពេទ្យ! ប៉ានៅបន្តជីវិតបានមួយយប់ តែចុងក្រោយគាត់នៅតែចាកចេញ។

ក្តីរំពឹងដែលថា បានប៉ាទៅផ្ទះហូបបបរសាមចូកជុំគ្នា ប្រែក្លាយជាការអង្គុយមើលបបរសាមចូកក្នុងកូនចានចង្កឹះក្នុងពេលបុណ្យរបស់ប៉ាទៅវិញ។ ត្រឹមតែមួយប៉ប្រិចភ្នែក ពួកយើងបាត់បង់ប៉ាដោយសារបុរសប្រមាទម្នាក់បើកបរពេលស្រវឹង។ ក្រោយចប់ពិធីបុណ្យ៧ថ្ងៃរបស់ប៉ា ម៉ាក់ក៏បន្តលក់ដូរចាប់ហួយដូចធម្មតា ព្រោះតែនេះគឺជារបរបង្គោលតែមួយគត់ដែលពួកយើងនៅសល់។

អ្នកផ្សេងមើលមកត្រឹមតែគិតថា ផ្ទះខ្ញុំបាត់បង់ប៉ា គឺគ្រាន់តែបាត់ប្រភពចំណូលរបស់មេគ្រួសារម្នាក់ប៉ុណ្ណោះ តែសម្រាប់ពួកខ្ញុំ ការបាត់បង់ប៉ា គឺបាត់បង់សុភមង្គលពាក់កណ្តាលទៅហើយ!

សម្រាប់សិស្សនិស្សិតនៅសាកលដែលប៉ាបង្រៀន ការបាត់បង់ប៉ា គឺបាត់បង់សាស្ត្រាចារ្យម្នាក់។ សម្រាប់សង្គមខ្ញុំវិញ ការបាត់បង់ប៉ា គឺបាត់បង់ធនធានមនុស្សម្នាក់ ដោយកើនឡើងចំនួនឃាតករម្នាក់ទៅវិញ។

ព្រឹកព្រលឹមថ្ងៃមួយ...

ខ្ញុំទើបតែជួយម៉ាក់បើកតូបរួច អតិថិជនដំបូងរបស់យើងក៏ឈប់ម៉ូតូនៅមុខផ្ទះ។

«មីង! ឱ្យបីយែរមួយកេស! យកអាមួយកេសបីម៉ឺន!» បុរសម្នាក់នោះពោលប្រាប់ម៉ាក់។

«ចាស! ចាំបន្តិច!» ម៉ាក់តប ហើយដើរមកខាងក្នុងផ្ទះដើម្បីយកឱ្យគេ។ ខ្ញុំឮហើយកើតចិត្តមួម៉ៅនឹងអ្នកដែលចូលចិត្តផឹកស្រា។ មិនគិតរកការងារឱ្យមានប្រយោជន៍ជាងហ្នឹងធ្វើទេអ្ហេស បានជាមករកស្រាទាំងព្រឹក? ខ្ញុំដើរទាំងមុខក្រញូវសំដៅទៅម៉ូយអពមង្គលរបស់ខ្ញុំ។

«ផ្ទះនេះគ្មានលក់ទេ! ទៅវិញទៅ!»

«អ្ហេ! ទិញរាល់ដងមានតើ!» ពូនោះតវ៉ា។

«តែចាប់ពីថ្ងៃនេះទៅ លែងមានហើយ! កុំមករកទៀត!» ខ្ញុំប្រើសម្តីខ្លៃតៗតបទៅពូនោះវិញ តាមចរិតក្មេងខ្ជិលរបស់ខ្ញុំ។

«ត:ម៉ា! ឯងឆ្កួតទេអ្ហី?» ម៉ាក់កាន់កេសស្រាបៀរនៅនឹងដៃ ព្រមទាំងដើរមកជេរខ្ញុំ។ ខ្ញុំសម្លឹងមើលកេសស្រានោះ ហើយសម្លឹងទៅម៉ាក់ទាំងរលីងរលោងទឹកភ្នែក។

«ម៉ាក់ចិត្តដាច់ណាស់!» ខ្ញុំតបទៅម៉ាក់វិញ។ ពូអ្នកទិញម្នាក់នោះឃើញម្តាយកូនយើងលេងទឹកមុខដាក់គ្នា ក៏ជិះម៉ូតូចេញទៅវិញ។

«ដេញម៉ូយទាំងព្រឹក! ជាអ្នកលក់រំបល់យក៏ស្អី!» ម៉ាក់បន្ទោសមកទៀត ហើយនេះជាលើកទីមួយដែលគាត់ប្រើសម្តីបែបនេះមកកាន់ខ្ញុំ។ ប៉ាជាបុរសដែលសុភាព ហើយមានចិត្តមេត្តា សូម្បីតែម៉ាក់ប្រើសម្តីគ្រោតគ្រាតដាក់កូន ក៏ប៉ាហាមដែរ។

«ម៉ាក់! យើងឈប់លក់ស្រាទៅ!»

«ឆ្កួតទេអ្ហី? ផ្ទះចាប់ហួយតែអត់មានលក់ស្រា?»

«តែរាល់ពេលដែលយើងលក់ស្រាឱ្យគេ ខ្ញុំមានអារម្មណ៍ថាយើងមិនមែនលក់ស្រាទេ យើងលក់ទឹកភ្នែកឱ្យគេ! ទឹកភ្នែកយើងនិងទឹកភ្នែកអ្នកឯទៀត ដែលមានសាច់ញាតិស្លាប់ដោយសារមនុស្ស

ស្រវឹង! យើងលក់ភាពឈឺចាប់របស់ខ្លួនឯងនិងគេគ្រប់គ្នាទាំងកេសៗរាល់ថ្ងៃ... រាល់ឆ្នាំ! មនុស្សស្លាប់រាល់ថ្ងៃ មនុស្សកើតរាល់ថ្ងៃ គេក៏ផលិតស្រារាល់ថ្ងៃដូចគ្នា! ខ្ញុំស្អប់!» ខ្ញុំនិយាយយ៉ាងវែងអន្ទាយដាក់ម៉ាក់ ទាំងទឹកភ្នែកហូររហាម។ ម៉ាក់ស្ងួតចិត្ត ព្រោះនេះជាលើកទីមួយដែលខ្ញុំហ៊ានស្រែកដាក់គាត់។ «ម៉ាក់ធ្ងន់អត់? ម៉ាក់លើកស្រាមួយកេសនោះទៅមានធ្ងន់ខ្លះអត់?» ឃើញម៉ាក់មិនតប ខ្ញុំស្រែកសួរម៉ាក់បន្ថែមទៀត ហើយក៏ឈរយំហ៊ូនៅមុខផ្ទះ។ ជេដ្ឋានិងមុទិតាអើតកឡឹមៗចេញពីក្នុងបន្ទប់មក រួចសម្លឹងមុខគ្នាឡិងឡង់។ ព្រោះឃើញខ្ញុំនិងម៉ាក់តឹងសរសៃកដាក់គ្នាជាលើកដំបូង។

«ធ្ងន់! ធ្ងន់ណាស់! តែកាតព្វកិច្ចចិញ្ចឹមពួកឯងវាធ្ងន់ជាង!» ថាតែប៉ុណ្ណេះ ម៉ាក់ក៏លើកស្រាដាក់លើគំនរបីយៃរទាំងជុងៗវិញ រួចដើរចូលទៅក្នុងបន្ទប់បាត់។

ពាក្យសម្តីរបស់ម៉ាក់មិនវែងទេ តែវាធ្ងន់! មួយរយគីឡូ? មួយពាន់គីឡូ? រាប់សែនគីឡូ? ឬធ្ងន់ជាងនេះ? ខ្ញុំមិនដឹងទេថាវាធ្ងន់ប៉ុនណា ព្រោះខ្ញុំធ្លាប់តែស្ពាយកាតាបទៅសាលា តែខ្ញុំមិនធ្លាប់ស្ពាយអម្រែកមើលថែទាំនិងចិញ្ចឹមគ្រួសារដូចម៉ាក់នោះទេ។ សមហើយ ដែលម៉ាក់ត្រូវត្អូញត្អែរថាធ្ងន់នោះ!

«បងម៉ា! បងម៉ាជួយម៉ាក់ផង!» សំឡេងជេដ្ឋាលាន់ឡើងពីក្នុងបន្ទប់ម៉ាក់មក។ ខ្ញុំប្រញាប់ជូតទឹកភ្នែកហើយរត់ទៅតាមការហៅរបស់ប្អូនប្រុស។

ទៅដល់ក្នុងបន្ទប់អ្វីដែលខ្ញុំឃើញមុនគេគឺរាងកាយស្ត្រីរាងស្គមស្តើង សម្បុរស... ស្ត្រីដែលនិយាយមិនសូវញុះទោះបីឈ្លោះជាមួយប្តី... ស្ត្រីដែលមិនធ្លាប់មានរឿងរ៉ាវជាមួយនរណា... ស្ត្រីដែលមិនធ្លាប់មើលងាយប្តី... ស្ត្រីដែលមិនធ្លាប់ជេរឬវាយកូន... គឺស្ត្រីដែលមានឈ្មោះថា «ម៉ាក់»ម្នាក់នោះ កំពុងសម្រាន្តស្តូកស្តឹងនៅលើឥដ្ឋ។

«ម៉ាក់!!!» ខ្ញុំស្រែកភ្ញាក់សំឡេង ហើយរត់ទៅត្រកងរាងកាយម៉ាក់ទាំងរន្ធត់ចិត្ត។

ក្រោយពីបញ្ជូនម៉ាក់ទៅមន្ទីរពេទ្យ លទ្ធផលបានបង្ហាញថាម៉ាក់មានជំងឺដុះសាច់ក្នុងថ្លើមដែលបានវិវត្តទៅជាមហារីក។ គាត់ឧស្សាហ៍និយាយថាចុកទ្រូងជាយូរមកហើយ តែពួកយើងមិនសូវបានចាប់អារម្មណ៍។ ខ្ញុំខ្វល់តែថាកាលវិភាគស្អែកនេះគឺមុខវិជ្ជាអ្វី ចំណែកប៉ាបានត្រឹមតែណែនាំឱ្យម៉ាក់ទៅពេទ្យ តែមិនដែលបាននាំទៅឡើយ ហើយម៉ាក់ខ្លួនឯងក៏មិនដាច់ចិត្តបិទតូបព្រោះខ្លាចបាត់ចំណូលប្រចាំថ្ងៃ។ ខ្ញុំក៏ដឹងច្បាស់ដែរថា បើឱ្យម៉ាក់រើសរវាងថ្ងៃសាលាកូន និង ថ្ងៃទៅពេទ្យ ម៉ាក់ប្រាកដជារើសថ្ងៃបង់សាលាឱ្យកូនហើយ។

ឥឡូវ ទម្រាំដឹង ជំងឺម៉ាក់វិវត្តទៅជាធ្ងន់ធ្ងរហើយ។ ពេទ្យតម្រូវឱ្យគាត់ចាក់គីមីទៅតាមការណាត់ដូច្នេះចំណាយក្នុងគ្រួសារបានកើតឡើងមួយកម្រិតទៀត បន្ថែមពីលើថ្លៃសិក្សារបស់ពួកខ្ញុំទាំងបី។ ម៉ាក់ត្រូវជាបត្រដូសបែបនេះ ចួនឈឺ ចួនជា ចួនបើកតូប ចួនបិទតូប រហូតដល់ខ្ញុំប្រឡងទី១២ជាប់។

«ទោះមានរឿងអី.... កុំឈប់រៀនណាកូន!» សំឡេងប៉ានៅតែលាន់ឡើងក្នុងខួរក្បាលខ្ញុំ តែរូបភាពម៉ាក់ដួលនៅលើឥដ្ឋក៏លាន់ឡើងក្នុងការចងចាំរបស់ខ្ញុំដូចគ្នា។ ថ្ងៃដែលប៉ាចាកចេញនិងថ្ងៃដែលម៉ាក់ដួលសន្លប់ សុទ្ធតែជាថ្ងៃដែលគួរឱ្យខ្លាចដូចគ្នាសម្រាប់ខ្ញុំ។

ខ្ញុំសម្លឹងមើលលិខិតសរសើរដែលបញ្ជាក់ថាខ្ញុំជាសិស្សពូកែលំដាប់លេខមួយទូទាំងសាលា រួចសម្លឹងទូរសព្ទដែលមានរូបថតលទ្ធផលប្រឡងទុតិយភូមិបាននិទ្ទេសA និងរូបគំនូរប៉ាដែលខ្ញុំទើបតែបានគូរបញ្ចប់ដោយអារម្មណ៍សោកសៅ។ ខ្ញុំចង់ឈប់រៀន! ក្នុងកាលៈទេសៈនេះ មនុស្សដែលរឹងមាំបំផុតក្នុងគ្រួសារខ្ញុំ គឺជាខ្ញុំ... ខ្ញុំគឺក្មេងស្រីអាយុ១៧ឆ្នាំម្នាក់ដែលមានសុខភាពល្អ ប៉ុន្តែឧស្សាហ៍យំពេលនឹកដល់ប៉ា និងពេលអាណិតម៉ាក់។ ចំណែកជេដ្ឋាទើបតែរៀនថ្នាក់ទី៨ ឯមុទិតានៅរៀនថ្នាក់ទី៥។ ពួកគេកំពុងពេញរៀន កំពុងចូលចិត្តសៀវភៅ! តែម៉ាក់ក៏កំពុងតែចុះខ្សោយដែរ!

ម៉ាក់! ម៉ាក់ត្រូវតែមានជីវិត ដើម្បីមើលភាពជោគជ័យរបស់កូនណា៎! ម៉ាក់ត្រូវតែអង្គុយទល់មុខកូន សម្លឹងមើលកូនរៀនចប់ មានការងារធ្វើ ក្លាយជាមនុស្សល្អក្នុងសង្គម។ ម៉ាក់មិនត្រូវលេងញ៉ាកដូចប៉ាទេ! ប៉ាលេងញ៉ាកណាស់ ព្រោះប៉ាមិនបានអង្គុយទល់មុខកូន តែប៉ាបែរជាមើលមកកូនពីលើមេឃទៅវិញ។

គឺនៅថ្ងៃនោះហើយដែល... ខ្ញុំយកលិខិតសរសើរនិងសញ្ញាបត្រទាំងអស់ទៅទុកក្នុងទូ យកសៀវភៅទាំងអស់រៀបដាក់កេសទុកវានៅបន្ទប់ដាក់អីវ៉ាន់ យកប្រដាប់ប្រដាគូរគំនូរទាំងអស់ទុកក្រៀនផ្ទះ ដោយជំនួសមកវិញនូវបញ្ជី និងវិក្កយបត្រអីវ៉ាន់សម្រាប់លក់ចាប់ហួយនៅលើតុរៀន។ ម៉ាក់ខ្សោយហើយ... តែមិនអីទេ! កូននឹងរឹងមាំជំនួសម៉ាក់! កូននឹងពង្រីករបរនេះឱ្យធំ!

ខ្ញុំចាប់ផ្ដើមលើកស្លាកយីហោនៅមុខផ្ទះដោយដាក់ថា«ឧត្តមាលក់គេសដ្ឋ:» ហើយរឿងបន្ទាប់ដែលខ្ញុំធ្វើគឺបង្វិលស្រាបៀរនិងគ្រឿងស្រវឹងឱ្យដេប៉ូធំគេវិញ និងឈប់លក់វាទៀត។ ម៉ាក់មិនសូវសប្បាយចិត្តនឹងជម្រើសខ្ញុំទេ ដែលមិនសប្បាយចិត្តក៏ព្រោះម៉ាក់ខ្លាចដាច់ម៉ូយ បាត់ចំណូលប៉ុណ្ណោះ ប៉ុន្តែខ្ញុំបានអះអាងចំពោះម៉ាក់ថាចំណូលយើងនឹងកើនទ្វេដង។ ដកស្រាមួយមុខ តែខ្ញុំបន្ថែមគ្រឿងទេសរាប់សិបមុខទៀត! ដូច្នេះ ម៉ាក់ក៏គោរពការសម្រេចចិត្តរបស់ខ្ញុំ និងជូនពរឱ្យខ្ញុំរីកចម្រើន។ កាលមុនខ្ញុំស្គាល់កាតាប តែឥឡូវខ្ញុំស្គាល់អម្រែកជាមេគ្រួសារវិញម្ដង។ ខ្ញុំស្គាល់ហើយរសជាតិក្នុងនាមជាអ្នករ៉ាប់រងគ្រប់យ៉ាងក្នុងផ្ទះ! រ៉ាប់រងតាំងពីចំណាយអំបិល ស្ករ ប៊ីចេង រហូតដល់កាតព្វកិច្ចធំៗ។ ហត់ណាស់! តែខ្ញុំនៅមានសង្ឃឹម!

រយៈពេល៦ឆ្នាំមកនេះ ខ្ញុំមានម៉ូយច្រើន។ ខ្លះទិញដុំ ដើម្បីយកទៅលក់បន្តទៀតផង។ ខ្ញុំចេះប្រើទូរសព្ទ ចេះប្រើបណ្ដាញសង្គម ខ្ញុំចេះផ្សព្វផ្សាយ ចេះធ្វើទីផ្សារ ដោយផ្តល់នូវការរៀបដាកញ្ចប់អីវ៉ាន់បើកតូបចាប់ហួយ សម្រាប់អ្នកចង់សាកល្បងលក់ដូរជំហានដំបូង ហើយមានអ្នកចាប់អារម្មណ៍ទិញដើម្បីយកទៅលក់បន្តនៅខេត្តផ្សេងៗ។ ខ្ញុំលក់ចំណេញតិច តែដាច់ច្រើន ហើយសប្បាយចិត្តក៏ច្រើនដូចគ្នា។

ក្នុងពេល ៦ឆ្នាំនេះ បើធៀបជីវភាពរបស់ខ្ញុំនិងមិត្តខ្ញុំដែលបានរៀននៅថ្នាក់ឧត្តមសិក្សា ខ្ញុំមិនចាញ់ពួកគេឡើយ! នេះមិនទាន់គិតដល់ថ្ងៃចំណាយរាប់ពាន់ដុល្លារលើការចាក់ថ្នាំគីមីរបស់ម៉ាក់ផង។ អ្វីដែលរឹតតែពិសេសទៀតនោះគឺ ម៉ាក់យកឈ្នះជំងឺមហារីក និងការព្យាបាលដោយការចាក់គីមីនោះបានហើយ! ម៉ាក់ដុះសក់ឡើងវិញ ហើយក៏ចាប់ផ្តើមមានសាច់មានឈាមឡើងវិញដែរ។

ត្រលប់មកបច្ចុប្បន្នកាលវិញ...

រម្ភើករឿងរ៉ាវចាស់ៗ ខ្ញុំស្រក់ទឹកភ្នែករាល់លើក ហើយលើកនេះក៏ដូចគ្នា! ខ្ញុំឈប់ស្រមៃ ហើយសម្លឹងមើលដើមពុទ្រាអនុស្សាវរីយ៍នោះវិញ ហើយនិយាយទៅកាន់ប៉ាក្នុងចិត្ត។

ប៉ា! កូនសុំទោសណា៎! កូនបានបំពានសន្យា កូនបានឈប់រៀន តែកូនធានាថា ម៉ាក់នឹងមានអាយុវែង! ជេដ្ឋានិងមុទិតា នឹងបានរៀនចប់បណ្ឌិតដូចដែលប៉ាធ្លាប់ប៉ង! ពួកគេនឹងក្លាយជាធនធានសំខាន់សម្រាប់ជាតិ។

ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់... កូនក្លាយជាអ្នកលក់ចាប់ហួយដូចម៉ាក់ ចំណែកជេដ្ឋានិងមុទិតានឹងបានរៀនសូត្រកាន់តែខ្ពង់ខ្ពស់ដូចប៉ា។ សង្ឃឹមថាប៉ានឹងមិនបន្ទោសកូន... ហើយមានមោទនភាពលើកូនវិញ!

.........................................

អាចរាប់ថា ថ្ងៃនេះជាថ្ងៃដ៏ទំនេរបំផុតសម្រាប់អ្នករកស៊ីលក់ដូរដូចជាខ្ញុំ ព្រោះខ្ញុំទុកការងារឱ្យចន្ទ្រាជួយគ្រប់គ្រង ចំណែកខ្ញុំឆ្លៀតមកអង្គុយសរុបបញ្ជីលក់ដូរផង និងសម្រាកលម្ហែផងនៅលើអង្រឹងចងក្រោមដើមស្វាយដែលមានម្លប់ត្រឈៃក្រោយផ្ទះ និងមានសត្វចាបកំពុងយំកំដរ។

ឱត្តមា! ហេតុអ្វីក៏ឯងស្តាប់ចាបយំហើយ បែរជាមានអារម្មណ៍ធូរស្បើយទៅវិញ? ហេតុអ្វីទៅជាមានក្តីសុខពេលដែលវាកំពុងយំ? អ្នកស?

ខ្យល់បក់ត្រសៀកៗ ខ្ញុំគេងយោលអង្រឹងដែលចងក្រោមដើមស្វាយ ដៃកាន់ទូរសព្ទពិនិត្យមើលបញ្ជីអីវ៉ាន់ ហើយយូរៗម្តង ខ្ញុំងាកទៅលើចុងស្វាយលួចសម្លឹងមើលសត្វចាបផ្លោះពីមែកមួយទៅមែកមួយៗ។

«បងម៉ា!» សំឡេងចន្ទ្រាបន្លឺឡើងៗ ខ្ញុំងើយសម្លឹងមើលមុខនាង ដែលតក់ស្លុត ហើយរត់ញាប់ជើងមកកាន់ខ្ញុំ។ របៀបលើកដាក់សំឡេងរបស់ចន្ទ្រាមិនខុសអីរបៀបលើកដាក់សំឡេងរបស់ជេដ្ឋា នៅថ្ងៃដែលម៉ាក់ដួលសន្លប់កាលពី៦ឆ្នាំមុននោះទេ។ ខ្ញុំបុកពោះភឹប តែប្រញាប់សួរបន្ទប់ ព្រោះក្រែងវាមិនមែនជារឿងរន្ធត់ចិត្តដូចខ្ញុំគិត។

«មានអីមែនចន្ទ្រា?»

«បងម៉ា! បងទៅក្នុងផ្ទះបន្តិចបានទេ? មានរឿងហើយ!» ចន្ទ្រាធ្វើទឹកមុខបារម្ភ ធ្វើឱ្យខ្ញុំកាន់តែព្រួយចិត្ត។ ខ្ញុំប្រញាប់រត់ញាប់ជើងទៅខាងក្នុងផ្ទះតាមពីក្រោយចន្ទ្រា។ ពេលទៅដល់ឃើញម៉ាក់និងមុទិតាឈរឱបជេដ្ឋាដែលជាប្អូនកណ្តាល។

«មានរឿងអី?» ខ្ញុំសួរញ័រមាត់ ត្រៀមចិត្តទទួលយកដំណឹងរន្ធត់។

គ្រប់គ្នាងាកមកខ្ញុំដោយទឹកភ្នែករលីងរលោង តែលាយឡំនឹងទឹកមុខរីករាយ។ ជាស្អីឱ្យប្រាកដ? ខ្ញុំអន្ទះអន្ទែងចង់ដឹងចម្លើយ។

«ជេដ្ឋាបានអាហារូបករណ៍ទៅរៀននៅស្វីសហើយ!» ម៉ាក់និយាយផងយំផង។

«បងអានទៅ!» ជេដ្ឋាកាន់ក្រដាសមួយសន្លឹកហុចមកឱ្យខ្ញុំ។

ខ្ញុំទទួលក្រដាសពីដៃប្អូន ហើយយកមកមើល។ សុទ្ធតែអក្សរអង់គ្លេស! ខ្ញុំខានរៀនយូរឆ្នាំហើយ ភាសាអង់គ្លេសក៏មិនដែលប្រើដែរ តែខ្ញុំអាចកាត់ន័យយល់បានថាវាជាលិខិតចេញពីសាលា

មួយនៅប្រទេសស្វីស ដែលបញ្ជាក់ថាជេដ្ឋាប្អូនប្រុសខ្ញុំនឹងទទួលបានការសិក្សាឥតបង់ថ្លៃរយៈពេល៤ឆ្នាំនៅទីនោះ។ អ៊ីចឹងតើបានជាម្នាក់ៗហូរទឹកភ្នែករហេមរហាម រួមទាំងខ្ញុំដែរ។ ខ្ញុំញញឹមផង យកដៃម្ខាងជូតទឹកភ្នែកផង ប្រើដៃម្ខាងទាញខ្លួនប្អូនប្រុសមកឱបផង។ ម៉ាក់និងមុទិតាចូលមកឱបពួកយើងជុំគ្នាដែរ។

ទីបំផុត ប្អូនប្រុសដ៏ពូកែរបស់ខ្ញុំធ្វើបានហើយ! គេគឺជាកូនប្រុសម្នាក់គត់ក្នុងគ្រួសារដែលសុទ្ធតែនារី តែគេមិនដែលធ្វើឱ្យម៉ាក់ ខ្ញុំ ឬប្អូនស្រីខ្ញុំ ស្រក់ទឹកភ្នែកទេ ទើបតែថ្ងៃនេះឯង ដែលយើងតមមិនយំមិនបាន។ ខ្ញុំគិតភ្លាមទៅដល់សំឡេងចាបយំដែលខ្ញុំបានឮមុនហ្នឹង ព្រោះខ្ញុំដឹងហើយថាហេតុអ្វីពេលវាយំ ខ្ញុំបែរជាស្ដាប់ហើយមានក្ដីសុខ គឺអាចមកពីវាមិនមែនកំពុងយំទេ តែវាកំពុងតែច្រៀងលេងសប្បាយក៏ថាបាន។ ដូចគ្រួសារយើងពេលនេះអ៊ីចឹង យើងមិនមែនយំទេ គឺយើងកំពុងតែរំភើបនិងមានមោទកភាពលើ សុជា ជេដ្ឋា ដែលជាកូនប្រុសតែមួយគត់នៃត្រកូលសុជា កូនប្រុសដែលស្គាល់កិត្តិយសនិងក្ដីសង្ឃឹមគ្រួសារ។

........................................

អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ...

ម៉ាក់ឱបជេដ្ឋាមិនលែង ព្រោះខ្វះតែពីរម៉ោងទៀតទេ ជេដ្ឋានឹងត្រូវឃ្លាតពីយើងទៅកាន់ប្រទេសស្វីសហើយ។

«ថែខ្លួនផងណាកូន! នៅនោះត្រជាក់ណាស់!» ម៉ាក់ផ្ដាំ។

«ដឹងហើយម៉ាក់! ម៉ាក់និយាយប្រាំដងហើយតាំងពីផ្ទះមក!»

«បងជេដ្ឋាចាំអូនផងណា! ចាំមើលអូនរៀនយកអាហារូបករណ៍ទៅស្វីសដូចបងជេដ្ឋាដែរ!» មុទិតាអះអាងពីគោលដៅរបស់នាង ដោយសារតែឆ្នាំនេះនាងរៀនថ្នាក់ទី១១ហើយ ដូច្នេះពេលចប់ទី១២ នាងក៏អាចដាក់ពាក្យប្រឡងបានដូចគ្នា។ ឆ្នាំនេះមុទិតាអាយុ១៦ឆ្នាំហើយ តែចរិតនៅញ៉ិកញ៉ក់ដូចកូនក្មេង ព្រោះអាងថាខ្លួនជាកូនពៅដែលតូចជាងគេនៅក្នុងផ្ទះ។

«ដឹងហើយមុទិតានារីជើងខ្លាំង! ខ្លាំងគ្រប់រឿង! តាំងពីរឿងរៀនរហូតដល់រឿងតមាត់!» ជេដ្ឋាសរសើរហើយឆ្លៀតញោះប្អូនពៅ។ ខ្ញុំនិងម៉ាក់បានត្រឹមសើចព្រោះឃើញមុទិតាធ្វើមុខក្រញូវ។

«កុំសូវតមាត់នឹងបងតៈម៉ាពេក! ពេលបងប្រើធ្វើខ្វះផង! ពេលទំនេរ បើមិនរៀនកុំសំងំក្នុងបន្ទប់! ឆ្លៀតចេញមកជួយលក់ដូរបងតៈម៉ាផង!» ជេដ្ឋាប្រដៅប្អូនស្រីពៅបន្ថែម។

«បងតៈម៉ាក់ជួលបងជេដ្ឋាប៉ុន្មាន បានជាគាត់ខំប្រដៅអូនម៉េះ?» មុទិតាងាកមកសួរខ្ញុំ។

«បងសុំមិនពាក់ព័ន្ធនឹងសង្គ្រាមកូនពៅនិងកូនបន្ទាប់ពៅទេ!» ខ្ញុំប្រកែកយករួចខ្លួន។ ម៉ាក់សម្លឹងមកពួកយើងទាំងបី ទាំងញញឹមបិទមាត់មិនជិត។ ខ្ញុំដឹងថាម៉ាក់លួចមានមោទកភាពលើពួកយើងដែលពួកយើងសុទ្ធតែជាកូនល្អ ល្មមតែអ្នកជិតខាងច្រណែននឹងវាសនាម៉ាក់បាន។

«អ៊ីចឹង... ខ្ញុំទៅខាងក្នុងហើយ! គេឱ្យពួកយើងជួបជុំគ្នានៅខាងក្នុង!» ជេដ្ឋាពោលឡើង។

«ទៅចុះកូន! សូមព្រះនិងប៉ាកូនតាមថែកូន!»

ម៉ាក់ឱ្យពរបន្ថែម។

"កុំប្រញាប់លួចស្រលាញ់កូនគេ!" មុទិតាចម្អន់ ជេដ្ឋាប្រានក្បាលប្អូនដោយក្នាញ់។ មើលទៅមុទិតាហាក់ដូចដឹងថាជេដ្ឋាមានមិត្តស្រីហើយបានជាមួយរយៈនេះឧស្សាហ៍ចម្អន់បងប្រុសគេណាស់។

"កុំចេះដឹងរឿងមនុស្សធំ!" ជេដ្ឋាបន្ទោស។

"ជេដ្ឋាចូលទៅក្នុងចុះ! មិនអ៊ីចឹងមិនចប់ទេ! នៅឈ្លោះជាមួយកូនពៅរហូតហ្នឹង!" ខ្ញុំប្រាប់ជេដ្ឋាតែក្នុងន័យចម្អន់មុទិតា។ ឃើញអត់? ពេលនេះកូនពៅចង់មុខចូលគ្នាទៀតហើយ!

"បាទ!" ជេដ្ឋាងក់ក្បាល ហើយគេងាកទៅម៉ាក់ រួចលត់ជង្គង់សំពះម៉ាក់បីដង។ ម៉ាក់រំជួលចិត្តដល់ស្រក់ទឹកភ្នែក តែគាត់ប្រញាប់ជូតភ្លាមៗ។ ខ្ញុំវិញក៏ព្យាយាមទប់ទឹកភ្នែកដែរ។ ជេដ្ឋាក្រោកឈរឱបម៉ាក់ រួចគេងាកមកខ្ញុំម្តង។ ភ្លាមៗ គេក៏លត់ជង្គង់ចុះ ក្រាបថ្វាយបង្គំខ្ញុំដូចគ្នា។ ខ្ញុំហាក់ភ្ញាក់ផ្អើលធ្វើខ្លួនមិនត្រូវ ព្រោះមិនដែលស្រមៃថាខ្លួនឯងត្រូវបានប្អូនទុកជាចាស់ទុំអីនោះទេ។ ខ្ញុំប្រុងទាញប្អូនឱ្យក្រោក តែម៉ាក់ឃាត់ ដូច្នេះខ្ញុំក៏នៅចាំប្អូនថ្វាយបង្គំគ្រប់បីដងសិន ទើបគេក្រោកឡើងឱបខ្ញុំ។

"សម្រាប់ខ្ញុំ... បងប្រៀបដូចជាប៉ាអ៊ីចឹង!" ជេដ្ឋាពោលទាំងឱបខ្ញុំនៅឡើយ។ ខ្ញុំឮពាក្យរបស់ប្អូនហើយ ទឹកភ្នែកដែលខំទប់មុននេះទាំងប៉ុន្មានក៏ហូរមកដោយគ្មានឧបសគ្គ។

"អម្រែកនេះធ្ងន់ណាស់! តែបងធ្វើបាន! អរគុណសម្រាប់ការលះបង់របស់បង! ការពិត បើប៉ាមិនចាកចេញ អ្នកដែលត្រូវលាគ្រួសារទៅរៀននៅក្រៅប្រទេសគួរតែជាបងត:ម៉ា!" ជេដ្ឋានិយាយបន្ថែមទៀត។ ខ្ញុំយំកាន់តែខ្លាំង ខ្លាំងដល់ថ្នាក់អ្នកដំណើរឯទៀតមើលមុខៗ ភាពទន់ជ្រាយស្រាប់តែសណ្ឋិតក្នុងខ្លួនខ្ញុំមួយរំពេច ទប់មិនជាប់! រាប់តាំងពីគ្មានប៉ាមក នេះគឺលើកដំបូងដែលខ្ញុំយំមិនខ្មាសគេឯង ខ្ញុំយំព្រោះខ្ញុំស្តាយសមត្ថភាពខ្លួនឯង ខ្ញុំយំព្រោះខ្ញុំបានលះបង់ជីវិតយុវវ័យរបស់ខ្លួនឯង ហើយដើរតួជាមេគ្រួសារជំនួសប៉ា។

ជេដ្ឋាលែងខ្លួនខ្ញុំ។ គេជូតទឹកភ្នែកឱ្យខ្ញុំ៖

"ខ្ញុំមានសំណាងណាស់ដែលកើតមកជាប្អូនរបស់បង!"

ខ្ញុំញញឹមអង្អែលក្បាលប្អូន ហើយបង្គាប់៖

"ទៅចុះ! មិត្តភក្តិអូនឯងកំពុងរង់ចាំ!"

"លាហើយ!"

ជេដ្ឋាបក់ដៃលាដាក់ពួកយើង ហើយរុញវ៉ាលិសចូលទៅខាងក្នុង។ ខ្ញុំឈរសម្លឹងប្អូនរហូតផុតកន្ទុយភ្នែក ហើយគិតពីពាក្យសម្តីប្អូនមិនឈប់។ សម្តីរបស់គេហាក់ដូចជាធ្វើឱ្យខ្ញុំភ្ញាក់ខ្លួន ហើយនឹកដល់ភាពជាយុវវ័យរបស់ខ្លួនជាខ្លាំង។

"ត:ម៉ាមែន?" សំឡេងប្រុសម្នាក់លាន់ឡើងក្បែរពួកយើង។ ទាំងខ្ញុំ ទាំងម៉ាក់ ទាំងមុទិតា ងាកស្រតាមមើលម្ចាស់សំឡេង។ គេជាបុរសម្នាក់រាងខ្ពស់ មាឌមាំ សម្បុរសណ្តែកបាយ សក់រួញក្ងីធំ ស្នាមញញឹមគេបង្ហាញនូវធ្មេញដែលដុះស្មើនិងសស្អាត បញ្ជាក់ថាគេជាមនុស្សដែលយកចិត្តទុកដាក់លើការថែទាំធ្មេញ។ ខ្ញុំមើលគេហើយ មើលទៀត នៅតែរកនឹកមិនឃើញថាគេជាអ្នកណា ហេតុអីក៏ស្គាល់ឈ្មោះខ្ញុំ។

"ចាស...!" ខ្ញុំឆ្លើយស្ទាក់ស្ទើរ មុននឹងសួរបន្ត "យើងធ្លាប់ស្គាល់គ្នា?"

«ខ្ញុំគឺវិសុទ! អតីតកូនសិស្សលោកគ្រូសុជា! កាលនោះធ្លាប់ទៅរៀនដល់ផ្ទះលោកគ្រូ ម៉ោងចេញលេងជួយលក់ចាប់ហួយទៀតអ្ហ!»

វិសុទ? អូ! មែនហើយ ឯក វិសុទ! គាត់អាយុបងខ្ញុំបីបួនឆ្នាំ។ កាលនោះខ្ញុំអាយុប្រហែលប្រាំបីប្រាំបួនឆ្នាំ ហើយប៉ានៅបង្រៀនចំណេះទូទៅតាមផ្ទះនៅឡើយ។ ម៉ាក់បងវិសុទតែងតែដឹកគាត់មកផ្ទះខ្ញុំរាល់ព្រឹកដើម្បីឱ្យប៉ាបង្រៀន។ ពេលសម្រាកគាត់តែងតែជួយលក់អីវ៉ាន់ម៉ាក់ខ្ញុំ ដើម្បីម៉ាក់បានបញ្ចុកបបរអូនជេដ្ឋា ព្រោះជេដ្ឋាទើបតែអាយុ២ឆ្នាំជាងនៅឡើយ។ ចួនកាល បងវិសុទក៏មកលេងបាយឡុកបាយឡ ឬគូរគំនូរជាមួយខ្ញុំដែរ។ គាត់ហ្នឹងហើយដែលបង្រៀនខ្ញុំជិះកង់ តែខ្ញុំសងគាត់វិញដោយចម្អន់ ដោយសារតែគាត់អាយុលើស១០ឆ្នាំហើយទើបតែបាក់ធ្មេញទឹកដោះ។ ពេលសើចម្ដងៗ ឃើញចន្លោះធ្មេញ គួរឱ្យចង់សើចណាស់! មកពីបែបហ្នឹងទេដឹង បានជាធ្មេញគាត់ឥឡូវស្អាតណាស់។ កាលនោះរៀនជាមួយប៉ាបានមួយឆ្នាំ បងវិសុទក៏ប្ដូរផ្ទះទៅរស់នៅក្នុងខណ្ឌផ្សេង និងមិនអាចទៅរៀននៅផ្ទះខ្ញុំទៀតទេ។

«ខ្ញុំចាំបងហើយ!» ខ្ញុំតបៗ

តមក... ការសន្ទនារវាងខ្ញុំ ម៉ាក់ និងបងវិសុទក៏កើតមានជាហូរហែ។

.......................................

នៅវត្តមួយកន្លែងក្នុងខេត្តកំពង់ចាម...

បងវិសុទលុតជង្គង់អុជធូបនៅមុខចេតិយដែលមានថ្មម៉ាបឆ្លាក់អក្សរថា «ឧទិសជូនលោកឪពុកកន សុជា»។ ខ្ញុំឈរនៅកៀនម្ខាងនៃចេតិយនេះ។ បងវិសុទសួររកអតីតលោកគ្រូរបស់គាត់ ដូច្នេះខ្ញុំក៏ឆ្លៀតពេលជូនគាត់តាំងពីភ្នំពេញ មកលេងលោកគ្រូរបស់គាត់ដល់ស្រុកកំណើត។

បងវិសុទទៅរស់នៅបរទេសជិត១០ឆ្នាំហើយ នៅទីនោះគាត់ធ្វើជាអ្នកអភិវឌ្ឍវិបសាយម្នាក់។ អុជធូបរួច គាត់ក៏ក្រោកឈរឡើងដោយទឹកមុខស្រងូតស្រងាត់។

«បើបងបានមករកលោកគ្រូតាំងពី៦ឆ្នាំមុន...» គាត់និយាយក្នុងន័យសោកស្ដាយ។

«បើមករកប៉ាចំថ្ងៃបុណ្យ បងចូលមិនចុះទេ! កូនសិស្សគាត់ឡើងណែនរោងបុណ្យអ្ហ!»

«មកពីលោកគ្រូ មានសិស្សស្រលាញ់ច្រើន...»

«មែនហើយ... ព្រោះតែស្រលាញ់ទើបពេលបាត់បង់ទៅ កាន់តែសោកស្ដាយ!»

«លោកគ្រូបងពូកែណាស់!»

«មកពីអ៊ីចឹងបានម៉ាក់ស្រលាញ់!»

«ពូកែត្រង់អប់រំកូនៗបានយ៉ាងល្អ!»

«ខ្ញុំទទួលយកពាក្យសរសើរហ្នឹងចុះ!» ថាហើយខ្ញុំសើចស្ញេញ។ បងវិសុទញញឹម។

«រូបគំនូរនោះដួលគេគូរមែន? ស្អាតណាស់!» បងវិសុទសួរ ហើយភ្នែកសម្លឹងទៅរូបគំនូររបស់ប៉ាដែលតាំងនៅលើជញ្ជាំង។ ស្នាមញញឹមស្រគត់ស្រគំរបស់ប៉ានៅក្នុងគំនូរប្រេងដែលជាស្នាដៃចុងក្រោយបំផុតរបស់ខ្ញុំនោះ ហាក់ដូចជាបណ្ដាសាដែលតាមដេរស្ដីខ្ញុំគ្រប់ពេល។ ដេរស្ដីដែលខ្ញុំបោះបង់ការសិក្សាបោះបង់អ្វីដែលខ្លួនស្រលាញ់។

«ភ្លេចហើយបង!» ខ្ញុំធ្វើពើ ព្រោះមិនចង់ឱ្យបងវិសុទសួរនាំច្រើន។

«និយាយអ៊ីចឹង... ធ្វើជាអ្នកបង្កើតវិបសាយនៅអាមេរិករកលុយបានច្រើនណាស់! ហេតុអីក៏បងចង់រស់នៅស្រុកខ្មែរវិញ?» ខ្ញុំសួរ ហើយដើរសំដៅទៅបង់អង្គុយនៅក្រោមដើមពោធិ៍ផង។

«ព្រោះនឹកដល់ពាក្យលោកគ្រូ!»

«ពាក្យរបស់ប៉ា? ប៉ាខ្ញុំហ្នឹង?» ខ្ញុំសួរដោយភ្ញាក់ផ្អើល។

«មែនហើយ! លោកគ្រូធ្លាប់ប្រាប់ថា រស់នៅកន្លែងណាក៏ដោយ គឺជាជម្រើស! តែបើអាចជួយសង្គមជាតិដែលជាទីកំណើតខ្លួន ទោះតិចឬច្រើន គឺជាគុណធម៌!»

«ប៉ាធ្លាប់និយាយអ៊ីចឹងឬ?»

«កុំប្រាប់ណាថា លោកគ្រូមិនដែលផ្ដាំអ៊ីចឹង?» បងវិសុនសួរបកមកវិញ។ ខ្ញុំគ្រវីក្បាលជំនួសចម្លើយ ព្រោះទោះប៉ាធ្លាប់ប្រាប់ខ្ញុំអ៊ីចឹងមែន ក៏ខ្ញុំចាំមិនបានដែរ។ ខ្ញុំចាំតែថា ខ្ញុំបានសន្យាជាមួយប៉ាថាទោះមានរឿងអ្វីកើតឡើងក៏ដោយ ក៏មិនឈប់រៀន ហើយខ្ញុំក៏បំពេញសន្យានោះមិនបានដល់សព្វថ្ងៃ។

«នឹកដល់ប្រសាសន៍លោកគ្រូ... បងក៏ចាប់ផ្ដើមគិត ហើយយល់ថា ខ្លួនឯងក៏មានសមត្ថភាព តែប្រើសមត្ថភាពនោះទៅជួយសាសន៍ដទៃទៅវិញ! ចុះពេលណាទើបបងអាចជួយខ្មែរ? បងគេងគិតរាល់ថ្ងៃ ហើយក៏សម្រេចថាត្រលប់មកខ្មែរវិញ! បងគួរតែធ្វើអីម្យ៉ាងដែលអាចជួយដល់លផលិតផលខ្មែរ តែមិនទាន់ច្បាស់ថាគួរចាប់ផ្ដើមពីផលិតផលណាមួយនៅឡើយទេ!»

«ជិត១០ឆ្នាំហើយ... បងនៅតែអាចត្រលប់មកវិញហ្ន?»

«១០ឆ្នាំក៏ដោយ... ២០ឆ្នាំក៏ដោយ! ឱ្យតែនៅមានបំណងប្រាថ្នាដែលត្រូវសម្រេច មានរឿងដែលត្រូវធ្វើ វានឹងមិនយឺតពេលនោះទេ!»

«អូ...» ខ្ញុំឆ្លើយខ្លី ព្រោះមិនពូកែសម្ដីស្រាប់ហើយ។ បន្តិចក្រោយមក យើងដើរមកដល់បង់ក្រោមដើមពោធិ៍ ម៉ាក់និងមុទិតាទើបតែកាន់ចានស្រាក់ចុះពីលើសាលាឆាន់ហើយដើរសំដៅមកកាន់ពួកយើងដែរ។ ថ្ងៃនេះខ្ញុំបណ្ដោយឱ្យចន្ទ្រាចាំតូបមួយថ្ងៃ ដោយសារតែកៀកភ្ជុំហើយ មិនសូវមានមនុស្សមកទិញអីវ៉ាន់នោះទេ។ ខ្ញុំចំណាយពេលពេញមួយថ្ងៃ នាំបងវិសុនដើរលេងនៅស្រុកកំណើតរបស់ប៉ា ហើយយូរៗម្ដងខ្ញុំមើលកាមេរ៉ាសុវត្ថិភាពតាមទូរសព្ទដៃ ដើម្បីមើលស្ថានភាពផ្ទះលក់ដូរ តែលើកនេះ ខ្ញុំស្រាប់តែបានឃើញរឿងរន្ធត់ចិត្តមួយទៅវិញ។

.........................................

«ម៉ាក់អារម្មណ៍មិនស្រួលសោះ! សង្ស័យតែចន្ទ្រាធ្វើរឿងអីមិនល្អទេ!» ម៉ាក់រអ៊ូតិចៗ ខណៈពួកយើងឈរនៅក្រៅផ្ទះ។

ពេលនៅវត្ត ក្រោយបានមើលកាមេរ៉ាសុវត្ថិភាពឃើញចន្ទ្រាស្ពាយកាតាបខោអាវរបស់នាងចាកចេញ ខ្ញុំទាក់ទងទៅនាងភ្លាម តែទាក់ទងនាងមិនបាន ដូច្នេះខ្ញុំក៏រូតរះមកផ្ទះវិញភ្លាមៗ។ ពេលមកដល់ឃើញទ្វារចាក់សោពីក្រៅ ហើយមេសោនោះជាមេសោថ្មី ដែលអ្នកផ្ទះខ្ញុំគ្មានកូនសោចាក់ឡើយ។ បងវិសុនផ្ទោះរបងដើម្បីរកប្រដាប់ប្រដានៅក្រោយផ្ទះដើម្បីមកកាត់មេសោ។ បានបន្តិចបងវិសុនបានផ្ទោះរបងចេញមកវិញដោយកាន់ញញួរនិងដែកគាស់ឡើងច្រែះមួយ។ មិនប៉ុន្មាន

នាទីផង បងវិសុនក៏អាចវាយមេសោនោះឱ្យបើកបាន។

ពួកយើងចូលទៅក្នុងផ្ទះ ឃើញថាអីវ៉ាន់ពុំមានបាត់អ្វីនោះទេ។ ដៃខ្ញុំនៅតែព្យាយាមទាក់ទងទៅចន្ទ្រា ព្រោះខ្ញុំនៅមានកូនចិត្តមួយគិតថា ប្រហែលជានាងមានការបន្ទាន់ត្រូវទៅស្រុកកំណើតទេដឹង។

«ទាក់ទងបានទេ?» បងវិសុនសួរខ្ញុំ។

«អត់បានទេ!»

«ខ្ញុំឃើញបងចន្ទ្រាលីបលៗក្បែរតុដាក់លុយរបស់បងត:ម៉ាប៉ុន្មានថ្ងៃហើយ តែមិនចាប់អារម្មណ៍ព្រោះក្រែងបងត:ម៉ាឱ្យយកលុយអាប់!» មុទិតាលើកឡើង។ ខ្ញុំដើររឹងទៅរកតុដាក់លុយ តែមិនឃើញសូម្បីតែមួយរយរៀលលុយខ្មែរ។ ថ្លើមខ្ញុំធ្លាក់ក្ដុកនឹកតូចចិត្តក្អែត! ថាព្រហ្មលិខិតទៅ ធ្វើបាបខ្ញុំ ចុះហេតុអីមនុស្សដែលខ្ញុំទុកចិត្តបំផុត អាចធ្វើបាបខ្ញុំបានដែរ?

ការពិតខ្ញុំមិនបានស្ដាយលុយដែលបាត់ទៅនោះទេ តែខ្ញុំស្ដាយអនាគតរបស់ចន្ទ្រា។ ខ្ញុំបានគិតរួចហើយថាដើមឆ្នាំក្រោយ ខ្ញុំនឹងឱ្យចន្ទ្រាទៅរៀនជំនាញសម្ផស្ស ព្រោះនាងធ្លាប់ប្រាប់ខ្ញុំថាថ្ងៃអនាគតទៅនាងចង់បើកកូនហាងធ្វើសក់និងតុបតែងកាយមួយនៅស្រុកកំណើតរបស់នាង។ ខ្ញុំនឹងផ្ដល់ដើមទុននិងទំនុកបម្រុងនាង! ដ្បិតថាខ្ញុំត្រូវការនាងឱ្យជួយការងារខ្ញុំ តែខ្ញុំមិនចង់កំណត់អនាគតនាងឱ្យនៅទ្រឹងត្រឹមខ្ញុំនោះទេ។

«ខកចិត្តណាស់! មិនគួរជួបមនុស្សបែបនេះទេ!» ម៉ាក់រអ៊ូតិចៗ។

ញ៉ាំអាហារពេលល្ងាចរួច បងវិសុនមិនទាន់ត្រលប់ទៅផ្ទះវិញទេ គាត់នៅអង្គុយកំដរខ្ញុំនិយាយពីនេះពីនោះនៅលើកៅអីក្បែរដើមពុទ្រា ខណៈម៉ាក់និងមុទិតាចូលសម្រាកក្នុងបន្ទប់រៀងខ្លួនហើយ។ ខ្ញុំសម្រេចចិត្តថាមិនប្ដឹងផ្ដល់អ្វីទាំងអស់ ព្រោះលុយមិនបានបាត់បង់ច្រើន គ្រាន់តែការខកចិត្តវាធំ!

«សម្រេចថា... មិនប្ដឹងប៉ូលិសទេរឿងចន្ទ្រាលួចលុយនោះ?» បងវិសុនសួរ។

«អត់ទេ! នាងក៏ដឹងថាខ្ញុំដាក់លុយនិងរបស់មានតម្លៃក្នុងទូដែកដែរ តែនាងមិនទម្លុះទូដែកនោះចាត់ទុកថានាងនៅគិតដល់ខ្ញុំហើយ! នាងលួចលុយលក់អីវ៉ាន់ថ្ងៃនេះ អាចមកពីនាងទាល់មែនទែនហើយ!»

«ចិត្តបុណ្យណាស់!» បងវិសុនចម្អន់។

«កុំឌឺខ្ញុំ! គិតតែបងទៅ!»

«គិតរឿងអី?»

«ធ្លាប់ធ្វើជាចោរគាស់ផ្ទះមែន បានជាវាយតែប៉ុន្មានប៉ូកសោះក៏របើកសោដែរ?»

«បងមិនមែនចោរគាស់ផ្ទះទេ! តែជាចោរលួច!»

«អ្ហាស?» ខ្ញុំបើកភ្នែកធំៗ ងាកសួរគាត់ដោយភិតភ័យ។

«លួចបេះដូងកូនស្រីគេ!» គាត់ឆ្លើយវិញយ៉ាងធូរ។ ខ្ញុំសម្លក់គាត់បែបក្នាញ់។

«កុំមកសម្លក់! សោខ្មៅងាយវាយបំបែកណាស់! កាលនៅផ្ទះចាស់ បងឧស្សាហ៍ភ្លេចសោផ្ទះ ហើយវាយបំបែកមេសោតែញយហ្នឹង!»

«អ្ហ!... ចុះលួចបានប៉ុន្មាននាក់ហើយ?»

«លួចអី?»

«លួចបេះដូងកូនស្រីគេហ្នឹង!»

«មិនទាន់បានម្នាក់ទេ! កំពុងរៀបផែនការ

លួច!»

«អ្ហូ...»

«ដើមនេះ មេស៊ីឡើងងាប់ហើយ! មើលចុះ សុទ្ធតែវល្លិគោងពេញហ្នឹង!» បងវិសុនលាន់មាត់ ហើយងើយទៅដើមពុទ្រា។

«ចាស! ងាប់ហើយ!»

«ហេតុអីមិនគាស់វាចេញ? ដើម្បីឱ្យដីទំនេរ អាចដាំអ្វីផ្សេងបាន?»

«ព្រោះដើមនេះ ប៉ាជាអ្នកដាំ!»

«ចុះមានសួរលោកគ្រូនៅថា ត្រូវតែទុកដើមពុទ្រានេះទោះបីជាវាងាប់ហើយ?»

«បងនិយាយចង់បានន័យថាម៉េច?»

«បងចង់បានន័យថា... កុំត្រាំត្រែងនឹងអតីតកាលយូរពេក នាំឱ្យខាតពេលធ្វើរឿងផ្សេងច្រើនជំពូកទៀត ដែលយើងចង់ធ្វើ!»

«ខ្ញុំគ្មានរឿងអីដែលចង់ធ្វើផង! គ្រាន់តែចង់បានលុយឱ្យច្រើនៗ...» ខ្ញុំឆ្លើយហី។

«ពិតមែន?»

«មែន!»

«ចុះនេះ?» គាត់ស្រាប់តែហុចថង់ខ្មៅមួយឱ្យខ្ញុំ។

«ស្អីគេហ្នឹង?» ខ្ញុំសួរដោយសង្ស័យ។

«មើលខ្លួនឯងទៅ!»

ខ្ញុំស្រាយថង់មើលតាមបញ្ជារបស់បងវិសុន។ អ្វីដែលខ្ញុំឃើញ ធ្វើឱ្យខ្ញុំបើកភ្នែកធំៗភ្ញាក់ផ្អើល។

«បានវាមកពីណា?» ខ្ញុំសួរបន្ទាន់។

«ពេលផ្ទោះរបងដើររកញញួរហ្នឹង ក៏ឃើញប្រអប់ហ្នឹង! ហើយក៏ដឹងភ្លាមថា អ្នកខ្វះកុហកបង!»

«កុហកអីគេ?»

«កុហកថាក្មេចជាងគូរគំនូរលោកគ្រូដែលតាំងនៅក្នុងចេតិយ! កុហកថាគ្មានរឿងអ្វីដែលចង់ធ្វើ!» គាត់និយាយដោយសម្លឹងមុខខ្ញុំចំៗ ធ្វើឱ្យខ្ញុំចុះចាញ់ក្រសែភ្នែកនោះ ហើយបេះដូងក៏ទន់ជ្រាយ ចង់និយាយពាក្យក្នុងចិត្តទាំងអស់ឱ្យគាត់ស្តាប់។ ការពិត ប្រអប់ដែលបងវិសុនហុចឱ្យមកនោះគឺជាប្រអប់ដាក់ជក់គំនូររបស់ខ្ញុំ។ វាប្រឡាក់ទៅដោយធូលីនិងកាន់ក្អែលដោយសារតែទុកវាចោលយូរឆ្នាំនៅក្រៅផ្ទះ។ ខ្ញុំស្ទើរតែភ្លេចអ្វីដែលខ្ញុំស្រលាញ់បំផុតទៅហើយ។

នៅយប់នោះ ខ្ញុំក៏សម្រេចចិត្តរ៉ាយរ៉ាប់នូវរឿងរ៉ាវក្នុងចិត្តដ៏ធ្ងន់កណ្តុកឱ្យបុរសម្នាក់ស្តាប់ ហើយបុរសម្នាក់នោះធ្លាប់ជាអ្នកបង្រៀនខ្ញុំជិះកង់ ជាអ្នកដែលកំដរខ្ញុំគូរគំនូរ អានសៀវភៅរឿងនិទាន និងជាអ្នកដែលគាស់កកាយក្តីស្រមៃដែលខ្ញុំកប់ចោលក្នុងអតីតកាលជាយូរមកហើយ។

«ជាអ្នកលក់អីវ៉ាន់ចាប់ហួយ មានអីមិនល្អ! តែបើគិតថាខ្លួនឯងអាចធ្វើអ្វីបានច្រើនជាងនេះ ម៉េចមិនសាកល្បង?» ក្រោយស្តាប់ខ្ញុំនិទានចប់ បងវិសុនក៏លើកឡើងបែបនេះ។

«សាក? សាកម៉េចទៅបង? ខ្ញុំខានចូលសាលាប្រាំមួយឆ្នាំជាងហើយ!»

«ខានចូលសាលាប្រាំមួយឆ្នាំ មិនមែនខានចូលមួយជីវិតឯណា! ទើបតែអាយុ២៣-២៤សោះ!»

«តែ... ខ្ញុំប្រហែលរៀនមិនចេះទេ!»

«នៅលើក្បាល ស្កូវប៉ុន្មានសរសៃហើយ?»

«មិនទាន់មានទេ!»

«សាស្ត្រាចារ្យបងទាំងអស់ សក់ស្កូវព្រាតហើយ តែថ្ងៃណាក៏គាត់អានសៀវភៅដែរ! ចាំថា

មានសាស្ត្រាចារ្យម្នាក់របស់បង មកដល់ឥឡូវទោះបីគាត់ចូលនិវត្តន៍ហើយក៏ដោយ ក៏គាត់នៅតែរៀនដែរ! ការសិក្សាមិនបានកំណត់អាយុមនុស្សទេ តែមនុស្សទេអ្នកកំណត់អាយុខ្លួនឯង! ត:ម៉ាគួរតែត្រលប់ទៅរៀនវិញ! រៀនជំនាញណាមួយដែលខ្លួនឯងស្រឡាញ់ អតិវឌ្ឍខ្លួនឯង ហោចណាស់ក៏អាចគ្រប់គ្រងការរកស៊ីឱ្យល្អជាងហ្នឹង កុំឱ្យបុគ្គលិកលួចលុយបានស្រួលៗ! រឿងខ្វះ មិនមែនយកការទុកចិត្តនិងមនោសញ្ចេតនាមកវាស់វែងទេ យើងត្រូវការទិន្នន័យច្បាស់លាស់មកវាស់វែង!»

«កំពុងប្រដៅមែន?»

«បាទ! ប្រដៅជំនួសលោកគ្រូរបស់បង!» គាត់និយាយញោះ ខ្ញុំដឹង តែក៏យល់ថាអ្វីដែលគាត់និយាយគឺគ្រាន់តែចង់ឱ្យខ្ញុំចាប់ផ្ដើមក្ដីស្រមៃរបស់ខ្លួនឯងឡើងវិញ។

«ត:ម៉ាខ្លួនតូច តែមានសមត្ថភាពពូកែ! គិតមើលទៅ! ក្លាយជាមេគ្រួសារនៅអាយុ១៧-១៨ឆ្នាំ រឿងអីគ្រាន់តែរៀនគូរគំនូរ រៀនមិនចេះ?»

«...» ខ្ញុំនៅស្ងៀម ស្ដាប់គាត់ប្រដៅ។

«អ្នកណាគេធ្លាប់ប្រាប់បង? គំនូរចម្លាក់គឺជាដួងព្រលឹងអីណាណីនោះ?» គាត់រម្ញឹក។

«គំនូរចម្លាក់មិនមែនជាការងារប៉ុណ្ណោះ តែជាដួងព្រលឹង!» ខ្ញុំកែពាក្យគាត់។

«ហ្នឹង! បងគិតថាត:ម៉ាគួរតែអាចបំពេញសន្យាជាមួយប៉ាយើងបានហើយ!»

«ប៉ាយើង? ប៉ាខ្ញុំទេ! មិនមែនប៉ាបងទេ!»

«គ្រូអាចារ្យជាឪពុកម្ដាយទីពីរដែរ! អ៊ីចឹងលោកគ្រូក៏ជាប៉ាបងដែរ!»

«ខ្ញុំមិនដែលឮប៉ាហៅបងថាកូនទេ! កុំមកបោក!»

«ថាមិនត្រូវ! ថ្ងៃក្រោយបងអាចក្លាយជាកូនប្រសាគាត់ផងក៏ថាបាន!»

«ថាម៉េច?» ខ្ញុំសួរគាត់ ទាំងអារម្មណ៍កាន់កាំង ហើយបេះដូងលោតញាប់ ព្រោះខ្ញុំមិនដែលឮពាក្យសារភាពអ្វីនោះទេ។ ជីវិតខ្ញុំកន្លងមកគឺមានតែ សៀវភៅ ប៊ិក គំនូរ អីវ៉ាន់ និងលុយៗ

«បងម៉ា...» សំឡេងនារីម្នាក់ដែលខ្ញុំស្គាល់ច្បាស់លាន់ឡើង ធ្វើឱ្យបងវិសុទខានបាននិយាយពាក្យបន្ត។ខ្ញុំនិងបងវិសុទងាកមើលទៅតាមប្រភពសំឡេង ឃើញចន្ទ្រានៅឈរជ្រងោៗ។ នាងស្លៀកសម្លៀកបំពាក់ដូចព្រឹកមិញដែរ សក់នាងរញ៉េរញ៉ៃដូចមិនបានរៀបចំ ហើយភ្នែកនាងពេញដាមដោយទឹកភ្នែក ដៃនាងទាំងគូលើកសំពះខ្ញុំរួចបាត់ទៅហើយ។

................................

២ឆ្នាំក្រោយមក....

ខ្ញុំឈរនៅមុខផ្ទះ សម្លឹងដើមពុទ្រាមួយដើមមានស្លឹកបៃតងខៀវមែកលាស់យ៉ាងល្អ។ វាដុះមិនឆ្ងាយប៉ុន្មានពីដើមពុទ្រាដែលប៉ាធ្លាប់ដាំឡើយ។ ដើមពុទ្រាដែលគ្មានជីវិតនោះ ត្រូវបានគាស់ចេញហើយ នៅពេលដែលគាស់ចេញ សម្អាតវល្លិ ទើបខ្ញុំឃើញមានពន្លកតូចៗនៃដើមពុទ្រាថ្មីកំពុងតែត្រដាបត្រដួសលូតលាស់។ ទោះបីដើមពុទ្រាចាស់ងាប់ លែងអាចផ្ដល់ផ្លែផ្កាអ្វីទៀត តែកូនពុទ្រាថ្មីនឹងលូតលាស់ មិនដាច់ពូជឡើយ។ ទោះបីប៉ាមិននៅ តែកូនៗរបស់ប៉ានឹងរឹងមាំ មិនឱ្យបាត់បង់តួនាទីជាកោសិកាសង្គមឡើយ។

ខ្ញុំបានចូលរៀនបន្តនៅមហាវិទ្យាល័យជំនាញទីផ្សារ និងឆ្លៀតពេលរៀនគូរគំនូរនៅសាលាដែលខ្ញុំធ្លាប់រៀន។ បងវិសុនបានចូលស្ដីដណ្ដឹងខ្ញុំ ហើយយើងនឹងរៀបការក្រោយពេលខ្ញុំចប់បរិញ្ញាបត្រ។ ខ្ញុំដឹងថាគាត់ចាប់អារម្មណ៍ខ្ញុំតាំងពីថ្ងៃដំបូងម្ល៉េះ ហើយពីរឆ្នាំមកនេះគាត់នៅតែយកចិត្តទុកដាក់ចំពោះខ្ញុំនិងគ្រួសារខ្ញុំ ព្រមទាំងលើកទឹកចិត្តឱ្យខ្ញុំរៀនទៀតផង។ អាចថា ខ្ញុំបញ្ច្រាសពីគេឯងបន្តិច! គេប្រឹងរៀនដើម្បីមានឱកាសរកលុយបានច្រើននៅថ្ងៃអនាគត ចំណែកខ្ញុំខំរកលុយឱ្យបានច្រើន ដើម្បីមានឱកាសរៀននៅថ្ងៃអនាគតវិញ។ យ៉ាងណាក៏ដោយ ទោះមានឬក្រ ការអប់រំនៅតែសំខាន់។

«ឧត្ដមាលក់ភេសជ្ជៈ» ត្រូវបានប្ដូរជា «ហាងទំនិញឧត្ដមា» វិញ ដោយសារខ្ញុំបានកែកុនផ្ទះឱ្យដូចជាម៉ាតទំនើបមួយ។ «ហាងទំនិញឧត្ដមា» មានគ្រប់យ៉ាងដូចផ្សារទំនើបដែរ តែនៅតែគ្មានលក់គ្រឿងស្រវឹងដដែល បែរជាមានរូបគំនូរលក់ទៅវិញ។ ខ្ញុំបានយកគំនូរពីវិចិត្រករខ្មែរចំណានៗ និងស្នាដៃរបស់មិត្តរួមថ្នាក់ខ្ញុំ យកមកដាក់តាំងលក់នៅក្នុងម៉ាត ហើយបងវិសុនក៏កំពុងតែបង្កើតវិបសាយមួយសម្រាប់លក់ស្នាដៃគំនូរទាំងនោះដែរ។ សិល្បៈត្រូវតែរស់ ទោះបីនៅក្នុងយុគបច្ចេកវិទ្យាឌីជីថលនិងយុគបញ្ញានិម្មិតឬដែលគេហៅថា AI នោះក៏ដោយ។ យើងត្រូវពឹងពាក់បច្ចេកវិទ្យា ដើម្បីឱ្យសិល្បៈរស់រានបានជាអមតៈ។ មូលហេតុដែលខ្ញុំរៀនជំនាញទីផ្សារ ព្រោះវានឹងជួយដល់ការងារគ្រប់គ្រងហាងទំនិញខ្ញុំ ហើយក៏ជួយដល់សិល្បៈគំនូរដែរ។ គ្រប់យ៉ាងសុទ្ធតែត្រូវការការធ្វើទីផ្សារ សូម្បីតែការគ្រប់គ្រងប្រទេសក៏ដោយ! ស្រលាញ់សិល្បៈតែម្នាក់ឯងមិនគ្រប់គ្រាន់ឱ្យសិល្បៈមួយនោះរស់នោះទេ យើងត្រូវផ្សព្វផ្សាយធ្វើទីផ្សារ ជំរុញឱ្យគ្រប់គ្នាស្រលាញ់សិល្បៈនោះដែរ។ មានឌីជីថល ពឹងឌីជីថល! មាន AI ពឹង AI! ក្នុងយុគសម័យណាក៏ដោយ ត្រូវតែបត់បែនតាមស្ថានការណ៍។

«បងម៉ា! នេះបញ្ជីស្តុកអីវ៉ាន់ដែលត្រូវកុម្ម៉ង់ថែម!» ចន្ទ្រាកាន់ក្រដាសមួយសន្លឹកហើយហុចឱ្យខ្ញុំ។ ខ្ញុំដកក្អែកពីដើមពុទ្រា ហើយសម្លឹងទៅចន្ទ្រាវិញ។ ឃើញនាង ខ្ញុំកាន់តែសរសើរខ្លួនឯងដែលអាចផ្ដល់ឱកាសឱ្យក្មេងស្រីម្នាក់បានកែខ្លួន។

កាលពីពីរឆ្នាំមុន ចន្ទ្រាពិតជាបានលួចលុយខ្ញុំទៅមែន។ នាងលួចព្រោះឪពុកនាងឈឺត្រូវចូលសង្គ្រោះបន្ទាន់! នាងថា បើសុំខ្ចីតាមសម្រួល ច្បាស់ជាម៉ាក់ខ្ញុំមិនព្រមទេ ព្រោះឪពុកនាងជាមនុស្សហិង្សា ហើយដែលគាត់ត្រូវចូលសង្គ្រោះបន្ទាន់ក៏ដោយសារតែរឿងផឹកស៊ីមិនគិតសុខភាពហ្នឹងដែរ។ ក្នុងនាមជាកូន អ្វីដែលនាងអាចធ្វើបាន នាងបានធ្វើអស់ហើយ! នាងហ៊ានសូម្បីតែលួចលុយថៅកែរបស់នាង។

«បងម៉ាធ្លាប់ប្រាប់ថា កាលប៉ាបងទើបស្លាប់ ហើយម៉ាក់បងធ្លាក់ខ្លួនឈឺ បងនៅជម្នះមិនលក់ស្រាបើទោះជាដឹងថារបរនោះចំណេញច្រើនក៏ដោយ! មនសិការបងនៅតែមាន បើទោះជាមានរឿងអ្វីកើតឡើងក៏ដោយ! ដូច្នេះហើយ ខ្ញុំក៏សម្រេចចិត្តថា យកលុយមកឱ្យបងវិញ! ព្រោះការលួចទ្រព្យគេ មិនមែនជាចរិតរបស់ខ្ញុំទេ! បងចង់ប្ដឹងប៉ូលិសក៏បាន តែខ្ញុំគ្រាន់តែចង់យកលុយមកសងបងវិញ ហើយសុំទោសបងប៉ុណ្ណោះ!» ទាំងនេះគឺជាសម្ដី

របស់ចន្ទ្រានៅយប់ដែលនាងត្រលប់មកចួបខ្ញុំវិញ។

ខ្ញុំបានផ្តល់ឱកាសឱ្យចន្ទ្រាកែខ្លួន ហើយនាងនៅតែបន្តធ្វើការជាមួយខ្ញុំដដែល។ នាងប្រាប់ថា នាងចង់រៀនពីរបៀបគ្រប់គ្រងការលក់ដូរដោយសារនាងចំណាយពេលរស់នៅជាមួយរបរនេះប្រាំមួយឆ្នាំហើយ គឺតាំងពីខ្ញុំចូលមកគ្រប់គ្រងរបរនេះពេញដៃម៉្លេះ។ ហើយថ្ងៃក្រោយ បើនាងរៀបការមានគ្រួសារ នាងនឹងចាប់អាជីពលក់ចាប់ហួយនេះ លែងចាប់យកអាជីពខាងសម្ផស្សហើយ។

«កុម្ម៉ង់គេតាមហ្នឹងចុះណា!» ខ្ញុំពិនិត្យបញ្ជីទិញទំនិញហើយ ក៏ហុចឱ្យចន្ទ្រាវិញ។ ចន្ទ្រាក៏ចូលទៅក្នុងហាងវិញ។

ភ្លាមនោះឡានមួយគ្រឿងមកឈប់ក្បែរ... គ្មានអ្នកណាទេ គឺបងវិសុន គូដណ្តឹងរបស់ខ្ញុំនោះអី។ បងវិសុនចុះពីលើឡាន ហើយដើរសំដៅមកខ្ញុំ ថ្ងៃនេះគាត់តែងខ្លួនសង្ហាណាស់។

«ធ្វើខ្លួនម៉េះ? គ្រាន់តែជូនប្អូនថ្ងៃឡើងយន្តហោះសោះ!» គ្រាន់តែគាត់ដើរមកជិតភ្លាម ខ្ញុំបង្អាប់ភ្នែត។

«មិនឱ្យតែងខ្លួនម៉េចត្រូវទៅកន្លែងដែលយើងចួបគ្នាដំបូងនោះអី!» គាត់តប។ មែនហើយ កាលនោះបន្ទាប់ពីបែកគ្នាអស់១០ឆ្នាំ យើងចួបគ្នាម្តងទៀតនៅព្រលានយន្តហោះហ្នឹងឯង គឺនៅថ្ងៃដែលជេដ្ឋាឡើងយន្តហោះ។ ចំណែកថ្ងៃនេះ គឺដល់វេនមុទិតាឡើងយន្តហោះម្តងហើយ ព្រោះនាងទទួលបានអាហារូបករណ៍ទៅសិក្សានៅប្រទេសស្វីសដូចបងប្រុសនាងដែរ។

ប៉ា! ប៉ាឃើញអត់? កូនរបស់ប៉ា ពូកែណាស់! សូម្បីតែកូន ក៏កូនបានបំពេញសន្យាជាមួយប៉ាដែរ! កូនចាប់ផ្តើមចូលរៀនយឺត តែកូនសំខាន់កូនបានចាប់ផ្តើម! ហើយទោះមានរឿងអ្វីកើតឡើង ក៏កូនមិនឈប់រៀនដែរ! កូននៅតែរៀន កូននឹងរៀនដល់សក់ស្កូវដុះពេញក្បាល! ទោះពេលនោះកូនចាស់ជ្រីវជ្រួញដល់ថ្នាក់បងវិសុនឈប់ស្រលាញ់ ក៏កូននៅតែរៀនដែរ។

«តស់! រួចរាល់ហើយ!» ម៉ាក់និងមុទិតាអូសវ៉ាលិសដើរចេញមក។ បងវិសុនរត់ទៅជួយកាន់វ៉ាលិសពីដៃម៉ាក់និងប្អូនថ្លៃ ហើយលើកដាក់គូទឡាន។ ខ្ញុំឈរសម្លឹងមើលដើមពុទ្រាថ្មីដែលដុះលូតលាស់យ៉ាងល្អ ហើយសម្លឹងមើលបាតដៃខ្លួនឯងដែលមានប្រឡាក់ពណ៌លាងមិនជ្រះ។ គឺមកពីព្រឹកមិញខ្ញុំឆ្លៀតគូរគំនូររូបដើមពុទ្រា ហើយដៃប្រឡាក់ពណ៌លាងសម្អាតមិនជ្រះអស់! តែមិនអីទេ ដៃជាងគំនូរប្រឡាក់ពណ៌ មានអីទាស់ខុស?

គិតរួច ខ្ញុំឡើងឡានអង្គុយទន្ទឹមបងវិសុនដើម្បីជូនដំណើរប្អូនស្រីពៅបន្តការសិក្សានៅប្រទេសស្វីស ហើយពេលត្រលប់មកផ្ទះវិញ ខ្ញុំត្រូវគូរគំនូររូបដើមពុទ្រានោះបង្ហើយ។

**-ចប់-**